# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី៣៤ លេខ ៨ ខែ សីហា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -

ក-228-2

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ផ្នែកសាសនា — ទំព័រ

– គិហិសមណសុខកថា ព្រះមុនីកោសល សួរ-ហាយ តែងនិងរៀបរៀង . . . . . ៨៤៥
– គោលច្បាប់ព្រះពុទ្ធសាសនា លោក ហេង-សមអាន តែងនិងរៀបរៀង . . . . ៨៦១
– ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) លោកប៊ូ-ប៊ូ ប្រែរៀបរៀង (ត) . . . . . ៨៧៧
– មធុរសវាហិណី សម្ដេចព្រះធម្មលិខិត ល្វី-ឯម ឧត្ដមប្រឹក្សា ប្រែរៀបរៀង (ត) . . . ៨៨៩
– មហោសថជាតក លោក អ៊ឹម-ភន បម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ (ត) ៨៩៩

ផ្នែកអក្សរសាស្ត្រ

– ភាសានិងអក្សរសាស្ត្រខ្មែរ លោក ឌឹក-ធាម តែងនិងរៀបរៀង ( តចប់ ) . . . . ៩០១
– សិលាចារឹកនៅប្រាសាទវិមានអាកាស ព្រះមហា ប៉ាង-ខាត់ ប្រែរៀបរៀង . . . ៩១៥
– អង្គរនិងសម័យអង្គរ លោក ផេង-ជ្រឹវ ប្រែពីទស្សនាវដ្ដី “ញូវ-អ៊្វីយ៉ង់” (ក្រុងប្រាក) លេខ ៣|១៩៦១ ( តចប់ ) . . . . . . . . . . . . . . ៩២៤
– ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ “ក” (ត) . . ៩៣៨
– វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង (ត) . . . . . . . ៩៣៩
– រឿងសាមកុក អ្នកឧកញ៉ា នូ-កន ប្រែរៀបរៀង (ត) . . . . . . . . . ៩៤០
– សកម្មភាពក្រុមជំនុំទំនៀមទម្លាប់ខ្មែរ . . . . . . . . . . . ៩៤៥

បច្ចុប្បន្នភាពជាតិ

– ពិធីសម្ពោធព្រះវិហារអាពាធិការនុគ្រោះ និងពិធីបញ្ចុះសីមាវត្តអង្គសិម្ពលី . . . . . ៩៥២

មួយឆ្នាំមាន ១២ លេខ តម្លៃជាវ ២៣០៛០០

34è Année — N° 8 — Aout 1962

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

## SOMMAIRE

### Partie religieuse

—Gihisamanasokhakatha par Préah Monikosal SO-HAY . . . . . 845
—Principes bouddhiques par M. HENG-SAM-AN . . . . . . . . . 861
—Préah Abhidhammapitaka «Kampir Préah Yamaka»
par M. BOU-PO (suite) . . . . . . . . . . . . . . . . 877
—Madhurasavahini par Samdech Préah Dhammalikhita
LOUIS-EM Haut conseiller (suite) . . . . . . . . . . . . 889
—Mahosotha Jataka (suite) . . . . . . . . . . . . . . . . 899

### Partie littéraire

—Le Langage et la littérature Khmèrs par M.DIK-KEAM (suite et fin) 901
—Inseription Khmèrs au monument de Viméan-Akas traduite par
le Vén. PANG-KHAT. . . . . . . . . . . . . . . . . . 915
—Angkor et son époque traduit de New-Orient (Prague) n° 3/1961
par M. PHÉNG-CHRIV ( suite et fin ) . . . . . . . . . . . . 924
—Activité de la Commission Culturelle chapitre «Ka» (suite) . . . 938
—Dictionnaire Sanscrit-Khmer par Vén. PANG-KHAT (suite) . . . 939
—Histoire de Sam-Kok traduite par Oknha NOU-KAN (suite) . . . 940
Activités de la Commission des mœus et coutumes . . . . . . . 945

### Actualités Nationales

—Cérénomie D'inaguration du temple APÉATHIKARNUKROH et
Cérénomie de pose de pierres Sima de la Pagode ANGSIMBALI 952

---

Prix d'Abonnement annuel (comprenant 12 numéros) : 230 $ 00

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ដាក់ការលាមក, ឲ្យធ្វើល្អទៅ ។
ឲ្យជិះសាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

## គិហិសមណសុខកថា

ព្រះមុនីកោសល សួរ-ហាយ អធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ចត្តារិមានិ គហបតយោ គិហិសុខានិ

អត្ថិសុខំ ភោគសុខំ អនណសុខំ អនវជ្ជសុខំ ។

*នេះជាពុទ្ធភាសិត ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងអំពីសេចក្ដីសុខរបស់គ្រហស្ថចំពោះពួកគហបតី ដូចសេចក្ដីវែកញែក អធិប្បាយពង្រីកទុកជាសណ្ដាប់នៃសិក្ខាកាមកុលបុត្រ តទៅនេះ*

### សេចក្ដីប្រែនៃពុទ្ធភាសិត

*ម្នាលគហបតីទាំងឡាយ សុខរបស់គ្រហស្ថនេះមាន ៤ យ៉ាងគឺ ៖*

*១– អត្ថិសុខ សុខព្រោះមានទ្រព្យ*

២- ភោគសុខ    សុខព្រោះប្រើប្រាស់ទ្រព្យ

៣- អណណសុខ    សុខព្រោះមិនជំពាក់បំណុល

៤- អនវជ្ជសុខ    សុខព្រោះមិនមានទោស ។

ពាក្យថា សុខនេះជាឥដ្ឋារម្មណ៍គឺអារម្មណ៍ជាទីប្រាថ្នា ជាទីពាប់ចិត្ត របស់មនុស្សសត្វ ។ សេចក្ដីស្រួលកាយសប្បាយចិត្ត របស់មនុស្សសត្វគ្រប់ជាតិក្នុងសកលលោក ហៅថា សុខ គឺលទ្ធផលណាមួយ ដែលនាំចិត្តមនុស្សសត្វឲ្យត្រេកអរីករាយ ឲ្យត្រូវការចង់បាន ចង់ជួបប្រទះ ។ ពាក្យថា សុខ នេះ ទុកជាបញ្ហាមួយ ដែលមនុស្សសត្វតែងដោះស្រាយដោយមធ្យោបាយផ្សេង ៗ គ្នា ដើម្បីស្លាក់រកឲ្យជួបប្រទះ ។ សេចក្ដីសុខជាធម្មជាតិមួយ ដែលជាទីស្រឡាញ់ពេញចិត្តរបស់មនុស្សសត្វទាំងអស់ឥតមាននរណាមួយ បដិសេធចោលឡើយ គឺមនុស្សគ្រប់ប្រភេទ សុទ្ធតែបែរមុខឈមទៅរកសេចក្ដីសុខគ្រប់ ៗ គ្នា ។ ករណីយកិច្ចដើម្បីរស់នៅរបស់មនុស្សគ្រប់ជាន់ថ្នាក់ មានរបរកសិកម្មពាណិជ្ជកម្មជាដើម សុទ្ធតែជាកិច្ចការឈមទៅរកសេចក្ដីសុខ នាំគ្នាបំពេរមុខព្រួញគឺសេចក្ដីប៉ុនប៉ងតម្រង់ទៅរកសេចក្ដីសុខតែម្យ៉ាង ។ អ្នកដែលមានឧបាយប្រាជ្ញា មានព្យាយាម មានគំនិតល្អ ក៏អាចស្វែងរកសេចក្ដីសុខបានដោយងាយ អ្នកដែលគ្មានឧបាយប្រាជ្ញា គ្មានព្យាយាម គ្មានគំនិតល្អ ក៏ស្វែងរកសេចក្ដីសុខបានដោយលំបាកណាស់ ។

ពាក្យថា សុខ មួយម៉ាត់នេះ នាំឲ្យបែកសាខាមានកម្មវិធី ឬផែនការ ជាច្រើនបែប ដូចយើងបានឃើញជាក់ស្តែងស្រាប់ហើយ ព្រោះតែ សេចក្តីសុខមួយប៉ុណ្ណេះ ៗ គ្រាន់តែការស្វែងរកសេចក្តីសុខ ដើម្បីជីវិត នេះនាំបណ្តាលហេតុមិនមែនតិចតួចទេ គឺនាំឲ្យមានជម្លោះឈ្លោះប្រកែក ទោទប្រកាន់ រហូតដល់ការប្រកាសសង្គ្រាមនឹងគ្នាទៅវិញទៅមក ព្រោះ តែការស្ទុះពន្ទះដណ្តើមដេញដើងគ្នា រកសេចក្តីសុខប៉ុណ្ណេះឯង នេះជា សេចក្តីបញ្ជាក់ឲ្យឃើញថា សុខមួយម៉ាត់នោះ ក៏អាចក្លាយទៅជាបញ្ហា សាំញ៉ាំដែលលំបាករកផ្លូវដោះស្រាយជាទីបំផុត ៗ

ក្នុងករណី ដូចសេចក្តីអធិប្បាយដោយសង្ខេបមកនេះ ទើបព្រះ សម្មាសម្ពុទ្ធ ទ្រង់សំដែង បញ្ញត្តធម៌វិន័យទុកមក ដែលយើងហៅថា ពុទ្ធសាសនា ប្រែថាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ៗ ពុទ្ធសាសនានេះ ហើយជាមធ្យោបាយមួយ ដ៏ប្រសើរបំផុត សម្រាប់ដោះស្រាយបញ្ហាក្នុង ការស្វែងរកសេចក្តីសុខ ដើម្បីមិនឲ្យប៉ះពាល់សិទ្ធិសេរីភាព ចំពោះ ជីវិត ទ្រព្យសម្បត្តិនឹងទីកន្លែង ដែលជាកម្មសិទ្ធិ របស់អ្នកណាមួយ ៗ នេះជាបុព្វកថាបរិយាយចំពោះពាក្យថា សុខ ៗ

## អធិប្បាយពង្រីកសេចក្តី គិហិសុខ ២ យ៉ាង

សេចក្តីសុខនេះ បើចែកតាមប្រភេទនៃបុគ្គលមាន២យ៉ាងគឺ គិហិ-សុខ សុខរបស់គ្រហស្ថ១ សមណសុខ សុខរបស់សមណៈ១ ៗ

ក្នុងអត្ថបទខាងដើមនេះ សូមសំដែងចំពោះ គិហិសុខ ជាមុន, លុះចប់សេចក្ដីអធិប្បាយអំពីគិហិសុខ ទើបសំដែងចំពោះ សមណសុខ មាន ៨ យ៉ាង តទៅជាខាងក្រោយ ។

១– អត្ថិសុខ សុខព្រោះមានទ្រព្យ ។ ទ្រព្យសម្បត្តិគ្រប់យ៉ាង ទោះជាទ្រព្យសង្ហារិមត្ថ ទ្រព្យអសង្ហារិមត្ថ រមែងប្រគល់សេចក្ដីសុខដល់ជនជាម្ចាស់ ដោយពិតប្រាកដ ប៉ុន្តែទ្រព្យទាំងនោះសំដៅយកទ្រព្យដែលស្វែងរកបានមកដោយផ្លូវធម៌ រាប់ថាជាទ្រព្យបរិសុទ្ធផុតអំពីសេចក្ដីរង្កៀសចោទប្រកាន់របស់បុគ្គលណាមួយ ជាទ្រព្យប្រកបដោយកម្មសិទ្ធិបរិបូណ៌ ទាំងការថែទាំ រក្សាទុកដោយការប្រយ័ត្ន មិនឲ្យមានអន្តរាយ មានអគ្យន្តរាយជាដើម ។ ទ្រព្យគ្រប់យ៉ាង ដែលជនជាម្ចាស់ទុកដាក់ក្នុងផ្ទះក្ដី នៅក្រៅផ្ទះក្ដី កាលបើជនជាម្ចាស់ត្រូវការប្រើប្រាស់ចាយវាយក្នុងវេលាណាមួយ ក៏អាចចាយវាយបានដោយស្រួល មិនបាច់ព្រួយបារម្ភចំពោះការខ្វះខាតឡើយ ។ ទ្រព្យសម្បត្តិដែលមានបាននេះ ជាគ្រឿងញុំាងចិត្តនៃជនជាម្ចាស់ ឲ្យកើតសេចក្ដីសប្បាយ រីករាយជានិច្ច ដោយហេតុថា ទ្រព្យគ្រប់យ៉ាងដែលមានបាននេះ កាលបើជនជាម្ចាស់ ប្រាថ្នាត្រូវការទិញដូររបស់ណាមួយក៏អាចទិញដូរបានភ្លាម ៗ តាមសេចក្ដីពេញចិត្ត ដែលខ្លួនចង់បាន ដោយសេចក្ដីសប្បាយ ឥតមានព្រួយលំបាកចិត្តក្នុងការស្វែងរកខ្ចីបុលបួងការអ្នកណាឡើយ ។ ទ្រព្យសម្បត្តិដែលមាន

នៅក្នុងអំណាចរបស់ជនជាម្ចាស់.ខ្លះ ប្រាកដជាសុខចិត្តនៃគ្រហស្ថ កប់ ជាជាប្រភពមួយរបស់សេចក្តីសុខ សមដូចភាសិតថា "ទ្រព្យទ្រនាប់ខ្លួន" ដែលកើតមានដល់ជនជាម្ចាស់ ។

អត្ថិសុខ ដែលអាចកើតឡើងបាន ដោយអាស្រ័យ ទិដ្ឋធម្មិកត្ថ (ប្រយោជន៍បច្ចុប្បន្ន) ៤ យ៉ាង មានឧដ្ឋានសម្បទាជាដើម សូមលោកអ្នកអានទាំងឡាយ សិក្សាក្នុងប្រយោជន៍បច្ចុប្បន្ន ៤ យ៉ាងនោះចុះ ។ ប្រយោជន៍ ៤ យ៉ាងនោះហើយ ទុកថាជាកម្មវិធីធំបំផុត សម្រាប់ស្វែងរកទ្រព្យសម្បត្តិឲ្យមានបាន ដើម្បីជីវិតជាសុខចម្រើន ឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្នដោយពិត ។

២- ភោគសុខ សុខព្រោះប្រើប្រាស់ទ្រព្យ ។ ការចាយវាយទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់ខ្លួន ក្នុងការទិញដូរវត្ថុណាមួយក្តី ក្នុងការបរិច្ចាគទានចំពោះសមណបព្វជិតក្តី ក្នុងការសង្គ្រោះដោះទុក្ខខ្លួនឯងឬអ្នកណាមួយក្តី ក្នុងការទំនុកបម្រុងជាតិសាសនាក្តី ក៏អាចមានសិទ្ធិបរិបូណ៌ ក្នុងការប្រើប្រាស់ចាយវាយជាដរាប ។ ការបញ្ចេញទ្រព្យសម្បត្តិ ដើម្បីប្រើប្រាស់ចាយវាយដោយសេចក្តីពេញចិត្តនេះ ទុកថាជាការសប្បាយរីករាយមួយ របស់ជនជាម្ចាស់ ដូចយ៉ាងការចាយវាយទ្រព្យសម្បត្តិ ដើម្បីសង់សេនាសនៈ សម្រាប់បម្រើព្រះពុទ្ធសាសនាក្តី សង់សាលាសិក្សាសម្រាប់ជាតិ ឬលើកថ្នល់ សង់ស្ពាន ជីកស្រះអណ្តូងក្តី

ធ្វើបុណ្យបំពេញកិច្ចកតញ្ញូកតវេទិតាធម៌ ចំពោះលោកអ្នកមានគុណ មានមាតាបិតាជាដើមក្តី ។ ការប្រើប្រាស់ចាយវាយទ្រព្យសម្បត្តិ ត្រូវតាមគោលបំណងរបស់ខ្លួននេះ ជាការនាំមកនូវសេចក្តីសុខសប្បាយ រីករាយត្រេកអរដ៏ក្រៃលែងរបស់ជនជាម្ចាស់ដោយពិត ពោះបើប្រើប្រាស់ចាយវាយទ្រព្យសម្បត្តិទាំងនោះ របេះតែរលស់ទៅ អស់ទៅពិតមែន ប៉ុន្តែជាហេតុឲ្យមានបីតិបាមោជ្ជៈ គឺមានអំណរសុខចិត្ត សប្បាយចិត្តជារឿយៗកើតឡើងព្រោះការចាយវាយដោយចិត្តជ្រះថ្លា ឬ ចិត្តជាព្រហ្មវិហារ ពុំមែនក្តៅក្រហាយចិត្ត ដូចការអស់ទ្រព្យ ព្រោះអន្តរាយ មានចោរន្តរាយជាដើមនោះឡើយ ។

ការប្រើប្រាស់ចាយវាយទ្រព្យ ប្រកបដោយធម៌នេះ ជាផ្លូវនាំមកនូវសេចក្តីសុខចិត្តរបស់គ្រហស្ថ ទាំងបច្ចុប្បន្នទាំងបរលោក ។ ការមិនបានប្រើប្រាស់ចាយវាយទ្រព្យ ដោយភាពនៃបុគ្គលជាមនុស្សមានមច្ឆរិយៈ ក៏រាប់ថាជាទុក្ខទោសមួយ របស់ជនជាម្ចាស់ទ្រព្យសម្បត្តិ ។

៣- អណណសុខ សុខព្រោះមិនជំពាក់បំណុល ។ ការជំពាក់បំណុលគេ ឈ្មោះថាជាទុក្ខព្រួយមួយដែលឲ្យផលផ្ទុយគ្នានឹងគ្មានបំណុល ដោយគិតឃើញថា អាត្មាអញ ជាប់ជំពាក់ទាក់ទិនទ្រព្យសម្បត្តិគេ មិនដឹងជាគេនឹងមកគម្រាមកំហែងតឹងទារបែបស្តីកន្លងថ្ងៃណាមួយទេ ធម្មតាអ្នកជំពាក់បំណុលគេ តែងមានសេចក្តីទុក្ខព្រួយ គានតឹងចំបែងក្នុងទ្រូងជានិច្ច

ទាំងការប្រមាថមើលងាយ អំពីជនជាម្ចាស់បំណុលក៏តែងមានជាទំនៀមៗ ភាពនៃជនអ្នកជំពាក់គេ តែងមានសេចក្ដីទុក្ខក្រៀមក្រំជានិច្ច ឥតមានមុខស្រស់ស្រាយសប្បាយចិត្តទេ ៗ ភាពនៃការមិនជំពាក់បំណុលគេ ទើបជាហេតុនាំមកនូវសេចក្ដីសុខសួស្ដី ក្នុងចិត្តរបស់ខ្លួន ដែលនាំចិត្តឲ្យអរសប្បាយ រីករាយរៀងរាល់ថ្ងៃ ៗ

៤– អនវជ្ជសុខ សុខព្រោះមិនមានទោស ៗ ការមានទោសក្នុងផ្លូវអាណាចក្រក្ដី ក្នុងផ្លូវពុទ្ធចក្រក្ដី សុទ្ធតែជាហេតុនាំមកនូវវិប្បដិ-សារៈ គឺសេចក្ដីក្ដៅក្រហាយ ស្ដាយក្រោយជាប្រាកដ ដូចយ៉ាងភាពនៃខ្លួន ប្រព្រឹត្តចោរកម្មក្ដី លក់ដូររបស់ខុសបញ្ញត្តិរបស់រាជការក្ដី ឬប្រព្រឹត្តទាស់ខុស ចំពោះអំពើណាមួយក្ដី សុទ្ធតែនាំមកនូវសេចក្ដីទុក្ខព្រួយ ទាំងអស់ ចំណែកខាងទោសក្នុងផ្លូវពុទ្ធចក្រ ដូចយ៉ាងប្រព្រឹត្តទុច្ចរិត ដោយកាយវាចាចិត្ត ក្នុងផ្លូវអកុសលកម្មបថ ១០ មានការសម្លាប់សត្វ លួចប្លន់បោកប្រាស់ទ្រព្យគេ និងការប្រព្រឹត្តិខុសចំពោះកូនប្រពន្ធគេជាដើម ឬក៏ធ្វើខ្លួនឲ្យថ្លស់ធ្លោយធ្លាក់ទៅក្នុងអបាយមុខ៤ប្រការ មានល្បែងស៊ីសងជាដើម ទាំងនេះសុទ្ធតែជាទោសនាំមកនូវទុក្ខភ័យ ទាំងក្នុងបច្ចុប្បន្ននិងបរ-លោក ដែលផ្ទុយគ្នានឹងការគ្មានទោស ៗ ការមិនមានទោស ទើបជាហេតុនាំមកនូវសេចក្ដីសុខសប្បាយដោយពិត, ភាពនៃបុគ្គលអ្នកមិនមានទោស ក្នុងផ្លូវទុច្ចរិតណាមួយនេះជាការប្រសើរបំផុត ដោយហេតុថាជា

អ្នកបេះប្រកបការរស់នៅដោយសុខស្រួល ប្រាសចាកសេចក្តីរង្កៀសអំពីខ្លួនឯងផង អំពីអ្នកដទៃផង ឈ្មោះថាជាអ្នករស់នៅរួចខ្លួន អំពីទុក្ខភ័យទោសទណ្ឌទាំងបច្ចុប្បន្នទាំងបរលោក ។ ភាពនៃការមិនមានទោសនេះរមែងសុខចិត្តរបស់គ្រហស្ថដែលមូលមិត្រជាមួយនឹងគ្រួសាររៀងរាល់ថ្ងៃៗ

គិហិសុខទាំង ៤ ប្រការ បានវែកញែកអធិប្បាយពន្យល់ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះ ។ សេចក្តីសុខរបស់មនុស្ស ទោះបីមានច្រើនស្ថានក៏ពិតមែន ប៉ុន្តែសេចក្តីសុខទាំង ៤ យ៉ាង ដូចអធិប្បាយមកហើយនោះ ឈ្មោះថាជាសុខចាំបាច់របស់គ្រហស្ថដោយពិត ព្រោះថាគ្រហស្ថជាអ្នកទទួលភារៈគ្រប់គ្រងផ្ទះគឺគ្រួសារ តែងមានកិច្ចការច្រើន មានកង្វល់បលិពោធច្រើន មានមុខការត្រូវចាយវាយច្រើន ម្យ៉ាងហើយបានជាគ្រហស្ថភាគច្រើន តែងប្រាថ្នាចំពោះភាពនៃខ្លួនជាអ្នកមានទ្រព្យ, ការប្រើប្រាស់ចាយវាយទ្រព្យ, ភាពនៃខ្លួនមិនជំពាក់បំណុលគេ នឹងភាពនៃខ្លួនមិនមានទោស ។ សេចក្តីប្រាថ្នារបស់គ្រហស្ថដែលសុខចិត្តចំពោះភាពនៃខ្លួនជាអ្នកមានទ្រព្យជាអាទិ៍នេះ កាលបើសេចក្តីសុខចិត្តបានសម្រេចហើយ ឈ្មោះថាជាសុខក្នុងផ្លូវចិត្ត សមដូចសេចក្តីប្រាថ្នានោះឯង ។ មនុស្សគ្រប់រូប កាលបើមានបំណងប្រាថ្នាចំពោះហេតុការណ៍ណាមួយហើយមិនបានសម្រេចដូចប្រាថ្នា រមែងនាំមកនូវទុក្ខ ដែលធ្វើឲ្យគ្មាននឹងសេចក្តីសុខពុំមាន ដូចយ៉ាងទលិទ្ទភាព (ភាពនៃសេចក្តីទាល់ក្រ) នេះជា

ទុក្ខមួយរបស់គ្រហស្ថ, ភាពនៃការមិនមានទ្រព្យប្រើប្រាស់, ភាពនៃខ្លួនជាអ្នកជំពាក់បំណុលគេ និងភាពនៃខ្លួនជាអ្នកមានទោស ទាំងនេះសុទ្ធតែជាទុក្ខរបស់គ្រហស្ថជាប្រាកដ ព្រោះមិនសុខចិត្ត ចំពោះភាពទាំងនោះទេ ដោយហេតុថា ទលិទ្ទភាពជាដើម ជាអនិដ្ឋារម្មណ៍របស់គ្រហស្ថ ពុំមែនជាឥដ្ឋារម្មណ៍ឡើយ ។ ចំពោះគិហិសុខ ៤ យ៉ាង ដូចអធិប្បាយមកហើយ ឈ្មោះថាជា គិហិសុខ ផង ជា ឥដ្ឋារម្មណ៍ នៃគ្រហស្ថផង ជាវិតបំណងត្រូវតាមគោលដៅនៃគ្រហស្ថផង ។

ជនជាគ្រហស្ថ កាលបើប្រកបដោយគិហិសុខ ៤ យ៉ាងហើយ ត្រូវតម្កល់ខ្លួនក្នុងស្ថាន ៤ យ៉ាងទៀត ទើបទ្រទ្រង់ឋានៈនៃខ្លួនជាគ្រហស្ថឲ្យគង់វង្សជាស្ថាពរតទៅបាន ។

ស្ថាន ៤ យ៉ាងនោះគឺ

១- ស្វែងរកទ្រព្យដែលវិនាស ឲ្យមានបានឡើងវិញ

២- ជួសជុលរបស់ដែលចាស់គ្រាំគ្រា

៣- ដឹងប្រមាណក្នុងការប្រើប្រាស់ទ្រព្យ

៤- តាំងស្ត្រី ឬ បុរសមានសីល ឲ្យជាអ្នកកាន់ការផ្ទះ ។

សំដែងអំពីគិហិសុខ ៤ យ៉ាង ចប់តែប៉ុណ្ណេះ

សមណសុខ ៨ យ៉ាង

បន្ទាប់តទៅនេះ សូមសំដែងចំពោះសមណសុខ ដែលមានមកក្នុង

អដ្ឋកថាជាតក ឯកនិបាត ដូចសេចក្ដីដែលវែកញែកអធិប្បាយ ដោយសង្ខេបតទៅ

សមណាសុខ ៨ យ៉ាង

១- ធនធញ្ញបរិគ្គហាភាវោ ការមិនមានសេចក្ដីហួងហែងចំពោះទ្រព្យសម្បត្តិនិងស្រូវអង្ករ ;

២- អនវជ្ជបិណ្ឌបាតបរិយេសនភាវោ ភាពនៃការស្វែងរកចំពោះបិណ្ឌបាត ដែលឥតទោស គឺបិណ្ឌបាតប្រកបដោយធម៌ ;

៣- និព្វុតបិណ្ឌបាតភុញ្ជនភាវោ ភាពនៃការបរិភោគអាហារបិណ្ឌបាតដ៏ត្រជាក់ ;

៤- រដ្ឋបីឡនាភាវោ ការមិនមានការបៀតបៀនអំពីអ្នកដែន;

៥- ឧបករណេសុ និច្ឆន្ទរាគភាវោ ភាពនៃសមណៈមិនមានឆន្ទរាគ ក្នុងឧបករណ៍ ;

៦- ចោរវិលោបេ និព្ភយភាវោ ភាពនៃសមណៈមិនមានភ័យ ក្នុងការលួចប្លន់នៃចោរ ;

៧- រាជរាជមហាមត្តេហិ អសំសដ្ឋភាវោ ភាពនៃសមណៈ មិនជាប់ចំពាក់ ដោយស្ដេចនិងមហាមាត្រនៃស្ដេច ;

៨- ចតូសុ ទិសាសុ អប្បដិហតភាវោ ភាពនៃសមណៈ មិនទើសទាក់ចំពោះទិសទាំងបួន ។

## អធិប្បាយពង្រីកសេចក្ដី

១- ពាក្យថា " មិនមានសេចក្ដីហួងហែងចំពោះទ្រព្យសម្បត្តិនិងស្រូវអង្ករ " ដោយហេតុថា សមណៈជាបព្វជិតក្នុងព្រះពុទ្ធសាសនា ជាអ្នកមានករណីយកិច្ចដោយឡែកផ្សេងពីគ្រហស្ថហើយ មិនត្រូវមានការខ្វល់ខ្វាយស្វែងរកទ្រព្យសម្បត្តិ និងធញ្ញជាតិផ្សេងៗ មានស្រូវអង្ករជាដើមទេ បើទុកជាបានទ្រព្យសម្បត្តិជាសមណបរិក្ខារដោយសទ្ធាជ្រះថ្លារបស់គ្រហស្ថក៏មិនត្រូវហួងហែង ទុកដាក់លាក់រក្សា ដែលប្រកបដោយមច្ឆរិយៈទេ ។ ការហួងហែង ការលាក់លៀម ការបំបិទបំបាំង ដោយការទុកដាក់នេះ លោករាប់ថាជាហេតុមួយនាំមកនូវទុក្ខរឿយៗ ព្រោះជាហេតុនាំឲ្យមានសេចក្ដីទុក្ខព្រួយ ភ័យបារម្ភជានិច្ច ចំពោះទ្រព្យសម្បត្តិដោយខ្លាចក្រែងអន្តរាយផ្សេងៗ មានចោរន្តរាយជាដើម ។ ត្រង់ការដែលគ្មានសេចក្ដីហួងហែងនេះ ឈ្មោះថាជាសុខចិត្តរបស់សមណៈដោយពុំមានទុក្ខព្រួយក្នុងការថែទាំ ។ ពាក្យថា សមណៈនេះពុំបានអធិប្បាយទេ គឺសំដៅយកបុគ្គលជាបព្វជិត ក្នុងព្រះពុទ្ធសាសនា ។

២- ពាក្យថា " ការស្វែងរកបិណ្ឌបាត ដែលឥតទោស " បានដល់ការស្វែងរកអាហារប្រកបដោយធម៌វិន័យ ដែលជាការស្វែងរក ប្រាសចាកអនេសនធម៌ ។ ការរស់នៅរបស់សមណៈ តែងជាប់ទាក់ទងដោយគ្រហស្ថដែលមានសទ្ធាជ្រះថ្លាដោយពិត ប៉ុន្តែមិនមែនរស់ដោយកិច្ចទាក់

ទទឹងគ្រហស្ថ ក្នុងផ្លូវទាំងឡាយមានពាណិជ្ជកម្ម កសិកម្ម ឬ រដ្ឋកម្ម ជាដើមឡើយ ។ ការស្វែងរករបស់សមណៈ ដើម្បីជីវភាពរបស់ខ្លួន ត្រូវប្រកបដោយផ្លូវបរិសុទ្ធវិសេសជាងគ្រហស្ថ ទើបសមគួរដល់ឋានៈនៃខ្លួនជាសមណៈជាបុព្វាគេតក្នុងព្រះពុទ្ធសាសនា, មិនត្រូវបណ្តោយឲ្យការរស់នៅរបស់ខ្លួនជាសមណៈប្រឡូកប្រឡំដោយផ្លូវទុច្ចរិតទេ ។ ការស្វែងរកបិណ្ឌបាត ដែលប្រាសចាកទោសនោះ សំដៅយកការវៀរស្រឡះចាកបាបធម៌ នឹងអនេសនធម៌ ឈ្មោះថាជាការស្វែងរកដ៏បរិសុទ្ធរបស់សមណៈ លោកចាត់ថាជាសុខរបស់សមណៈ ដោយអាជីវៈបរិសុទ្ធ ដែលគេមិនអាចចាប់ថ្នាក់បាន ។

៣- ពាក្យថា "ការបរិភោគអាហារបិណ្ឌបាតដ៏ត្រជាក់" ដោយហេតុថា សមណៈ ដែលស្ម័គ្រចិត្តទទួលផ្នួសក្នុងព្រះពុទ្ធសាសនា ត្រូវជាអ្នកសុខចិត្ត ព្រមទទួលអាហារបិណ្ឌបាតតាមតែប្រទះ គឺចួនកាលបានអាហារត្រជាក់ ចួនកាលបានអាហារក្តៅ ប៉ុន្តែធម្មតាអាហារបិណ្ឌបាតដែលតាយកតាយិកា ដោះដួសចម្រុងទុកដាក់បាត្រនោះ បើទើបនឹងដោះចី ។ ហើយភិក្ខុសាមណេរបានទៅទទួលបិណ្ឌបាតជាដំបូងក្នុងកាលដែលនៅក្តៅ, ក៏ជាភ័ព្វរបស់ភិក្ខុសាមណេរ ដែលទទួលបិណ្ឌបាតមុននោះមួង ។ ។ តាមដោយពិត អាហារបិណ្ឌបាតសម្រាប់ដាក់អង្គគ្រប់ពោះព្រះសង្ឃច្រើនតែត្រជាក់ ព្រោះគេដោះដួសទុកយូរ ដើម្បីព្រះសង្ឃដែល

និមន្តមកបិណ្ឌបាត ដែលឃ្លាតពេលពីគ្នា គឺចួនកាលព្រះសង្ឃពីរ ឬ បី រូបមកទទួលបិណ្ឌបាតជាមួយគ្នា ចួនកាលព្រះសង្ឃ ១ រូប ៗ មកទទួល រយៈល ៗ អំពីគ្នា ម៉្លោះហើយអាហារបិណ្ឌបាតនោះ ក៏ទៅជាអាហារត្រជាក់ ៗ សមណៈដែលរស់នៅដោយអាហារបិណ្ឌបាតនេះ ពុំសូវបានអាហារក្តៅទេ ច្រើនតែប្រទះអាហារត្រជាក់ ៗ ត្រង់ការដែលសមណៈព្រមសុខចិត្តបរិភោគអាហារត្រជាក់នេះ រាប់ថាជាតបធម៌មួយ របស់សមណៈ សម្រាប់ញុំាងចិត្តឲ្យស្លូតស្ងប់ ឈ្មោះថាជាសុខស្រួលរបស់សមណៈក្នុងការទូន្មានចិត្ត មិនបណ្តោយចិត្តឲ្យរេហើររហាប់រលោរលាំ សព្វបើគ្រាន់តែរសអាហារនោះឡើយ ៗ

៤– ពាក្យថា “មិនមានការបៀតបៀនអំពីអ្នកដែន” ដោយហេតុថាសមណៈមានភាពជាអ្នកស្លូតសុភាព មានកាយវាចាចិត្តស្ងប់ តាមត្រៃសិក្ខាសម្រាប់សមណៈមិនមានអ្នកពជការបៀតបៀន ឬប្រើអំណាចយសសក្តិជិះជាន់សង្កត់សង្កិន រឹបអូសយកទ្រព្យសម្បត្តិដូចជនអ្នកនៅក្នុងដែនណាមួយទេ, ពុំមែនដូចជាមនុស្សក្នុងដែនដែលត្រូវបង់ពន្ធដារ ឬត្រូវគេមានអំណាចបៀតបៀន ដោយឧបាយណាមួយ ដើម្បីឲ្យបានទ្រព្យសម្បត្តិ មានមាសប្រាក់ជាដើម អំពីសមណៈនោះឡើយ ៗ ការមិនប្រព្រឹត្តបៀតបៀនអំពីអ្នកពជការក្នុងដែននេះ ឈ្មោះថាសុខរបស់សមណៈ

ដោយពុំមានគេចោទប្រកាន់គំនិតរបៀតបៀន ដែលនាំឲ្យមានឈ្មោះសៅហ្មងនោះឡើយ ។

៥- ពាក្យថា "មិនមានធនធូរភក្នុងឧបករណ៍" នោះសំដៅយកភាពនៃសមណៈ មិនមានសេចក្ដីប្រាថ្នាប៉ុនប៉ងគ្រោគអរាវរៈរវាមចំពោះគ្រឿងប្រើប្រាស់ មានចីវរជាដើមនោះទេ ។ គ្រឿងឧបករណ៍ផ្សេងៗមានចីវរទីងសេនាសនៈជាដើម ដែលសមណៈ បានទទួលមកហើយប្រកបដោយធម៌ជារបស់ខ្លួនខ្ចស់ក្ដី ថោកទាបក្ដី មិនត្រូវជាប់ចំពាក់ឬរិះគន់រើសអើង ចំពោះគ្រឿងឧបករណ៍នោះឡើយ ។ ត្រូវតាំងចិត្តជាឧបេក្ខាក្នុងគ្រឿងឧបករណ៍ជាដរាប ។ គ្រឿងឧបករណ៍ដែលមិនទាន់បានមក ក៏មិនត្រូវប្រាថ្នា រវះរវាមហួសហេតុ ដើម្បីរក្សាភាពនៃខ្លួនជាសមណៈឲ្យបិតនៅល្អ ។ គ្រង់ដែលមិនមានធនធូរភគឺសេចក្ដីប្រាថ្នារហើររហាប់ក្នុងឧបករណ៍ ឈ្មោះថាជាសុខរបស់សមណៈ ដោយសេចក្ដីសន្ដោសពុំមានគេរិះគន់ពេបជ្រាយបាន ។

៦- ពាក្យថា "មិនមានភ័យក្នុងការលួចប្លន់នៃចោរ" បានដល់ភាពនៃសមណៈ មិនមានគិតភ័យព្រួយបារម្ភអំពីចោរដែលលួចប្លន់ ព្រោះសមណៈ ជាអ្នកមិនសន្សំទ្រព្យសម្បត្តិ ដែលគួរឲ្យចោរមានបំណងមកលួចប្លន់បានទេ ។ ការលួចប្លន់នៃចោរនេះ ជាទុក្ខភ័យមួយ របស់មនុស្សអ្នកមានទ្រព្យក្នុងលោក, ការមិនមានភ័យអំពីចោរលួចប្លន់ ឈ្មោះ

ថាជាសុខមួយដែរ ។ ភាពនៃសមណៈឈ្មោះថា ផុតចាកសេចក្តី ទុក្ខព្រួយអំពីចោរហើយ ទើបលោកចាត់ថាជាសុខរបស់សមណៈ ។

៧– ពាក្យថា "មិនជាប់ចំពាក់ដោយស្តេចនឹងមហាមាត្រនៃស្តេច" សំដៅយកភាពនៃសមណៈ មិនត្រូវប្រឡូកប្រឡំ ទាក់ទងញឹកញយដោយការចុះឡើងប្របូកប្របល់រឿយៗ ជាមួយនឹងស្តេចឬមហាមាត្រ (លោកអ្នករាជការ) របស់ស្តេចទេ ព្រោះថាស្តេចនឹងមហាមាត្រតែងមានកិច្ចការក្នុងប្រទេសច្រើនយ៉ាង សមណៈជាអ្នកមានភេទផ្សេង មានករណីយកិច្ចក៏ផ្សេង មិនត្រូវបណ្តោយខ្លួន ឲ្យមានការប្រព្រឹត្តជាប់ទាក់ទងប្រឡូកប្រឡំជាមួយដោយញឹកញយទេ ព្រោះថា ការជាប់ចំពាក់ដោយឥស្សរជនមានស្តេចជាដើមនោះ ជាហេតុនាំឲ្យឥស្សរជន ដែលមានកិច្ចការច្រើនរវល់នឹងបែរមកធ្វើបដិសណ្ឋារៈ ចំពោះសមណៈផង នាំឲ្យមានហេតុការណ៍ណាមួយ ពុំសមគួរដល់សមណភាពផង ។ ការមិនជាប់ចំពាក់នេះ ឈ្មោះថាជាសុខរបស់សមណៈ ដ្បិតសមណៈត្រូវមានឱកាសទំនេរ អំពីកិច្ចការរបស់គ្រហស្ថហើយ ។

៨– ពាក្យថា "មិនរើសទាក់ចំពោះទិសទាំង ៤" បានដល់ភាពនៃសមណៈដែលត្រាច់ទៅក្នុងទិសណាមួយ បណ្តាទិសទាំង ៤ ឬទិសទាំង ៨ របះតែអាចទៅបានទាំងអស់ មិនសូវមានចិត្តជាប់ចំពាក់ចំពោះទី

កន្លែងមួយៗទេ ដោយសមណៈជាអ្នកមិនមានទ្រព្យសម្បត្តិ ទុកជាកម្មសិទ្ធិរបស់ខ្លួននោះទេ ទោះបើនឹងចង់ត្រាច់ទៅកាន់ទិសណាមួយ ក៏អាចទៅបានដោយងាយ មិនលំបាកក្នុងការដោះខ្លួនចេញដូចគ្រហស្ថនោះទេ ។ ថាវវត្ត ជាកម្មសិទ្ធិរបស់សមណៈក្ដី ការឃាត់ខាំងនៃរាជការចំពោះសមណៈក្ដី ក៏ពុំសូវមាន ព្រោះហេតុនោះ សមណៈអាចចេញដើរទៅកាន់ទីណាមួយក៏ចេះតែទៅបានដោយស្រួល ឥតមានទើសទាក់ជាប់ចំពាក់ដូចគ្រហស្ថនោះឡើយ ។ ការមិនមានទើសទាក់ក្នុងទិសរបស់សមណៈឈ្មោះថាជាសុខរបស់សមណៈដោយហេតុមានផ្លូវទូលាយក្នុងការសិក្សាក្ដីក្នុងការទៅកាន់ទីណាមួយក្ដី មិនជាប់នៅក្នុងទីមួយៗ ដូចគ្រហស្ថឡើយ ។

គិហិសមណសុខកថា ចប់

# គោលបញ្ញប់នៃព្រះពុទ្ធសាសនា

## ចាកធម្មបទ - ខុទ្ទកនិកាយ

លោក ហោង-សមអាន រៀបរៀង

---

ពលនិករទូទៅ មានច្រើនជាតិ ច្រើនសាសន៍ ច្រើនប្រទេស ដែលអាស្រ័យនៅលើពិភពលោក សុទ្ធតែមានជំនឿក្នុងអ្វីមួយ បើមិនតិចក៏ច្រើន ដែលខ្លួនយល់ឃើញថាជាវត្ថុដ៏សក្តិសិទ្ធិគួរតែពឹងពាក់អាស្រ័យ គួរគោរពរាប់អាន ពុំសូវនៅតែឯកឯងឥតទីពឹងឡើយ ។ វត្ថុដ៏សក្តិសិទ្ធិទាំងនោះ គេច្រើននិយមយកសាសនា ឬ លទ្ធិដែលជាបវេណី របស់បុព្វបុរសសម្រាប់ជាតិនីមួយៗតែងប្រព្រឹត្តកាន់ជាប់តៗ គ្នាមក ទើបឈ្មោះថា សាសនា ។ សាសនានេះមានផ្សេងៗគ្នា តាមមតិរបស់សាស្តាចារ្យនីមួយ ៗ បង្កើតឲ្យមានឡើង ដើម្បីញ៉ាំងបរិស័ទឲ្យចូលជឿស្តាប់គោរពរាប់អាន ដូចយើងបានឃើញ បានឮមកហើយដែលមានក្នុងលោកនេះ ។ បណ្តាសាសនាទាំងអស់ក្នុងលោក មានតែព្រះពុទ្ធសាសនមួយទេ ដែលជាសាសនាមានសារៈសំខាន់បណ្តាប់ជាងសា-សនាឯទៀតៗ ទាំងអស់ ព្រោះជាសាសនាដែលអាចធ្វើមនុស្សគ្រប់ឋានៈជាអ្នកប្រតិបត្តិតាម ឲ្យមានសន្តិភាព សេរីភាព មេត្រីភាព សាមគ្គីភាព

ឯកកដ្ឋ ទីងឥស្សរភាពខ្លួនទៅក្នុងត្រៃលោកបាន ។ ព្រះមហាបុរសមួយរូប អ្នកមានវិចារណញ្ញាណដ៏ជ្រាលជ្រៅ បានរាវរកឃើញសេចក្ដីប្រតិបត្តិដែលមានខ្លឹមសារវិសេស អាចធ្វើមនុស្សគ្រប់ឋានៈ ឲ្យបានរួចចាកភ្លើងកិលេស ហើយបានប្រកាសផ្សាយទុកជាប់មកដល់សព្វថ្ងៃនេះ ឯមហាបុរសនោះ គឺព្រះសម្មាសម្ពុទ្ធរបស់យើងហ្នឹងឯង ។ កាលដែលព្រះសម្ពុទ្ធទ្រង់ស្វែងរកសេចក្ដីប្រតិបត្តិ ដែលមានខ្លឹមសារវិសេសនោះ ពុំមែនទើបនឹងស្វែងរកក្នុងមួយជាតិជាទីបំផុតនេះទេ គឺស្វែងរកអស់កាលជាច្រើនជាតិណាស់ ដូចមានប្រវត្តិដែលអ្នកប្រាជ្ញទាំងឡាយ បានចារឹកក្នុងគម្ពីរជាច្រើន មានគម្ពីរបឋមសម្ពោធជាដើម ដែលមានសេចក្ដីដំណាលថា កាលព្រះបរមគ្រូនៃយើងនៅក្នុងឋានៈជាពោធិសត្វ មានព្រះនាមថា សុ-មេធបណ្ឌិត បានបំពេញបារមីធម៌ទាំងឡាយ មានទានបារមីជាដើម អំណើះអំពីនោះមក សូម្បីសោយព្រះជាតិជាអ្វី ទោះបីជាតិជាមនុស្សក្ដី ជាអមនុស្សក្ដី ជាតិរច្ឆានក្ដី សុទ្ធតែបានបំពេញបារមីធម៌គ្រប់ ។ ជាតិ ដើម្បីស្វែងរកនូវមោក្ខធម៌តែម្យ៉ាង រហូតដល់បច្ឆិមជាតិ ដែលមាននាមថា សិទ្ធត្ថ គំរប់កាលអស់ ៤ អសំខេយ្យ មួយសែនកប្ប នៅតែមិនជួបប្រទះនឹងខ្លឹមរបស់សេចក្ដីប្រតិបត្តិ គឺមោក្ខធម៌ឡើយ ។

ព្រះសិទ្ធត្ថៈគោតម ទ្រង់ប្រសូតនៅថ្ងៃសុក្រ ១៥ កើត ខែ

វិសាខ ឆ្នាំច ព្រះវររាជបិតាព្រះនាម ព្រះសុទ្ធោទនៈគោតម ព្រះវររាជមាតា ព្រះនាម ព្រះសិរីមហាមាយា ជាព្រះចៅក្រុងកបិលពស្តុ នៃដែនសក្កៈ ។

លុះព្រះជន្មាយុបាន ១៦ ព្រះវស្សា ព្រះសិទ្ធត្ថទ្រង់ទទួលរាជាភិសេកជាព្រះចៅក្រុងកបិលវត្ថុ ដោយមានព្រះនាង យសោធរាពិម្ពាទេវី ជាអគ្គមហេសី ហើយទ្រង់មានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាម ព្រះរាហុលកុមារ ។ ដល់ព្រះជន្មាយុបាន ២៩ ព្រះវស្សា ក្រោយពេលដែលទ្រង់យល់នូវទេវទូតទាំង ៤ គឺៈ ជរា-ព្យាធិ-មរណៈ និង អ្នកបួស ព្រះសិទ្ធត្ថទ្រង់នឿយណាយ ក្នុងភេទជាឃរាវាស ក៏ទ្រង់យាងចេញទាំងកណ្ដាលអធ្រាត្រទៅបំពេញបព្វជ្ជា ស្វែងរកនូវសព្វញ្ញុតញ្ញាណជាមោក្ខធម៌ មិនយូរប៉ុន្មាន បានយល់ឃើញច្បាស់នូវសព្វញ្ញុតញ្ញាណនោះនៅលើរតនបល្លង្ក ក្រោមដើមពោធិព្រឹក្ស ពេលព្រះអាទិត្យរះបំព្រាង១ នៃថ្ងៃ ១៥ កើត ខែវិសាខ ឆ្នាំរកា ក្រោយធ្វើទុក្ករកិរិយា ៦ វស្សា ។ ព្រះសិទ្ធត្ថទ្រង់បានព្រះនាមហៅថា «ព្រះពុទ្ធ» តាំងពីថ្ងៃនោះរហូតមក ។

តាំងពីពេលដែលបានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណមក ព្រះពុទ្ធជាម្ចាស់ ទ្រង់ប្រកាសសាសនធម៌ដល់សត្វនិករទូទៅក្នុងលោក ។ លុះដល់ថ្ងៃ ១៥ កើត ខែមាឃ ឆ្នាំរកា ជាកំរប់ ៩ ខែគត់ គិតពីថ្ងៃដែល

ព្រះអង្គបានត្រាស់ដឹង ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រជុំព្រះអរហន្តទាំងឡាយ ធ្វើមហាសន្និបាត ក្នុងវត្តវេឡុវ័ន ប្រគល់ដំណែងអគ្គសាវកដល់ព្រះថេរៈពីរអង្គគឺ :

អគ្គសាវកទី១ បានដល់ព្រះសារីបុត្រជាឯតទគ្គ (Record) ខាងបញ្ញា

សាវកទី ២ បានដល់ព្រះមោគ្គល្លានជាឯតទគ្គ (Record) ខាងឫទ្ធិ

ហើយទ្រង់ប្រកាសគោលច្បាប់ព្រះពុទ្ធសាសនាគឺ :

សព្វបាបស្ស អករណំ កុសលស្សូបសម្បទា

សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ

ការមិនធ្វើបាបទាំងពួង ១ ការបំពេញកុសល ១

ការជុសខាត់សំអាតចិត្តរបស់ខ្លួន ១ ទាំង ៣ នេះ

ជាគោលច្បាប់ព្រះពុទ្ធសាសនានៃព្រះពុទ្ធទាំងឡាយ ។

ព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គ ដែលបរិនិព្វានទៅហើយក្តី ដែលនឹងត្រាស់ដឹងក្នុងអនាគតក្តី សុទ្ធតែទ្រទ្រង់នូវមហាករុណាទិគុណ ប្រកបដោយអត្តសម្បត្តិ (គុណជាចំណែករបស់ព្រះអង្គ) និងបរហិតសម្បត្តិ (គុណជាចំណែកដល់សត្វដទៃ) ព្រះអង្គជាគរុដ្ឋានិយៈនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់សំដែងធម៌ទូន្មានប្រៀនប្រដៅសត្វលោកដោយព្រះទ័យដ៏បរិសុទ្ធ សំដែងច្បាប់ហេតុផលនៃសេចក្តីសុខ-ទុក្ខ ដើម្បីអ្នកស្តាប់

អ្នករៀនពិចារណាឲ្យឃើញច្បាស់គឿងដោយខ្លួនឯង តាមលំអានផៃពុទ្ធ ទក់ទងដូចគ្នាគ្រប់ៗព្រះអង្គ ឥតដាក់អាជ្ញាបង្ខំបញ្ញាឲ្យជឿឡើយ ។

ព្រះពុទ្ធ ដែលទ្រង់សំដែងធម្មវិន័យប្រោសវេនេយ្យសត្វអស់រយៈកាល ៤៥ ព្រះវស្សា ក៏ចូលបរិនិព្វានទៅ ទើបព្រះសង្គីតិកាចារ្យ ប្រមូលរៀបរៀងនូវពុទ្ធវចនៈនោះ ដោយពួក ៗ ឲ្យដឹងថា នេះជាធម៌ នេះជាវិន័យ នេះជាពុទ្ធប្បញ្ញត្តិ នេះជាពុទ្ធានុញ្ញាត ទើបចាត់ទៅជាបិដកមាន ៣ គឺ វិន័យបិដក សុត្តន្តបិដក អភិធម្មបិដក ចាត់ទៅជាធម្មក្ខន្ធ មាន ៨៤០០០ ព្រះធម្មក្ខន្ធ ។ ពុទ្ធសាសនធម៌ មានចំនួនច្រើនយ៉ាងនេះក៏ដោយ គង់សង្គ្រោះចូលក្នុងគោលច្បាប់ ៣ យ៉ាង ដែលមានការមិនធ្វើបាបទាំងពួងជាដើមនេះដែរ ដូចសេចក្ដីអធិប្បាយចំពោះគោលមួយៗតទៅ ៖

១– សព្វបាបស្ស អករណំ ការមិនធ្វើបាបទាំងពួង

(គោលទី ១ នេះសង្គ្រោះចូលក្នុងវិន័យបិដក)

- គោលទី ១ នេះជាច្បាប់ប្រដៅសត្វលោកមិនឲ្យធ្វើបាប, ។

ពាក្យថា បាប នេះ បានដល់អំពើអាក្រក់គ្រប់យ៉ាង នាំឲ្យក្ដៅក្រហាយ ជាហេតុញុំាងសត្វលោកឲ្យធ្លាក់ទៅអបាយ ។

ពាក្យថា បាប នេះ ប្រែថា អំពើអាក្រក់ ការដល់នូវសេចក្ដីវិនាស ការក្រេកទុកនូវសេចក្ដីវិនាស ។

ចាប សព្ទនេះ មានបាលីសម្រាប់និយាយ ផ្លាស់ប្តូរគ្នាជាច្រើន យ៉ាងគឺ :

ចាប អំពើលាមក

ទុច្ចរិត ការប្រព្រឹត្តអាក្រក់

អកុសល អំពើមិនល្អ

អករណីយៈ អំពើដែលមិនត្រូវធ្វើ

វិសមចរិយា ការប្រព្រឹត្តវិលោក

អព្រហ្មចរិយៈ ការប្រព្រឹត្តមិនប្រសើរ ។

ពាក្យថា មិនធ្វើបាបទាំងពួង បានដល់ការព្យាយាមកំចាត់បាបទាំងអស់ ដោយកាយ វាចាចិត្ត គឺវៀរចាកអកុសលកម្មបថ ១០ ប្រការ(១)។

ឯអកុសលកម្មបថ ១០ ប្រការនេះ លោកចែកចេញជា ៣ ពួក គឺ កាយកម្មជាពួក ១ វចីកម្មជាពួក ១ មនោកម្មជាពួក ១ ។

## កាយកម្ម

កាយកម្ម : គឺអំពើដែលធ្វើអាក្រក់ដោយកាយ មាន ៣ យ៉ាង គឺ: បាណាតិបាត ១, អទិន្នាទានៈ១, កាមេសុមិច្ឆាចារ១ ។

១- បាណាតិបាតៈ កិរិយាសម្លាប់សត្វដោយកាយខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្លាប់ ។

---

ព្រះសិរីមង្គលាចារ្យ បានប្រមូលអត្ថបទពីក្នុងអដ្ឋកថា ព្រះវិន័យ ព្រះសូត្រជាច្រើនអន្លើ មករៀបរៀងក្នុងគម្ពីរមង្គលត្ថទីបនី

បណ្តាជីវិតរបស់មនុស្សនិងសត្វនីមួយ ៗ ជាទីស្រឡាញ់ពេញចិត្តជាងវត្ថុដទៃ ៗ ព្រោះការស្លាប់នេះមិនជាទីពេញចិត្តនរណាម្នាក់ឡើយ ។ ព្រោះហេតុដូច្នោះ បានជាមនុស្សសត្វទាំងអស់ក្នុងពិភពលោក ខំប្រឹងប្រែងស្វែងរកស៊ីទាំងយប់ទាំងថ្ងៃ មិនគិតដល់ការនឿយហត់ ដើម្បីញុំាងជីវិតឲ្យរស់ស្ថិតស្ថេរតទៅ ។

ជីវិតជាទីស្រឡាញ់ពេញចិត្តរបស់មនុស្សសត្វ សេចក្តីស្លាប់ជាទីសំអប់របស់មនុស្សសត្វ បើបុគ្គលណាហ៊ានទម្លាយសេចក្តីស្រឡាញ់របស់គេ គឺសម្លាប់ផ្តាច់ជីវិតគេ បុគ្គលនោះរមែងទទួលនូវទុក្ខទោសដូចគេវិញមិនខាន ។ អំពើសម្លាប់នេះអាចឲ្យទោសជាក់ស្តែងនឹងភ្នែកក្នុងជាតិនេះក៏មាន ដូចជាសម្លាប់មនុស្ស នឹងត្រូវទទួលបាបគ្រោះជាទម្ងន់ គឺត្រូវរាជការផ្តន្ទាទោស មានដាក់គុកច្រវាក់ជាដើម សូម្បីតែសម្លាប់សត្វតិរច្ឆានរាល់ ៗ ថ្ងៃយូរខែឆ្នាំ ក៏នឹងមានទោសក្នុងជាតិនេះដែរ ដូចជាគោឃាតកៈ គោឃាតកៈនេះគាត់សម្លាប់គោចិញ្ចឹមជីវិតរាល់ ៗ ថ្ងៃ ថ្ងៃណាគ្មានសាច់គោបរិភោគ ថ្ងៃនោះគាត់មិនបរិភោគអាហារទេ មានថ្ងៃមួយគ្មានសាច់គោ គាត់ទៅកាត់អណ្តាតគោទាំងរស់យកមកអាំងបរិភោគ រំពេចនោះស្រាប់តែអណ្តាតរបស់គាត់ធ្លាក់ចុះក្នុងចានបាយស្រែករោទ៍ដូចគោ មិនយូរប៉ុន្មាន ក៏ស្លាប់ទៅកើតក្នុងអវចីនរក រងទុក្ខវេទនាក្រៃអនេក ។

បាណាតិបាតកម្មរមែងនាំទុក្ខវេទនាមកឲ្យគ្រប់គ្នាដែលបានប្រព្រឹត្តសមតាមអំពើដែលបានធ្វើពីព្រេងមក ។ ឧទាហរណ៍ដូចជា ៖

## រឿងព្រាហ្មណ៍ទិសាបាមោក្ខាចារ្យ (១)

ក្នុងអតីតកាល មានព្រាហ្មណ៍ម្នាក់ជាទិសាបាមោក្ខាចារ្យ បង្រៀនវិជ្ជាការដល់សិស្សតាំងឡាយ ដែលមកពីគ្រប់ទិស នៅក្នុងក្រុងពារាណសី នៃដែនកាសី ។ លោកសាស្ត្រាចារ្យនោះបានសម្លាប់ចៀម ១ ហើយឲ្យធ្វើមតកភត្ត(២) ។ ដោយកម្មដែលគាត់សម្លាប់ចៀមនោះ លុះអន្តោលទៅចាប់កំណើតកើតនៅទីណា តែងស្លាប់ដោយដាច់ក្បាលនៅទីនោះ ប្រមាណជា ៤៩៩ ជាតិ ក្នុងគំរប់ ៥០០ ជាតិ គាត់បានមកកើតជាចៀមរបស់ព្រាហ្មណ៍ជាទិសាបាមោក្ខាចារ្យ ដូចគ្នានឹងព្រាហ្មណ៍មុននោះ ។ ឯព្រាហ្មណ៍ជាទិសាបាមោក្ខាចារ្យចង់ធ្វើមតកភត្ត គាត់ចាប់ចៀមប្រុងនឹងសម្លាប់ ។ ចៀមជាសត្វដឹងជាតិ នឹកឃើញបុព្វកម្មរបស់ខ្លួនហើយសើច ។ ហើយយំ ។ ព្រាហ្មណ៍ឃើញដូច្នោះក៏សួរថា "នែ ! សត្វចៀម ម្តេចបានជាសើចហើយយំ ?" ចៀមក៏ប្រាប់តាមសត្យថា "ខ្ញុំមានសេចក្តីត្រេកអរ ដោយគិតថាមុខជារួចចាកសេចក្តីទុក្ខមានសភាពដូច្នេះក្នុងថ្ងៃនេះ បានជាខ្ញុំសើចដែលខ្ញុំយំនោះ ដោយខ្ញុំអាណិតលោក ព្រោះយល់ថា បើលោកសម្លាប់ខ្ញុំ មុខជាលោកត្រូវដាច់ក្បាល ៥០០

---

១– មតកភត្តជាតក ទុតិយវគ្គ ឯកនិបាត ។ ២- ភត្តដែលធ្វើសងដល់មនុស្សស្លាប់ ។

ជាតិដូចខ្ញុំដែរ ។ ព្រាហ្មណ៍ថា "នែ! ចៀម ឯងកុំភិតភ័យឡើយ អញមិនសម្លាប់ឯងទេ" ។ ចៀមថា "បើទុកជាលោកមិនសម្លាប់ខ្ញុំ ខ្ញុំក៏ត្រូវស្លាប់ថ្ងៃនេះដែរ" ។ ព្រាហ្មណ៍លែងចៀមទៅ ហាមកូនចៅនឹងសិស្សានុសិស្សទាំងឡាយមិនឲ្យសម្លាប់ចៀមនោះឡើយ ។

ឯសត្វចៀម កាលបើរួចខ្លួនហើយ ក៏ទៅអើតកស៊ីស្លឹកឈើដែលដុះអាស្រ័យនូវថ្ម ១ ដុំ វេលានោះស្រាប់តែមានរន្ទះបាញ់ត្រូវខ្នងថ្ម បែកថ្មធ្លាក់មកត្រូវចៀមដាច់ក ស្លាប់ក្នុងទីនោះទៅ ។

ព្រោះហេតុនោះ ព្រះបរមសាស្តាទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ! បាណាតិបាត ដែលបុគ្គលធ្វើហើយ ជាអំពើប្រព្រឹត្តទៅដើម្បីអបាយ ក្លាយកំណើតទៅកើតក្នុងនរក រួចពីនរកមកកើតជាប្រេត រួចពីប្រេតមកកើតជាអសុរកាយ រួចពីអសុរកាយមកកើតជាតិរច្ឆាន បានទុក្ខវេទនាជាអនេ្លង លុះបាបកម្មនោះស្រាល មកកើតជាមនុស្ស ក៏ជាមនុស្សឈឺច្រើន អាយុខ្លី (១) ។

បាណាតិបាតកម្ម លោកឲ្យឈ្មោះថា បាប ជាអំពើមិនត្រូវធ្វើឡើយ ។

២- អទិន្នាទានៈ កិរិយាលួចលាក់ឆក់ដណ្តើមទ្រព្យគេដោយខ្លួនឯង ឬប្រើគេឲ្យលួច ។

បណ្តាទ្រព្យសម្បត្តិទាំងអស់ ដែលគេរកបានមក ទោះមាន

---

១- អង្គុត្តរនិកាយកាយ អដ្ឋកថានិបាត សព្វលហុសូត្រ ។

វិញ្ញាណក្តី ឥតវិញ្ញាណក្តី ល្អក្តី អាក្រក់ក្តី សុទ្ធតែជាទីពេញចិត្ត គេមិនចង់ឲ្យនរណាមកលួច ឬឆក់ដណ្តើមឡើយ ។ ព្រោះហេតុនោះអំពើលួច លោកឲ្យឈ្មោះថាបៀតបៀនគេ ធ្វើឲ្យគេលំបាកចិត្ត បើនរណាធ្វើឲ្យគេលំបាកចិត្តហើយ នរនោះនឹងទទួលទោសទុក្ខដូចគេវិញ ។

អទិន្នាទាន ដែលបុគ្គលធ្វើហើយ ជាអំពើប្រព្រឹត្តទៅ ដើម្បីអបាយ គឺនាំជនលួចទាំងឡាយឲ្យដល់នូវសេចក្តីវិនាស ក្នុងបច្ចុប្បន្នជាតិនេះប្រាកដ ។ ដូចថា អំពើលួចនេះ កុំថាឡើយដល់ទៅប្លន់ដណ្តើមយកទ្រព្យមានតម្លៃច្រើន ដោយហោចទៅ សូម្បីតែលួចទ្រព្យតិចតួចប៉ុណ្ណោះ ក៏ត្រូវតែរងបាបគ្រោះយ៉ាងពន្ធឹកពុំខាន គឺត្រូវគេចាប់ចងដាក់វាយដំ ដាក់គុកច្រវាក់ធ្លាក់ខ្លួនជាមនុស្សទោសពេញទី ។ កាលបើធ្លាប់ជាប់ទោសដូច្នោះហើយ តមកនឹងចេញមុខធ្វើការធំដុំពុំបាន ដោយជាប់ខាត ព្រោះគេស្គាល់ថា ជាមនុស្សអាក្រក់ ។ ជួនកាលទ្រព្យគេបាត់ ដោយហេតុអ្វីផ្សេងទៀតសោះ ប៉ុន្តែខ្លួនដែលធ្លាប់មានកេរ្តិ៍អាក្រក់ គ្រាន់តែនៅផ្ទះក្បែរគ្នាប៉ុណ្ណោះ ក៏គេប្រចាប់ថាខ្លួនលួចក៏សឹងមាន ។ ជនលួចជាទីមើលងាយនៃជនទាំងឡាយ ដូចជារូបឆ្កែលួច ។

បើបុគ្គលណាហ៊ានប្រព្រឹត្តអទិន្នាទាន បន្តិចបន្តួចហើយ បុគ្គលនោះនឹងហ៊ានប្រព្រឹត្តអទិន្នាទានធំក្លាហាន គឺហ៊ានប្លន់ដណ្តើមមិនលែង

តែឃាតបង់តេញបន្តក់ហើយ មិនត្រូវជ័បាបគ្រោះជាទម្ងន់ គឺត្រូវកជការចាប់មកផ្តន្ទាទោស បើកជការចាប់មិនបាន ក៏ត្រូវឃ្លាតចាកផ្ទះញាតិមិត្រ ឪពុក-ម្តាយ នៅដេកក្នុងព្រៃ មិនហ៊ានចូលស្រុកមួយអាយុៈ ។

ទោសនៃអទិន្នាទាននេះឧទាហរណ៍ដូចជា ៖

## រឿងកុហកតាបសៈ

កន្លងកាលកន្លងយូរយារណាស់ហើយ មានតាបសម្នាក់ឈ្មោះកុហកៈ អាស្រ័យនៅបណ្ណសាលាក្បែរក្រុងពារាណសីនៃដែនកាសី មានកុដុម្ពិកម្នាក់និមន្តតាន់ពល់ ១ ថ្ងៃ ១ ដល់មានភោរភ័យ កុដុម្ពិកយកមាសប្រាក់ទៅកប់ក្រោមសាលាផ្ទើនឹងតាបស ។ ឃើញមាសប្រាក់ច្រើនដូច្នេះក៏គិតថា « មាសប្រាក់របស់កុដុម្ពិកនេះ បើអញយក នឹងអាចចិញ្ចឹមជីវិតរស់ដោយស្រួលអស់ ១ អាយុៈ » គិតដូច្នោះហើយក៏លួចមាសប្រាក់នោះយកទៅកប់កន្លែងផ្សេងទៀត ហើយទៅបញ្ឆោតកុដុម្ពិកថា « អាត្មាភាពនៅទីនេះ ប្រឡូកប្រឡល់ជាមួយនឹងមនុស្សច្រើនមានសេចក្តីធុញទ្រាន់ពេក នឹងសូមលាញោមទៅព្រៃហិមពាន្តថ្ងៃនេះហើយ » កុដុម្ពិកនិយាយអង្វរថា « បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់គង់នៅទីនេះចុះ ខ្ញុំព្រះករុណានឹងសាងសាលាហើយ ធ្វើរបងព័ទ្ធជុំវិញជាថ្មីទៀត ដើម្បីចៀសវាងការប្រឡូកប្រឡល់នឹងមនុស្ស » តាបសនៅតែមិនយល់ព្រមទទួលនិមន្តរបស់កុដុម្ពិកឡើយ ការចេញចាកបណ្ណសាលាជាការចាំបាច់របស់កុហក

តាបស ។ លុះទិវាទៅបិណ្ឌបាតក៏ត្រឡប់មកវិញ ដោយមានយកស្បៀង ពីរបីសម្រាប់មកសៀតនឹងផ្ទះសក់ហើយប្រាប់កុដុម្ពិកថា " ញោម ស្បៀង នេះធ្លាក់ពីដំបូលផ្ទះញោមមកជាប់ផ្ទះសក់អាត្មា ។ ខ្ញុំមិនអធិដ្ឋាន បានជាយកមកជូនញោមវិញ " ។

គ្រានោះ ព្រះបរមពោធិសត្វបានឮសំដីតាបស ក៏ជ្រាបថា ជាសំដី បង្អន់ផាន ហើយសួរកុដុម្ពិកថា "លោកមានយកអ្វីទៅផ្ញើនឹងតាបសនោះ ដែរ? " កុដុម្ពិកឆ្លើយថា "មានមាសប្រាក់ខ្លះដែរ" ព្រះពោធិសត្វប្រាប់ ថា " បើដូច្នោះតាបសនេះលួចទៅហើយ បានជាគាត់និយាយយ៉ាងនឹង ហឹង" ។ ថាហើយក៏នាំគ្នាទៅមើលឯសាលា ឃើញថាមាសប្រាក់នោះ បាត់មែន ក៏នាំគ្នារត់ទៅតាម លុះទាន់ក៏វាយដំប្រចំដាក់ហៀបនឹងស្លាប់ ហើយយកទ្រព្យត្រឡប់មកផ្ទះវិញ ។

ជនលួចស្លាប់ទៅ ទៀងតែទៅកើតក្នុងនរក រួចពីនរកមកកើតជា ប្រេត រួចពីប្រេតមកកើតជាអសុរកាយ រួចពីអសុរកាយមកកើតជាតិ-រច្ឆាន រងទុក្ខវេទនាជាអង្វែង ។ លុះផលកម្មនោះស្រាល មកកើតជា មនុស្ស វិនាសទ្រព្យសម្បត្តិ សូម្បីតែប្រាក់ ១០០ ក៏ទុកមិនគង់ដែរ ។

អទិន្នាទានកម្ម លោកឲ្យឈ្មោះថា បាប ជាអំពើមិនត្រូវ ធ្វើឡើយ ។

៣ - កាមេសុមិច្ឆាចារ កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវសេវនកិច្ច ជាមួយកូនប្រពន្ធ ប្ដី អ្នកដទៃ ។

មនុស្សក្នុងពិភពលោករមែងហួងហែងរក្សាផ្លូវកាមជាធម្មតា បើបានស្រីណាមួយជាប្រពន្ធហើយគេស្រឡាញ់ប្ដូរជីវិត ហួងហែងរក្សា មិនឲ្យបុរសណាដទៃមកប្រព្រឹត្តល្មើសនឹងស្រីនោះឡើយ ។ បើគេចិញ្ចឹមស្រីណាជាកូនរបស់គេ ៗ ស្រឡាញ់ថែរក្សាទុកបំរុងរៀបចំទុកដាក់ឲ្យបុរសណាដែលស្រឡាញ់ពេញចិត្តមកដណ្ដឹងតាមច្បាប់ប្រវេណីគេមិនចង់ឲ្យបុរសដទៃមកប្រព្រឹត្តល្មើសក្នុងច្បាប់ប្រវេណីឡើយ ។ បើបុរសណាទៅលួចរួមរ័កនឹងកូនក្រមុំ ឬ ភរិយាគេ បុរសនោះឈ្មោះថាធ្វើឲ្យគេពិបាកចិត្ត ជាហេតុធ្វើឲ្យខូចសាមគ្គីធម៌ដរាបដល់ឈ្លោះប្រកាប់គ្នាក៏មាន ។ ទោសដែលមើលឃើញក្នុងជាតិនេះក៏មានច្រើន ។ ការប្រព្រឹត្តខុសក្នុងកាមនេះ បើចេះលាក់បិទបាំងមិនឲ្យឃើញក្នុងជាតិនេះ ក៏គង់ទទួលទោសក្នុងបរលោកមិនខាន ឧទាហរណ៍ដូចជា ៖

## រឿងនាងឥសីទាសីថេរី [1]

នៅក្នុងនគរកុសុមបាដលិបុត្ត មាននាងភិក្ខុនីពីររូប គឺព្រះនាងឥសីទាសីថេរី ១ ព្រះនាងពោធិថេរី ១ ជាជីតាក្នុងសាក្យត្រកូល ជាថេរីបរិបូណ៌ដោយសីល ជាពហុស្សុត មានកិលេសកំចាត់បង់ហើយ ។ ក្នុងពេលក្រោយ

---

១ ចាកថេរីគាថា ចត្តាឡីសនិបាត ខុទ្ទកកាយ ។

ធ្វើកត្តកិច្ច ព្រះនាងភិក្ខុនីទាំងពីរ នៅគង់ក្នុងទីស្ងាត់ ។ ព្រះនាងពោធិ ថេរីផ្តើមសួរថា “ ម្នាលនាងឥសីទាសី ! នាងប្រកបដោយរូបឆោមស្រស់ ប្រិមប្រិយនឹងរកស្រីណាប្រដូចគ្មាន តាំងវ័យក៏នៅក្មេង តើនាងមានយោបល់បែបដូចម្តេច បានជាមកបួស? ” ។ ព្រះនាងឥសីទាសីក៏ឆ្លើយថា “ ម្នាលនាងពោធិ ! ចូរនាងប្រុងតាំងស្តាប់តាមដំណើរនេះចុះ ៖

បិតាខ្ញុំជាមហាសេដ្ឋី ប្រកបដោយសីល នៅក្រុងឧជ្ជេនី នៃប្រទេសអវន្តិ ។ ខ្ញុំជាធីតាម្នាក់ជាទីពេញចិត្តបិតា ។ លុះពេលក្រោយមក បិតាបានលើកខ្ញុំឲ្យមានស្វាមី ខ្ញុំក៏ទៅបំរើស្វាមីម្តាយ-ឪពុកក្មេក ។ កាលបើឃើញសាច់ញាតិស្វាមីខ្ញុំ ឬបរិវារស្វាមីខ្ញុំមក ខ្ញុំទទួលរាក់ទាក់ជូនភោជនាហារតាមសមគួរដល់វត្ថុដែលគេត្រូវការ ។ ខ្ញុំតែងក្រោកមុនស្វាមី ហើយចូលទៅគោរពប្រតិបត្តិប្តី ខ្ញុំដូតលាងដៃប្តី តាំងដូតលាងសំអាតទ្វារធរណីជាដើម ។ ខ្ញុំដាំបាយខ្លួនឯង លាងចានខ្លួនឯង ខ្ញុំថ្នមស្វាមីដូចមាតាបិតាថ្នមកូនខ្ចី តែប្តីខ្ញុំខឹងនឹងខ្ញុំ ។ ប្តីខ្ញុំនិយាយនឹងមាតាបិតារបស់គេថា “ខ្ញុំសូមលាលោកឪពុក-ម្តាយហើយ ខ្ញុំមិនអាចនៅជាមួយនាងឥសីទាសីបានឡើយ” ។ មាតាបិតាក្មេកខ្ញុំសួរខ្ញុំថា “នៃកូនស្រីសំឡាញ់ តើនាងធ្វើអ្វីខុសនឹងប្តីនាង ចូរនាងប្រាប់កំហុសនោះ តាមពិតឲ្យមែនដឹងផង? ខ្ញុំប្រាប់ថា “លោកម្តាយឪពុក! ខ្ញុំគ្មានធ្វើអ្វីខុសទេ បើប្តីខ្ញុំស្អប់រូបខ្ញុំ តើឲ្យខ្ញុំធ្វើអ្វីត្រូវចិត្តគាត់ ។ ម្តាយ-ឪពុកក្មេកខ្ញុំ ក៏នាំខ្ញុំ

ទៅប្រគល់ឲ្យម្តាយ-ឪពុកខ្ញុំវិញ ។ ក្រោយមកម្តាយ-ឪពុកខ្ញុំឲ្យខ្ញុំមានប្តីមួងទៀត ប្តីទីពីរ ខ្ញុំនៅផ្ទះស្វាមីបានតែ ១ ខែគត់ ប្តីខ្ញុំលែងខ្ញុំចោល ដែលខ្ញុំជាស្រីបំរើប្តីដូចទាសី មានមារយាទល្អ ។

ថ្ងៃមួយ បិតាខ្ញុំនិយាយនឹងបុរសម្នាក់ឲ្យមកធ្វើជាស្វាមីខ្ញុំ បានរួមគ្នាតែកន្លះខែ ក៏តែ់ចោលខ្ញុំទៅទៀត ។ ខ្ញុំអង្គុយសញ្ជឹងតែម្នាក់ឯងថា អាត្មាអញត្រូវលាមាតាបិតាចេញទៅបួស ។ គ្រានោះ មានព្រះនាង ជិនទត្តាថេរី កំពុងត្រាច់ដើម្បីភិក្ខាហារ បានមកដល់ផ្ទះបិតាខ្ញុំ ខ្ញុំក្រោកឡើងនិមន្តឡើងលើផ្ទះ ហើយអង្គាសចង្ហាន់ ព្រះថេរីឆាន់ឆ្អែតស្កប់ស្កល់ហើយ ខ្ញុំក៏លាមាតាបិតាចេញបួស ។ លុះបានអនុញ្ញាតិពីមាតាបិតាហើយ ខ្ញុំក៏ទៅកាន់សំណាក់ព្រះសម្មាសម្ពុទ្ធ ដើម្បីសូមបព្វជ្ជា បួសបាន ៧ ថ្ងៃបានសម្រេចវិជ្ជាបី ។ ម្នាលនាងពោធិ! ចូរនាងចាំស្តាប់នូវបាបកម្មរបស់ខ្ញុំដូចតទៅនេះ ៖

ម្នាលនាងពោធិ! ក្នុងអតីតជាតិ ខ្ញុំជាបុរសកេទ ធ្វើជាងមាស ខ្ញុំជាមនុស្សស្រវឹងវ័យបានប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។ លុះស្លាប់ទៅបានកើតក្នុង សង្ឃាតនរក អស់កាលជាយូរ លុះរួចចាកនរកនោះហើយ មកកើតជាស្វា ស្វាឈ្មោលជាមេហ្វូង បានខាំផ្តាច់អង្គជាតិរបស់ខ្ញុំ ក្រោយពីថ្ងៃកើត ៧ ថ្ងៃ ។ រួចពីស្វា បានមកចាប់កំណើតជាពពែខ្វាក់ផង ខ្ចកផង ខ្ញុំត្រូវគេព្រនាក់កូនក្មេងអស់ ១២ ឆ្នាំ ហើយត្រូវ

គេគ្រៀវ មានជន្ទីវបៀតបៀន ។ រួចពីពពៃខ្លាក់-ខ្វក បានមកចាប់កំណើតជាគោខ្វាក់-ខ្វក កើតបាន ១២ ខែ មានពេមក្រហមដូចជ្រលក់ល័ខ កំត្រូវគេគ្រៀវ ហើយទាញនង្គ័លរនាស់អួសរទេះដែលផ្ទុកទំនិញធ្ងន់ ទៅទាំងខ្វាក់-ខ្វក ។ រួចពីគោខ្វាក់-ខ្វក បានមកចាប់កំណើតជាមនុស្ស មានកេទមិនប្រាកដ មិនប្រាកដប្រុស-ស្រី (ខ្ទើយ) ។ រួចពីមនុស្សខ្ទើយ បានមកចាប់កំណើតជាទារិកា ក្នុងត្រកូលនៃអ្នករទេះ ត្រូវឈ្មួញជាម្ចាស់របជាន់ អូសទាញចេញពីផ្ទះ ។ ពេលនោះ បុត្ររបស់ឈ្មួញរទេះឈ្មោះ គិរិទាសៈ យកខ្ញុំទៅទុកក្នុងផ្ទះរបស់គេ ។ ប្រពន្ធរបស់ គិរិទាសៈ ជាស្រីមានសីលផង មានគុណផង ជាស្រីប្រព្រឹត្តតាមកស្តា ខ្ញុំញុះញង់ឲ្យ គិរិទាសៈ ដេញប្រពន្ធដើមចេញពីផ្ទះ ។ លុះដល់ក្នុងជាតិជាទីបំផុតនេះ ខ្ញុំបានមកកើតក្នុងសាក្យត្រកូល ប្តីទាំងឡាយលះលែងចោលខ្ញុំ ជាស្ត្រីខះខែងបំរើប្តីដូចទាសី ។ នេះព្រោះតែកម្មអាក្រក់ដែលខ្ញុំបានធ្វើ ។

(នៅមានត)

# ព្រះអភិធម្មបិដក

# គម្ពីរព្រះយមកៈ

*លោក ប៊ុ - ប៉ុ ប្រែរៀបរៀង*

( តមក )

---

## អនុសយយមក

សត្តានុសយា កាមរាគានុសយោ បដិឃានុ-សយោ មានានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុ-សយោ ភវរាគានុសយោ អវិជ្ជានុសយោតិ ។

*លំដាប់នេះ សូមវិសជ្ជនាក្នុងអនុសយយមកតទៅ ដំណើរសេចក្តីថា ភគវា សម្តេចព្រះទ្រង់ព្រះភាគ កាលព្រះអង្គត្រាស់ទេសនានូវសង្ខារយមកចប់ចុះហើយ ក្នុងលំដាប់នោះទើបត្រាស់ទេសនានូវអនុសយយមកតទៅទៀត ។ ក្នុងអនុសយយមកនោះ ទ្រង់ត្រាស់ទេសនាដោយអនុស័យប្រាំពីរប្រការ ។*

សត្តានុសយា អនុស័យប្រាំពីរប្រការនោះគឺ ៖

១– កាមរាគានុស័យ

២– បដិឃានុស័យ

៣– មានានុស័យ

៤- ទិដ្ឋានុស័យ

៥- វិចិកិច្ឆានុស័យ

៦- ភវរាគានុស័យ

៧- អវិជ្ជានុស័យ ៗ

ព្រះពុទ្ធអង្គទ្រង់ត្រាស់សួរថា យស្ស អនុសេតិ(១) បើកាមរាគានុស័យ ដេកនៅក្នុងសន្ដាននៃបុគ្គលណា បដិឃានុស័យដេកនៅក្នុងសន្ដាននៃបុគ្គលនោះឬ? ម្យ៉ាងទៀត បើបដិឃានុស័យដេកនៅក្នុងសន្ដាននៃបុគ្គលណា កាមរាគានុស័យដេកនៅក្នុងសន្ដាននៃបុគ្គលនោះឬ? បើកាមរាគានុស័យដេកនៅក្នុងសន្ដាននៃបុគ្គលណា មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ និង អវិជ្ជានុស័យដេកនៅក្នុងសន្ដាននៃបុគ្គលនោះឬ? បើមានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ និងអវិជ្ជានុស័យដេកនៅក្នុងសន្ដាននៃបុគ្គលណា កាមរាគានុស័យដេកនៅក្នុងសន្ដាននៃបុគ្គលនោះឬ ឬមិនបានដេកនៅផងទេ?

ទ្រង់ត្រាស់វិសជ្ជនាថា បើកាមរាគានុស័យដេកនៅក្នុងសន្ដាននៃបុគ្គលណា បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ និងអវិជ្ជានុស័យ ក៏ដេកនៅក្នុងសន្ដាននៃបុគ្គលនោះ បើកាមរាគានុស័យមានក្នុងសន្ដាននៃបុគ្គលណា អនុស័យប្រាំមួយប្រការ

---

១- ប្រែតាមព្យញ្ជនៈថា ដេកតាមឬដេកនៅ ។ ប្រែតាមសេចក្ដីថា មាន, ត្រាំ ឬ កើត។

ទៀតក៏មានក្នុងសន្តាននៃបុគ្គលនោះដែរ ។

កាមរាគានុសយមូលកាង អនុស័យទាំងប្រាំមួយប្រការនោះ រមែងមានកាមរាគានុស័យជាឫសគល់ជាមូលហេតុ បើគ្មានកាម-រាគានុស័យជាទីតាំងទេ អនុស័យទាំងប្រាំមួយប្រការ មានបដិឃា-នុស័យជាដើម ក៏កើតឡើងមិនបាន ។

មានពាក្យបុច្ឆាថា កាមរាគានុស័យនោះតើដូចម្តេច ? អ្វីហៅថា កាមរាគៈ ? អ្វីហៅថា អនុស័យ ? កាមរាគានុស័យនោះតើអាស្រ័យហេតុដូចម្តេច ?

មានពាក្យវិសជ្ជនាថា កាមរាគៈនោះបាននឹងសេចក្តីត្រេកក្នុងកាម អនុស័យនោះ គឺការដេកតាមឬត្រាំនៅក្នុងខន្ធសន្តាននៃសត្វរឿយ ៗ ។ កាមរាគ គឺសេចក្តីត្រេកអរក្នុងកាម ២ ប្រការ គឺកិលេសកាម ១ វត្ថុកាម ១ ។

កិលេសឈ្មោះថាកាមនោះ ព្រោះហេតុថាកិលេសដែលសត្វគប្បីប្រាថ្នា ។ វត្ថុឈ្មោះថាកាមនោះ ព្រោះហេតុថាជារបស់ដែលសត្វគប្បីប្រាថ្នាដូចគ្នា ។

សេចក្តីត្រេកអរក្នុងកាម ២ ប្រការនោះឈ្មោះថា អនុស័យ ព្រោះហេតុថាដេកត្រាំនៅឬលិចនៅក្នុងខន្ធសន្តាន នៃសព្វសត្វដេកនៅរឿយ ៗ ដេកត្រាំនៅជានិច្ច ក្នុងខន្ធសន្តាននៃសត្វទាំងឡាយ រៀរលែងតែព្រះ

អរិយបុគ្គលដែលប្រកបដោយលោកុត្តរចិត្ត ទើបមិនអាចដេកត្រាំនៅបាន ។

បដិឃៈ បាននឹងចិត្តប្រកបដោយសេចក្ដីក្រោធ ។

មានៈ បាននឹងសេចក្ដីប្រកាន់ខ្លួន ។

ទិដ្ឋិៈ បាននឹងការដែលបុគ្គលយល់ឃើញខុស នឹងប្រកាន់ខុស ហើយប្រៀនប្រដៅឲ្យអ្នកដទៃយល់ឃើញខុសប្រកាន់ខុសតាមខ្លួន ។

វិចិកិច្ឆាៈ បាននឹងបុគ្គលមានចិត្តគិតសង្ស័យ មិនបានកំណត់ឲ្យដាច់ស្រេច ។

ភវរាគៈ បាននឹងសេចក្ដីត្រេកអរក្នុងភពបី គឺកាមភព រូបភព នឹងអរូបភព ។

អវិជ្ជា បាននឹងការមិនដឹង ។

ធម៌ទាំងប្រាំពីរនេះឈ្មោះថា អនុស័យ ព្រោះហេតុថាដេកត្រាំនៅជាប់ជានិច្ចក្នុងខន្ធសន្ដាននៃសត្វទាំងឡាយ លុះតែបានសម្រេចអរិយមគ្គ អរិយផល ទើបធម៌ទាំងប្រាំពីរនេះលែងត្រាំក្នុងសន្ដាន ។

ធម៌ទាំងប្រាំពីរនេះ គ្រាន់តែកាមរាគមួយប៉ុណ្ណោះ បើកើតមានក្នុងចិត្តអ្នកណាហើយ តែងធ្វើអ្នកនោះឲ្យក្ដៅក្រហាយអន្ទះអន្ទែង បើមិនខំបំបាត់ចេញទេ ចេះតែបណ្ដោយឲ្យកើតខ្លាំងក្លាឡើងពាល់តែអត់ទ្រាំមិនបានដល់វេលាឃើញស្ត្រីមានសេចក្ដីស្នេហាស្រឡាញ់ខ្លាំងពេក ទៅជាក្លួច

ខ្លួនគ្មានគិតអៀនខ្មាស ហ៊ាននិយាយចំអកចំអន់លេងសើចឬហ៊ានចូលទៅចាប់ដៃពាល់ខ្លួនប្រាណស្រីនោះ ដែលគេមិនដឹងខ្លួនសោះ ជួនកាលត្រូវពជខណ្ឌតឹពជការចាប់យកទៅធ្វើខណ្ឌកម្មឬពិន័យជាប្រាក់កាស ជួនកាលកើតឈ្លោះប្រកែកវាយដំគ្នា ព្រោះទៅស្រឡាញ់ប្រពន្ធគេឬប្តីគេ ។

ម្យ៉ាងទៀត អនុស័យប្រាំពីរប្រការមានកាមរាគានុស័យជាដើមនេះ បើកើតមានក្នុងចិត្តនៃបុគ្គលណាហើយ តែងញ៉ាំងបុគ្គលនោះឲ្យប្រព្រឹត្តទុច្ចរិតផ្សេងៗ ដែលខ្លួនមិនធ្លាប់ប្រព្រឹត្តពីមុនមកសោះ ទៅជានាំឲ្យហ៊ានប្រព្រឹត្ត ជាហេតុនាំឲ្យបាននូវសេចក្តីវិនាសក្នុងជាតិនេះនិងជាតិមុខ ៗ ហេតុដូច្នោះ អ្នកមានប្រាជ្ញាគួរតែខំកំចាត់បង់នូវអនុស័យទាំងប្រាំពីរប្រការមានកាមរាគានុស័យជាដើមនេះឲ្យអស់ចេញពីសន្តាន ដូចជាការលះបង់នូវសេចក្តីត្រេកអរក្នុងកាមពីរប្រការ លោកសំដៅយកភិក្ខុបព្វជិតទើបលះបង់កាមពីរនោះបាន នេះកំណត់ជាន់ខ្ពស់បំផុត បើកំណត់ជាន់ទាបវិញ បុគ្គលជាឃរាវាសក៏អាចលះបង់កាមពីរនោះបានដែរ គឺមិនឲ្យត្រេកអរក្នុងកាមគុណរបស់អ្នកដទៃ នឹងវត្ថុរបស់អ្នកដទៃ បើគ្រាន់តែនឹកត្រេកអរក្នុងចិត្តរបស់ខ្លួនប៉ុណ្ណោះ មិនបញ្ចេញអាការខាងក្រៅឲ្យឃើញច្បាស់ក៏ឥតទោស ជាការដែលអ្នកប្រាជ្ញសរសើរថាជាបុគ្គលសន្តោស។

បដិឃានុស័យ បាននឹងសេចក្តីក្រោធ កើតមានក្នុងចិត្តអ្នកណា តែងធ្វើអ្នកនោះឲ្យបានទុក្ខទោសឲ្យវិនាសច្រើនឬតិច តាមកម្លាំងក្រោធ

ខ្វាំងឬតិច ៗ អ្នកក្រោធខឹងមិនបានសេចក្តីសុខឬការចំរើនផលប្រយោជន៍អ្វី ៗ ឡើយ ៗ

មានានុស័យ បាននឹងការប្រកាន់ខ្លួនប្រាណ បើកើតមានក្នុងចិត្តអ្នកណាហើយ តែងធ្វើអ្នកនោះឲ្យបាននូវសេចក្តីវិនាសជាច្រើនប្រការ ៗ

ព្រះអដ្ឋកថាចារ្យ សំដែងដោយអនុលោមតាមព្រះពុទ្ធភាសិតនៃសម្តេចព្រះបរមទសពលមានច្រើនប្រការ ព្រោះថាមានះនោះបើកើតមានឡើង ហើយបណ្តោយឲ្យចេះតែចំរើនច្រើន ៗ ឡើង គឺនាំបណ្តាលឲ្យស្រវឹងទៅផ្សេង ៗ គឺស្រវឹងព្រោះជាតិ ១ ស្រវឹងព្រោះគោត្រ ១ ស្រវឹងព្រោះឥតរោគ ១ ស្រវឹងក្នុងជីវិត ១ ស្រវឹងក្នុងលាភ ១ ស្រវឹងសក្ការៈ ១ ស្រវឹងក្នុងការគោរព ១ ស្រវឹងក្នុងបរិវារ ១ ស្រវឹងក្នុងសម្បត្តិ ១ ស្រវឹងក្នុងការសរសើរគុណ ១ ស្រវឹងក្នុងភាពជាពហូសូត្រ ១ ស្រវឹងក្នុងបដិភាណ ១ ស្រវឹងក្នុងយស ១ ៗ បុគ្គលមានមានះច្រើនតែងនាំឲ្យកើតមានសេចក្តីស្រវឹងផ្សេង ៗ ដូចរៀបរាប់មកប៉ុណ្ណោះជាដើម ៗ

អ្នកស្រវឹងព្រោះជាតិនោះ តែងកើតអំពីកេទ តាំងបួនជាមូលហេតុ គឺកេទក្សត្រ ១ កេទព្រាហ្មណ៍ ១ កេទឈ្មួញ ១ កេទអ្នកស្រែ ១ ៗ

កេទក្សត្រតែងកើតមានះប្រកាន់ខ្លួនថា ជាតិសម្បន្នោ ហិ ១ ត្តិយោ ឈ្មោះថាក្សត្រជាអ្នកបរិបូណ៌ដោយជាតិ អាត្មាជាក្សត្រប្រកប

ដោយជាតិខ្ពង់ខ្ពស់ គ្មានអ្នកណាស្មើឡើយ អាត្មានជាក្សត្រកើតមកអំពីក្សត្រតសន្តតិវង្ស ។

ឯការស្រវឹងដោយជាតិនោះ ជាហេតុនាំឲ្យដល់នូវសេចក្តីវិបត្តិ ដូចសាក្យរាជទាំងឡាយដែលប្រកបដោយមានះនោះ ព្រះរាជកុមារព្រះនាមវិឌូឌភៈ សម្លាប់ព្រះញាតិវង្សានុវង្សឲ្យអស់ព្រះជន្មជាច្រើន ។

ការស្រវឹងព្រោះគោត្រនោះ គឺកើតមានះថា អាត្មាកើតក្នុងអាទិត្យ-វង្ស ក្សត្រផ្សេង ៗ មានវង្សគោតមជាដើមជាង ។

ចំណែកព្រាហ្មណ៍ទាំងឡាយដែលស្រវឹងក្នុងជាតិនោះ គឺមានមានះប្រកាន់ខ្លួនថា យើងជាព្រាហ្មណ៍កើតអំពីជាតិនៃព្រាហ្មណ៍មហាសាល ។

ព្រាហ្មណ៍ដែលប្រកាន់គោត្រនោះ គឺប្រកាន់ខ្លួនថា អាត្មាជាព្រាហ្មណ៍កើតអំពីកស្សបគោត្រជាដើម ។

ឈ្មោញនឹងអ្នកត្រកូលទាំងឡាយនោះ មានមានះព្រោះអាស្រ័យនូវជាតិនឹងគោត្រនៃខ្លួន ៗ ដូចគ្នា ។

មានះអាស្រ័យនូវជាតិទើបកើតមានឡើង ឈ្មោះថា ជាតិមទោ ស្រវឹងព្រោះជាតិ ។ មានះអាស្រ័យនូវគោត្រទើបកើតមានឡើង ឈ្មោះថា គោត្តមទោ ស្រវឹងព្រោះគោត្រ ។

សេចក្តីស្រវឹងក្នុងភាពគ្មានរោគនោះ គឺកើតមានះប្រកាន់ខ្លួនថា អហំ អរោគោ អាត្មានេះជាអ្នកឥតរោគ កណ្ហាបង្ហាឧមត្តិបិ

សូម្បីមាត្រាថាព្យាធិ គឺឬសកើតឡើងដល់អាត្មាក៏គ្មាន ជនទាំងឡាយដទៃក្រៅអាត្មា សុទ្ធតែជាអ្នកមានរោគច្រើន ។

សេចក្តីស្រវឹងក្នុងវ័យនោះ គឺមានមានៈថា អាត្មានៅក្មេង ជនឯទៀតច្រើនតែជាអ្នកចាស់ជរា ឯអាត្មាអញសូម្បីចាស់ជរាក៏មែនហើយ ប៉ុន្តែសក់នៅខ្មៅមិនទាន់ស្កូវមួយសរសៃទេ ធ្មេញមិនទាន់បាក់មួយ សាច់នឹងស្បែកមិនទាន់ស្វិតជ្រួញជ្រីវ ភ្នែកមិនទាន់ងងឹត ត្រចៀកមិនទាន់ថ្លង់ជាដើម ។

ការស្រវឹងថាខ្លួនគ្មានរោគ នឹងស្រវឹងក្នុងវ័យ ទាំងពីរប្រការនេះកើតមានឡើង ព្រោះតែបុគ្គលមិនបានពិចារណាឲ្យឃើញច្បាស់ដោយបញ្ញារបស់ខ្លួន ។ អ្នកមានប្រាជ្ញាគប្បីចូលចិត្តថាធម្មតាមនុស្សឬសត្វមិនដែលគ្មានរោគទេ សុទ្ធតែមានរោគនៅប្រចាំខ្លួនគ្រប់គ្នាជានិច្ច ប្លែកគ្នាតែអ្នកខ្លះមានរោគតិច អ្នកខ្លះមានរោគច្រើនប៉ុណ្ណោះ ហើយរោគនោះខុសគ្នាទៀត មិនសូវដូចគ្នាទេ ។ ប៉ុន្តែមានរោគម្យ៉ាងដូចគ្នា គ្រប់រូបមនុស្សសត្វ គឺរោគស្រេកទឹកនឹងរោគឃ្លានបាយ ដែលជារោគធំបំផុតប្រចាំជីវិត ព្រោះថាមនុស្សគ្រប់រូបយកចិត្តទុកដាក់ខំថែរក្សា មើលរោគស្រេកនឹងរោគឃ្លាននេះជានិច្ច សូម្បីបានផឹកទឹកនឹងបរិភោគបាយមួយពេលឆ្អែតហើយ ក៏នៅតែមិនសះជារោគនេះ ព្រោះថាកន្លងពេលពីនោះបន្តិចទៅ ក៏កើតរោគស្រេកឃ្លានទៀត រាល់ថ្ងៃខែរហូតទៅដល់ស្លាប់ ។

ចំណែកការស្រវឹងក្នុងវ័យនោះ ក៏កម្រនឹងពិចារណាឲ្យយល់ហើយកំចាត់ស្រវឹងចេញបានណាស់ ។ អ្នកមានប្រាជ្ញាគប្បីចូលចិត្តចុះថា បើទុកជាខ្លួនយើងនៅក្មេង ក៏ឈ្មោះថាប្រាសចាកវ័យ ព្រោះដកបួណមកគ្របសង្កត់ជានិច្ច គឺថាមានដកពល់វេលា ឯជីវិតនេះតែរឹតចូលទៅជិតសេចក្តីស្លាប់រាល់ថ្ងៃខែឆ្នាំ ។ បើរាប់ថ្ងៃខែដែលខ្លួនរស់នៅរួចមកហើយឃើញថានេះតែចំរើនច្រើន ៗ ឡើង ឯថ្ងៃខែឆ្នាំខាងមុខនេះតែថយតិច ៗ ទៅ ហេតុនោះ បានជាលោកប្រាប់ថា បុគ្គលកើតមកក្នុងលោកនេះមិនបានស្ថិតនៅឲ្យទៀងទាត់ក្នុងវ័យណាមួយទេ គឺដំបូងជាបឋមវ័យ ហើយលឿនទៅដល់មជ្ឈិមវ័យជាថ្នាក់កណ្តាល រហូតដល់ថ្នាក់បំផុតជាបច្ឆិមវ័យ ៗ

បុគ្គលអ្នកស្រវឹងក្នុងវ័យនោះ សូម្បីដឹងថាខ្លួនមានសក់ស្កូវ ធ្មេញបាក់ ភ្នែកងងឹត សាច់ស្បែកជ្រួញជ្រីវហើយ ក៏នៅតែគិតថាខ្លួននៅក្មេង មិនយល់ព្រមថាខ្លួនចាស់ជរាទេ បើគេហៅតាយាយក៏អាក់អន់ចិត្ត បើគេហៅប្អូនបងក៏សប្បាយរីករាយចិត្ត ដូច្នេះចាត់ថាអ្នកស្រវឹងក្នុងវ័យ ៗ

ឧប្បន្នោ មានោ មានះប្រកាន់ខ្លួនកើតឡើងដោយអំណាចនៃចិត្តគិតថា អហំ ចីរំ ជីវំ ជិវាមិ អញមានជីវិតរស់នៅឥឡូវនេះ ហើយនឹងមានជីវិតរស់នៅតទៅមុខទៀតបានយូរក្តី អញតែងបានសុខឥតទុក្ខព្រួយ អញមានជីវិតដ៏មាំមួនឋិតថេរ អ្នកឯទៀតមានជីវិតមិនមាំមួនទេ មានជីវិតមិនបានសុខដូចអញឡើយ មានះយ៉ាងនេះឈ្មោះថា ស្រវឹងក្នុងជីវិត ៗ

ការស្រវឹងក្នុងលាភនោះ គឺប្រកាន់ថាខ្លួនជាអ្នកមានលាភច្រើន ជាអ្នករកលាភបានងាយ ៗ ឯអ្នកដទៃសូម្បីមានលាភក៏មែនហើយ ប៉ុន្តែមិនស្មើនឹងអញទេ ។ ចំណែកបណ្ឌិតជនវិញ មិនស្រវឹងក្នុងលាភយ៉ាងនេះទេ លោកសំគាល់ថាអាត្មាអញបានលាភច្រើនដូច្នេះ មកពីហេតុដែលអញបានធ្វើកងការកុសលទុក ទើបលោកឧស្សាហ៍បរិចាគទាន ។

ការស្រវឹងក្នុងបរិវារនោះ គឺប្រកាន់ថាអាត្មាអញនេះមានបរិវារច្រើនរាប់រយរាប់ពាន់នាក់ ឥតអ្នកណាមានបរិវារច្រើនស្មើនឹងអញទេ លុះស្រវឹងយ៉ាងនេះហើយ ក៏តាំងអហង្ការមមង្ការ គឺប្រកាន់ថាមានតែអញជាអ្នកប្រសើរវិសេសជាងគេ ចំណែកអ្នកប្រាជ្ញវិញ បើទុកជាមានបរិវារច្រើនដល់ប៉ុន្មាន ក៏លោកមិនស្រវឹងដូច្នេះដែរ ។

ការស្រវឹងក្នុងសម្បត្តិនោះ គឺស្រវឹងដោយអំណាចនៃគំនិតគិតឃើញថា អាត្មាអញមានគ្រឿងឧបភោគបរិភោគជាច្រើន នឹងមានកាមគុណទាំងប្រាំ ជាទីប្រលោមលួងលោមចិត្តក៏ច្រើន ស្រស្រិង្គារនឹងវត្ថុអ្វីៗ ក៏មានគ្រប់មុខឥតខ្វះ យល់ឃើញដូច្នេះហើយមិនបានធ្វើការកុសលណាមួយទេ បែរជាតាំងខ្លួនក្នុងអហង្ការមមង្ការសំគាល់ថា អាត្មាអញជាអ្នកមានសម្បត្តិច្រើនជាងគេ ឥតអ្នកណាមានស្មើទៅវិញ ។ ចំណែកបណ្ឌិតវិញ បើទុកជាមានសម្បត្តិច្រើនដល់ប៉ុន្មាន ក៏លោកមិនស្រវឹងយ៉ាងនេះដែរ លោកតែងតែចែកទ្រព្យរបស់ខ្លួនជាបួនចំណែក គឺមួយចំណែកទុក

ចំណាយក្នុងគ្រាមានគ្រោះថ្នាក់អាសន្នអន្តរាយ ពីរចំណែកសម្រាប់ប្រកបកិច្ចការចិញ្ចឹមជីវិតមានពាណិជ្ជកម្មជាដើម និងចិញ្ចឹមគ្រួសារខ្លួន មួយចំណែកទៀតសម្រាប់ធ្វើបុណ្យ បណ្ឌិតលោកបែងចែកទ្រព្យជាបួនចំណែកយ៉ាងនេះ ។

ការស្រវឹងក្នុងសរីរៈពណ៌សណ្ឋាននោះ គឺសំគាល់ថា អភិរូបោ ចាសាទិកោ អាត្មាអញមានរូបរាងកាយពណ៌សម្បុរទ្រង់ទ្រាយល្អឆើតឆាយសមរម្យនាំឲ្យអ្នកផងមានចិត្តជ្រះថ្លាស្រឡាញ់ អ្នកដទៃសូម្បីមានរូបរាងល្អ ក៏មិនស្មើនឹងអញ គ្មានគេសរសើរដូចអញដែរ ។

ការស្រវឹងក្នុងភាពជាពហុស្សូត្រនោះ គឺស្រវឹងដោយគំនិតគិតឃើញថា អាត្មាអញជាអ្នកបានរៀនច្រើន បានស្តាប់ច្រើន គ្មានអ្នកណាចេះដឹងស្មើនឹងអញទេ ។ ការស្រវឹងនេះមានពីប្រការ គឺស្រវឹងថាខ្លួនជាអ្នកចេះដឹងច្រើនជាងគេ ១ ស្រវឹងថាមិត្រសម្លាញ់ ឬ បក្សពួករបស់ខ្លួនជាអ្នកចេះដឹងច្រើនជាងគេ ១ ។

ការស្រវឹងក្នុងបដិភាណនោះ គឺសំគាល់ថា អាត្មាអញជាអ្នកមានបញ្ញាឈ្លាសវៃ ប៉ិនប្រសប់ក្នុងការបុច្ឆានិងវិសជ្ជនាយ៉ាងស្ទាត់ គ្មានអ្នកណាឈ្លាសវៃប៉ិនប្រសប់ពោលឆ្លើយស្មើនឹងអញទេ ។

ការស្រវឹងក្នុងសិល្បសាស្ត្រវិជ្ជាការនោះ គឺសំគាល់ថាអាត្មាអញមានវិជ្ជាការប្រសើរជាងអ្នកដទៃ គ្មានអ្នកណាស្មើនឹងអញឡើយ ។

មានះដែលកើតមានឡើងដោយអំណាចនៃសេចក្តីស្រវឹងនោះ បើ

ពោលដោយប្រភេទមានច្រើនយ៉ាងណាស់ ប៉ុន្តែនាំមកសំដែងក្នុងទីនេះ ដោយសង្ខេបប៉ុណ្ណោះ ។ អ្នកមានបញ្ញាគប្បីជ្រាបចុះថា មានះនោះបាន នឹងការប្រកាន់ផ្សេង ៗ ដែលនឹងឲ្យមានទោសក្នុងជាតិនេះឬជាតិមុខ ដូ-យ៉ាងដូចសុប្បពុទ្ធសាក្យរាជ ជាព្រះបរមញាតិរបស់សម្តេចព្រះពុទ្ធអង្គ ជាព្រះបិតានៃព្រះនាងពិម្ពានឹងព្រះទេវទត្ត ជាព្រះបរមជេដ្ឋារបស់សម្តេចព្រះនាងសិរិមហាមាយា កាច់ចូលក្នុងវង្សនៃសាក្យរាជប្រកបដោយព្រះទ័យរឹងរូសមានមានះ ទើបបានចងអាឃាតព្យាបាទក្នុងសម្តេចព្រះបរម.សាស្តាដោយហេតុពីរប្រការ គឺលះបង់ចោលនូវព្រះនាងពិម្ពាទៅបព្វជ្ជា១ នឹងតាំងនៅក្នុងទីជាពៀរនៃព្រះទេវទត្ត ១ លុះចងពៀរដូច្នេះហើយ ទើបរាំងផ្លូវគោចរបិណ្ឌបាតនៃសម្តេចព្រះបរមគ្រូលោកនាថ ពាល់តែបានសោយផលនៃកម្មជាទិដ្ឋធម្មវេទនីយ៍ គឺមហាប្រឹថពីស្រូបចុះទៅកើតក្នុងមហាអវិចិនរក អាស្រ័យហេតុដែលប្រកបដោយមានានុស័យ ។

បុគ្គលដែលប្រកបដោយទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុ-ស័យ នឹងអវិជ្ជានុស័យ ក៏ជាហេតុនឹងឲ្យដល់នូវសេចក្តីវិនាសក្នុងជាតិនេះនឹងជាតិមុខដូចគ្នា ។ ហេតុនោះ បានជាសម្តេចព្រះបរមសាស្តាទ្រង់ត្រាស់ទេសនា អនុស័យប្រាំពីរប្រការបញ្ចូលក្នុងយមកបករណ៍ដោយប្រការដូច្នេះ ។

អនុសយយមកៈ ចប់ប៉ុណ្ណោះ

(នៅមានត)

មធុរសភាឞាណី

# សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

ខ្ញុំច្យុតចាកស្ថានទេវលោកនាយ ដោយកុសលមូលចាស់ទៀត ក៏បានមកកើតក្នុងត្រកូលព្រាហ្មណ៍ដ៏ស្ដុកស្ដម្ភមាំមួនពេញដ៏ក្រៃកជគ្រឹះ ហើយបានលះបង់នូវកាមគុណទាំង៥ ជាស្រឡះចូលមកបួសក្នុងព្រះពុទ្ធសាសនា ខ្ញុំមានអាយុ ៧ ឆ្នាំរាប់ពីឆ្នាំកំណើត បានសំរេចអរហត្តកំចាត់បង់នូវកិលេសទាំងអស់ ជាអង្គព្រះខីណាស្រពមួយដែរ ។

ឧបសម្បាទយិ ពុទ្ធោ គុណមញ្ញាយ ចក្ខុមា
តរុណោ បូជនេយ្យោហំ ពុទ្ធបូជាយិទំ ផលំ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានបញ្ញាចក្ខុ បានពិចារណាជ្រាបច្បាស់នូវគុណវិសេសរបស់ខ្ញុំហើយ ទ្រង់បានអនុញ្ញាតឲ្យឧបសម្បទជាភិក្ខុភាវៈក្នុងព្រះពុទ្ធសាសនា ឯខ្លួនខ្ញុំជាកុលបុត្តមានវ័យនៅក្មេងក៏ពិតមែន តែថាជាបុគ្គលគួរគេបូជា បានជាព្រះអង្គទ្រង់រាប់អាន នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

ចិត្តចក្ខុ វិសុទ្ធំ មេ សមាធិ កុសលោ អហំ
អភិញ្ញាបារមិប្បត្តោ ពុទ្ធបូជាយិទំ ផលំ ។

ចិត្តចក្ខុរបស់ខ្ញុំ ស្អាតប្រពៃហើយ ខ្ញុំជាបុគ្គលឈ្លាសក្នុងសមាធិទាំង

បានដល់នូវត្រើយនៃអភិញ្ញាទាំង ៦ផង នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជា ដោយពិត ។

បដិសម្ភិទានុប្បត្តា ឥទ្ធិបាទេសុ កោវិទោ
សទ្ធម្មបារមិប្បត្តោ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំបានដល់នូវបដិសម្ភិទាទាំង៤ មានធម្មប្បដិសម្ភិទាជាដើម ហើយ ជាបុគ្គលឈ្លាសវាងវៃក្នុងឥទ្ធិបាទទាំងឡាយបួនផង ទាំងបានដល់នូវការចេះចប់ព្រះសទ្ធម្មថែមទៀត នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

តិំសកប្បសហស្សម្ហិ សម្ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំបានបូជាហើយចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ នូវផ្កាកណ្ណិការ ខ្ញុំពុំដែលស្គាល់នូវទុគ្គតិភពដល់ម្តងឡើយ ក្នុងរវាងបីម៉ឺនកប្ប នេះជាផល ដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

ខ្ញុំបានដុតកំទេចនូវកិលេសទាំងឡាយអស់ហើយ ភពគ្រប់ទាំងអស់ ខ្ញុំក៏បានដកគាស់រំលើងចេញស្រេចហើយ បានកាត់ចំណងដែលជាគ្រឿង

បង់ក្នងកពអស់ហើយ ជាអ្នកមិនមានអាសវធម៌ឡើយ គួរទាដូចជាដំរីដ៏ប្រសើរ ដែលបានកាត់ខ្នងចងជើងហើយចូលទៅនៅក្នុងព្រៃឥតភ័យ ដូច្នោះឯង ខ្ញុំមានដំណើរទៅកាន់ព្រះនិព្វានល្អហើយ វិជ្ជាទាំងឡាយបី ក៏ខ្ញុំបានសំរេចហើយ ក្នុងសំណាក់នៃព្រះសម្ពុទ្ធ ជាច្បងក្នុងលោក សាសនារបស់ព្រះពុទ្ធជាម្ចាស់សោត ក៏ខ្ញុំបានធ្វើឲ្យសំរេចហើយដែរ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋមេ
ឆឡភិញ្ញា សច្ឆិកតា កតំពុទ្ធស្ស សាសនំ ។

ម្យ៉ាងទៀត បញ្ញដិតគុណទាំងឡាយគឺបដិសម្ភិទាបួន វិមោក្ខប្រាំបី នឹងអភិញ្ញាទាំងឡាយប្រាំមួយ ក៏ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ សាសនាដែលប្រកបដោយអង្គទាំងប្រាំបួន ក៏ខ្ញុំបានធ្វើសំរេចហើយដែរ ។

លុះទត្តរសាមណេរ បានសំដែងព្រះគាថាទាំងអស់នេះចប់ហើយ ពួកជនជាច្រើនដែលបានស្តាប់នូវព្រះគាថាទាំងនោះហើយ ក៏មានសេចក្តីសោមនស្សជ្រះថ្លា តែងចំណាយទ្រព្យសម្បត្តិតាត់ធ្វើពុទ្ធបូជាបំពេញ-កុសលកម្ម ឲ្យប្រព្រឹត្តទៅខាងមុខពុំដាច់ឡើយ ។

ព្រោះហេតុដូច្នោះបានជាព្រះអរហន្តទាំងឡាយលោកពោលជាបទព្រះគាថាដូចនេះថា

សហោតុកា បច្ចិមកា បិ សត្តា ទាបិ ច សក្កោន្តិជហា
តុមេវំ អនិច្ចមានេហិ ជនេហិ ទុក្ខំ អាភវ ទាបិ

បរិវជ្ជនិយំ ។

អធិប្បាយថា៖ សត្វទាំងឡាយដែលកើតក្នុងបច្ឆិមកត នោះបីប្រ-កបដោយត្រៃហេតុជាឧបនិស្ស័យគួរដល់ព្រះអរហត្តក្តី ក៏គង់ពុំអាចនឹងលះបង់នូវបាបកម្មបាន ដូចយ៉ាងឧត្តរសាមណេរនេះឯង ជនទាំងឡាយអ្នកមិនប្រាថ្នានូវសេចក្តីសុខទុក្ខលំបាក ត្រូវតែវៀរលែងបាបកម្មចេញឲ្យឆ្ងាយចាកសន្តាន មិនត្រូវធ្វើឲ្យកើតមានក្នុងសន្តានឡើយ ។

សម្តែងរឿងនិទានឧត្តរសាមណេរជាគំរប់បួនក្នុងវគ្គទីបី ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណេះឯង ៕

---

## ៥– កាចិរបដ្ឋិនវត្ថុ

សំដែងរឿងនិទានជនអ្នកនៅក្នុងកំពង់ឈ្មោះកាចិរៈតទៅទៀតដោយភារបាលីថា ជម្ពូទីបេ បេច្ឆិយរដ្ឋេ កាចិរបដ្ឋនំ ណាម អហោសិ ដូច្នេះជាដើម អធិប្បាយជាសេចក្តីថា មានកំពង់មួយឈ្មោះកាចិរៈក្នុងដែនឈ្មោះបេច្ឆិយៈក្នុងជម្ពូទ្វីបនេះឯង ។

មនុស្សទាំងឡាយ អ្នកនៅអាស្រ័យនាកំពង់នោះសុទ្ធតែជាមិច្ឆា-ទិដ្ឋិ អ្នកកាន់សានបូជាព្រះឥសូរ ដែលយើងធ្លាប់ហៅនាបច្ចុប្បន្នថាអ្នកតាសម្រាប់គោរពប្រតិបត្តិជាក្រប្រតី ។

ពួកមនុស្សដែលជាមិច្ឆាទិដ្ឋិទាំងអម្បាលនោះ ក៏ចាត់ចែងគូររូបគំនូរជាអ្នកតាលើផែនក្តារមួយផ្ទាំង ដំកល់ទុកក្នុងរោងអ្នកតានោះ ហើយចាប់

គួរប្រដិមាដំណាងព្រះមានព្រះភាគ ដោយអាការហាក់ដូចជាចុះក្រាបថ្វាយបង្គំរូបអ្នកតានោះឯង ។

ឯជនទាំងឡាយជាឧបាសក ឧបាសិកាទៅនាកំពង់កាប៉ាល់ជនេនោះ បានចូលទៅកាន់ពេងអ្នកតា បានគយគន់មើលរូបគំនូរផ្សេង ៗ ក្នុងទីនោះ ៗ ក៏បានឃើញរូបប្រដិមាដំណាងអង្គព្រះសម្មាសម្ពុទ្ធ ដែលពួកជនជាមិច្ឆាទិដ្ឋិបាត់ជាងឲ្យគួរបទុះបង្អាប់ដូច្នោះ ។

ទើបពួកជនជាឧបាសកឧបាសិកាទាំងនោះ កើតទោមនស្សក្តួលចិត្តដោយការនឹកដល់ព្រះគុណច្រើនអនេកប្បការ កើតទុក្ខព្រួយផ្សះខ្សឹកខ្សួលថា "នុយើងទាំងឡាយបានឃើញនូវរូបដែលមិនគួរគេប្បីឃើញ ដែលពួកគេធ្វើបង្អាប់យ៉ាងនេះសោះ" ដោយយើងយល់ច្បាស់ថា ក្នុងលោកព្រមទាំងទេវលោកមារលោក ព្រហ្មលោកព្រមទាំងសមណទីងព្រាហ្មណ៍ ក្នុងពួកសត្វព្រមទាំងមនុស្សជាសម្មតិទេពនឹងមនុស្សជាប្រក្រតី ក្នុងផ្ទៃចក្រវាឡដែលរាប់ប្រមាណមិនបាន បើវៀរលែងតែព្រះមានព្រះភាគជាម្ចាស់ចេញហើយ ពុំមានបុគ្គលណាមួយពិសេសលើសលប់ ឬត្រឹមស្មើដោយព្រះមានព្រះភាគឡើយ ។

ឯព្រះមានព្រះភាគព្រះអង្គជាបុគ្គលគួរពួកសត្វទាំងអស់ បូជាមន-ស្សការថ្វាយបង្គំដោយពិត ឯរូបគំនូរដែលពួកមិច្ឆាទិដ្ឋិឲ្យគូរនេះ មិនសំគួរដល់កិត្តិយសរបស់ព្រះសម្មាសម្ពុទ្ធឡើយ ។ លុះពួកមនុស្សជាសម្មាទិដ្ឋិ

បានរំពឹងគិតយ៉ាងនេះហើយ  ក៏អត់ទ្រាំពុំបាននាំគ្នាស្រែកទ្រហោខ្ទួញយំ បំរះនទៀលតែពល់ៗ គ្នា  ទើបលីលាត្រេចទៅកាន់ទ្វារព្រះបរមរាជវាំង ហើយស្រែកឲ្យលាន់ឮសំឡេងគឹកកងឡើងក្នុងកាលនោះឯង ។

ព្រោះនោះហេតុ បានជាព្រះគន្ថរចនាចារ្យ លោកពោលនូវបទព្រះគាថាក្នុងអបទានដូច្នេះថា:

ទ្វត្តឹសលក្ខណធរោ សុក្កាបក្ខោវ ចន្ទិមា
អនុព្យញ្ជនសម្បន្នោ សាលរាជាវ ផល្លិតោ ។

អធិប្បាយថា: ព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គទ្រទ្រង់នូវមហាបុ-រិសលក្ខណៈ ៣២ ដ៏ប្រសើរបរិបូណ៌  ដោយអនុព្យញ្ជនទាំងប៉ែតសិបគត់ដ៏ភ្លឺស្វាងរុងរឿងដូចជាព្រះចន្ទ្ររះឡើងក្នុងសុក្កបក្ខ ចំណែកខាងខ្នើតនាថ្ងៃ១៥  ពុំនោះសោត បីដូចជាដើមសាលព្រឹក្សជាឈើប្រចាំទ្វីប ដែលមានផ្ការីកស្គុសស្គាយ មានពន្លឺភ្លឺស្វាងរុងរឿងផ្សាយទៅកាន់ទិសានុទិសៗ

រំសីជាលបរិក្ខិតោ  ទិត្តោវ កនកាកលោ
ព្យាមប្បភាបរិក្ខិត្តោ សតរំសីទិវាករោ

ព្រះមានព្រះភាគជាម្ចាស់  ទ្រង់មានបណ្តាញរស្មីព័ទ្ធព័ទ្ធជុំវិញ  ដ៏ភ្លឺប្រាលរន្ទាលបីដូចជាភ្លើងឆេះព្រៃ  ទ្រង់មានឆព្វណ្ណរង្សីប្រមាណមួយព្យាយាមព័ទ្ធព័ទ្ធជុំវិញដ៏ភ្លឺស្វាងរុងរឿងបីដូចជាព្រះអាទិត្យមានរស្មីដ៏ច្រើនរះឡើងនាកណ្តាលអាកាស ។

សោណ្ណាភាសោ ជិនវរោ សមណីវ សិលុច្ចយោ
ការុណាបុណ្ណហទយោ វិវត្ថា វិយ សាគរោ
លោកាវសុតកិត្តីវ សិនេរុវុត្តមោ
យសសាវត្ថតោ ជិនោ អាកាសសទិសោ មុនី

ព្រះជិនស្រីដ៏ប្រសើរ ទ្រង់មានព្រះឆ្វីប្រិមប្រិយដូចផ្ទៃកញ្ចក់មាស និងមានព្រះកក្រ្តចរើនស្មើដូចកែវមណី ទ្រង់មានដួងហឫទ័យត្រជាក់ពោរពេញដោយសេចក្តីករុណា បីដូចជាសមុទ្រសាគរដ៏ត្រជាក់ ជាគ្រឿងបណ្តុះបណ្តាលឲ្យកើតកែវទាំងពួង ព្រះអង្គជាវីរបុរសដ៏ថ្មើមខ្ពង់ខ្ពស់បំផុត បីដូចភ្នំសិនេរុ ដ៏ខ្ពស់ជាងភ្នំនានាក្នុងលោក ព្រះអង្គទ្រទ្រង់នូវទំហំយសបរិវារដ៏ធំ ទ្រង់ជាវរមុនី មានព្រះបញ្ញាញាណដ៏ទូលំទូលាយ ដូចផ្ទៃអាកាស ។

អសង្គចិត្តោ សព្វត្ថ អនិលោវ ឥធាយកោ
បតិដ្ឋា សព្វភូតានំ មហីវ បុរិសុត្តមោ
អនុបលិត្តោ លោកេន តោយេន បទុមំយថា ។

ព្រះមានព្រះភាគ លោកនាយកទ្រង់ឥតមានមន្ទិលកិលេស ព្រះអង្គមានព្រះទ័យពុំបានជាប់ជំពាក់នៅក្នុងអារម្មណ៍ទាំងពួង បីដូចជាខ្យល់បក់ផាត់ទៅឥតមានធូលី ព្រះអង្គជាបុរសដ៏ឧត្តមជាទីពឹងនៃសត្វទាំងឡាយទាំងពួង បីដូចជាផែនដីធំជាទីប្រតិស្ឋាននៃពួកសត្វនិងសម្ភារៈទាំងឡាយ

ព្រះអង្គមានព្រះមនោគតិ ពុំបានជិតជាប់ក្នុងលោកធម៌ បីដូចជាស្លឹកឈូក ដែលពុំបានជិតជាប់ ដោយទឹកភ្លៀងដូច្នោះ ។

កុវាទកដ្ឋទាហនោ អគ្គិក្ខន្ធោវ សោភតិ
អគ្គទារិយ សត្តូ កិលេសវិនាសនោ ។

ព្រះមានព្រះភាគ ទ្រង់ដុតបំផ្លាញនូវពាក្យពោលតិះដៀលដ៏អាក្រក់របស់ជនដទៃ ដូចជាដុតឧស ទ្រង់មានព្រះសរីរាវយវៈដ៏ល្អ ដូចគំនរភ្លើង ទ្រង់ញ៉ាំងកិលេសឲ្យវិនាសសត្វ ១ កាល បីដូចជាថ្នាំឱសថ សម្រាប់រម្ងាប់រោគទាំងពួងដូច្នោះ ។

គន្ធមាទនសេលោវ គុណគន្ធវិភូសិតោ
គុណានំ អាករោ ធីរោ រតនានំ វ សាគរោ ។

ព្រះមានព្រះភាគទ្រង់ប្រដាប់ស្អិតស្អាង ដោយគ្រឿងក្រអូបគឺគុណ បីដូចជាភ្នំគន្ធមាទន៍ ព្រះអង្គជាអ្នកប្រាជ្ញទ្រទ្រង់នូវធម៌ ជាអណ្តូងទឹកសំរាប់បង្ហូរចេញនូវគុណទាំងឡាយ បីដូចជាសមុទ្រសាគរជាទីកើតនៃកែវទាំងឡាយ ។

លុះពួកមនុស្សជាសម្មាទិដ្ឋិបានពណ៌នាពុទ្ធគុណយ៉ាងនេះជាដើមហើយ ក្រាបបង្គំទូលព្រះបរមក្សត្រិយ៍ដូច្នេះថា ទេវៈ បពិត្រព្រះសម្មតិទេព ព្រះពុទ្ធរូបដែលជនមិច្ឆាទិដ្ឋិធ្វើយ៉ាងនេះពុំគួរសោះឡើយ សូមព្រះអង្គទ្រង់ជ្រាប ។

ឯព្រះបរមក្សត្រិយ៍ ស្តេចទ្រង់ព្រះសណ្តាប់ពាក្យនោះហើយក៏ត្រាស់ថា ម្នាលអ្នកដ៏ចំរើន មនុស្សទាំងអស់នេះគេតែងពោលសរសើរនូវអានុភាពនៃអ្នកតារបស់ខ្លួនទីទៃៗ ថាជាធំប្រសើរវិសេសផ្សេងៗ ចំណែកខាងអ្នកទាំងឡាយ តើអាចញ៉ាំងយើងឲ្យដឹងនូវអានុភាពនៃព្រះសាស្តា-ចារ្យរបស់អ្នកទាំងឡាយថា ជាធំប្រសើរវិសេសផ្សេង ៗ បានឬទេ? ។

ទើបឧបាសកទាំងឡាយក្រាបបង្គំទូលថា បពិត្រមហារាជ ការណ៍នេះមិនក្រអ្វីសោះឡើយ សូមព្រះអង្គចាត់សេវកាមាត្យទាំងឡាយឲ្យលើកឡើងនូវរូបអ្នកតានឹងរូបបដិមានៃព្រះមានព្រះភាគរបស់យើងឡើងកាន់បល្ល័ង្ក ហើយរុំបិទបាំងដោយសំពត់សសុទ្ធស្រេច ប្រថាប់ត្រាម្រាមព្រះហស្តលើសំពត់នោះផ្ទាល់ព្រះអង្គ ហើយបញ្ជាមនុស្សឲ្យរក្សាទុកដោយប្រពៃក្នុងពេងអ្នកតាជាមួយគ្នា លុះដល់កន្លងទៅបាន ៧ ថ្ងៃហើយសូមព្រះអង្គចាត់មនុស្សអ្នកគ្រប់គ្រងឲ្យនាំមកថ្វាយសូមព្រះអង្គទតរមិលមើលនូវរូបភាពទាំងនោះ ព្រះអង្គគង់អាចជ្រាបបាននូវអានុភាពនៃព្រះសាស្តាចារ្យជាម្ចាស់នៃខ្ញុំព្រះអង្គទាំងឡាយថា ជាធំប្រសើរវិសេសផ្សេង ៗ ក្នុងកាលនោះឯង ។

កាលនោះ ព្រះបរមក្សត្រិយ៍ ទ្រង់ចាត់សេវកាមាត្យឲ្យតាក់តែងធ្វើតាមទំនងដូចពាក្យពោលរបស់ឧបាសកទាំងឡាយនោះឯង ហើយទ្រង់ត្រាស់បង្គាប់ឲ្យដំកល់ទុកខាងក្នុងពេងនៃអ្នកតានោះដូចនេះថា អ្នកទាំង

ឡាយត្រូវបិទទ្វារទាំងអស់ ហើយបោះត្រាចាក់សោរក្សាទុកឲ្យមាំមួនកំ-ណត់ ៧ ថ្ងៃកុំប្រហែសធ្វេសឡើយ ។

ឯសេវកាមាត្យ ក៏បានធ្វើតាមព្រះរាជបញ្ជាព្រះមហាក្សត្រនោះហោង ។ លំដាប់តពីនោះមក ពួកឧបាសកទាំងអស់នោះ បានប្រជុំគ្នាចាត់ចែងឲ្យមាន រក្សាសីលប្រាំ រក្សាឧបោសថសីល ចំរើននូវមេត្តាចិត្តផ្សាយទូទៅក្នុងសត្វទាំងឡាយទាំងពួងគ្រប់ ៧ ថ្ងៃ ហើយឧទ្ទិសចំណែកបុណ្យជូនទៅ ព្រមទាំងបានធ្វើកិរិយាបូជាចំពោះព្រះរតនត្រ័យគ្រប់ទិវារាត្រី ហើយបញ្ចេញសំឡេងសូត្រតាបួងសួងឲ្យលាន់ឮគឹកកងឡើងថា: « ដោយតេជ:អានិសង្ស ជាគ្រឿងហូរមកពុំដាច់នៃកុសលរាសីដែលយើងទាំងឡាយបានធ្វើមកហើយ សូមទេវតាទាំងឡាយទាំងពួង ដែលមានរិទ្ធិអានុភាពធំក្នុងលោកនេះក្តី ស្តេចចតុលោកបាលបួនព្រះអង្គដែលរក្សាមនុស្សលោកក្តី សូមអញ្ជើញមកសម្តែងនូវសភាពសក្តិសិទ្ធិជាក់ស្តែងគួរជាទីអស្ចារ្យដល់យើងទាំងឡាយ ក្នុងកាលឥឡូវនេះឯង » ។ ដោយបុញ្ញានុភាពរបស់ឧបាសកទាំងនោះ បណ្ឌុកម្ពលសិលាសនៈរបស់សម្តេចព្រះអម្រិន្ទ្រាធិរាជជាស្តេចនៃទេវតា ក៏សម្តែងនូវអាការក្តៅក្រ-ហាយដូចជាគំនររងើកភ្លើងជាទីអស្ចារ្យក្នុងខណៈនោះឯង ។

(នៅមានត)

# មហោសថជាតក

លោក អ៊ឹម-កង ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស កឹម-តូរ ពិនិត្យ

( តមក )

---

វីបុរស-អាមាត្យនៃពោធិសត្វ បាយល់ស្តេចទាំងឡាយរត់ទៅដូច្នោះ ហើយ ក៏រឹងធ្វើបញ្ចេញនូវស័ព្ទនោះច្រើនថា ឥឡូវនេះ ស្តេចចុលនីនីស្តេចមួយយោនិងមួយរត់ទៅវិញហើយ ៗ ម្នោះហើយស្តេចទាំងឡាយ ពួសព្ទមហាជនផងទាំងឡាយភិតភ្ញាចភ័យ នានឹងស្លាប់នោះច្រើនមួយសា ក៏រត់ទៅទំលាយសេនាយោធាទាំងឡាយ រត់ទៅដោយទិសនាយទិសអាយ ប្រញាយទីទៃៗ ឥតបីមានឈប់ឈរឡើយ ៗ សូម្បីតែបុរសអាមាត្យនៃពោធិសត្វឯង បាក៏ស្រែកហៅធ្វើនូវស័ព្ទបន្ទំជាកោលាហលវវល់ច្រើនហោង ៗ ពោធិសត្វអ្នកលបក្រឡាប់ចូលទៅក្នុងព្រះនគរ នឹងអស់សេនាយោធាទាំងឡាយជាបរិវារច្រើន ៗ រីសេនាយោធាស្តេចចុលនីព្រហ្មទត្តពជ ភិតភ័យខ្លាចនឹងស្លាប់ ក៏រត់ទៅចម្ងាយមាត្រាបីយោជន៍ ៗ ឯអាចារ្យកេវដ្តព្រាហ្មណ៍ឯង ក៏ឡើងជិះសេះបរ ហើយ ដូតឈាមថ្លាសអំភ្ជាងទៅដល់សេនាយោធាទាំងឡាយនោះហើយ ជិះនៅលើខ្នងសេះនោះចូលទៅក្នុងនគរ ហើយថា ភោ ភ្លា ម្នាលគ្នាយើងអើយ ! កុំបីរត់ចូលទៅក្នុងនគរឡើយ ចូរអ្នកទាំងឡាយឈប់ៗ អញ

នេះពុំសំពះចៅមហោសថបុត្រគហបតីឡើយ ។ វីសេនាយោធាទាំងនោះ គេមិនជឿ មិនឈប់ឡើយ គេសឹងតែរត់ទៅហោង អស់ពលសកលយោធាទាំងឡាយ ក៏ស្រែកដេររម៉ើកអាចារ្យកេវដ្តព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍កំណាចបាបអប្រិយអើយ ! ព្រះស្តេចមកធ្វើនូវអំពើហៅធម្មយុទ្ធនេះ សុភាពអាស្រូវអ្វីមាល្យាយម៉្លេះ គេថា ព្រះស្តេចឯងពុំទាន់បានស្រដីដល់ ១ មាត់ទឹងគេ ស្រាប់តែនុនចុះសំពះគេមុន អំពីចំណែកចំណោះនាអ្នកគប្បីធ្វើឲ្យតាប់នូវស្តេចនោះគ្មានឡើយ លំដាប់នោះ អាចារ្យកេវដ្តព្រាហ្មណ៍ ធ្វើដូចជាមិនឮនូវពាក្យសេនាយោធាទាំងឡាយនោះ គេដើររម្ងង់ទៅហោង ។ អាចារ្យកេវដ្តព្រាហ្មណ៍ ទៅដោយនូវផ្លូវនោះ ដល់ទៅសេនាយោធាទាំងឡាយហើយថា ភោន្តោ ម្នាលអ្នកទាំងឡាយអើយ ! អ្នកចូរជឿអញ អញនេះ មិនសំពះបាមហោសថឡើយ មហោសថនេះ ក៏បំពាក់អញនឹងកែវមណីរតនំ ទេ សព្វេបិ ភោ ភជាតោ ធាធាការេហិ ពោធេត្វា អត្តនោ តាជំ តាហាបេត្វា . . . វីអាចារ្យកេវដ្តព្រាហ្មណ៍ស្រដីបន្ទឺអស់ស្តេចទាំងឡាយនោះ ដោយនូវប្រការផ្សេង ៗ ប្រយោជន៍នឹងឲ្យយកពាក្យអាត្មា តែសូម្បីសេនាយោធាដែលធ្លាយទៅនោះ ស្តេចឲ្យក្រឡាប់វិលមកវិញ ។

(នៅមានត)

ផ្នែកអក្សរសាស្ត្រ

# ភាសាសាស្ត្រ និង អក្សរសាស្ត្រខ្មែរ

រៀបរៀងដោយ ឌ. គាម

(តចប់)

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថួន
ឲ្យបានខ្ជាប់ខ្ជួន គង់វង់គត់មត់ ។
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ ។

ប.ព.

## ជំពូកទី៣
## ប្រវត្តិអក្សរ

១– ព្យញ្ជនៈ សម័យមុនព្រះថោង (កៅណ្ឌិន្យ) មកកាន់ប្រទេសយើង នៅក្នុងរវាងសតវត្សទី ១ ក្រោយព្រះពុទ្ធកាលប្រមាណ ៦០០ ឆ្នាំ ប្រជាជាតិគោកធ្លកនៅមិនទាន់មានអក្សរប្រើនៅឡើយទេ តែដល់សម័យឥណ្ឌៀនាំសាសនធម៌មកកាន់ប្រទេសយើង ខ្មែរយើងក៏បានចម្លងយកបែបទម្រង់អក្សររបស់ឥណ្ឌៀមកធ្វើជាអក្សរខ្មែរឡើង ។ តែបែបអក្សរឥណ្ឌៀមានច្រើនបែប ដូចនៅបែកប្រទេសឥណ្ឌៀខាងជើង ឥណ្ឌៀប្រើអក្សរមួយបែបរាងជ្រុង ៗ ដែលជាអក្សរមានរូបរាងដែលគេថាអក្សរក្អាយមកពី

ទេវិតាគិរី ឯអក្សរដែលឥណ្ឌៀនាំមកឲ្យខ្មែរសម័យនោះ មានទរង់មូលៗ ដែលគេប្រើនៅក្នុងប្រទេសឥណ្ឌៀ ប៉ែកខាងត្បូងសម័យនោះ ។ តែអក្សរបែបឥណ្ឌៀក៏ក្លាយបន្តិចម្តងៗ រហូតមកដល់អក្សរខ្មែរយើងសព្វថ្ងៃនេះ ។

សម័យមុន យើងប្រើព្យញ្ជនៈមានដល់ទៅ ៣៥ តួ ឃើញថាលើសសព្វថ្ងៃ ២ តួគឺ ឞ ឝ តែព្យញ្ជនៈ ២ តួនេះ គេយក ស្ស នេះប្រើជំនួសវិញនៅពេលចុងសតវត្សទី ១៧ (គ.ស. ១៧៤៧) ។

ក) មានវណ្ណយុត្តិ (៉) ផ្លាស់ជា ង្ហ (សិលាចារឹកលេខ ៩.១២,១៥ សៀវភៅសិលាចារឹកនគរវត្តទំព័រ២៧,៣១,៣៧) ស៊ីជាសិក្ខិវិញ្ញាណ = សឹងជាសខិវិញ្ញាណ

Nº 17 (B) . . . ជុំនំមហ្វោរពោរតាំមាន = ជុំនំបៅពៅតាងមាន ។

Nº 21 (B) . . . តុបតយោកប្រាកតាំកវាយ . . . = ត្បិតយកប្រាក់ដង្វាយ . . . ។

ខ) វិសជ្ជនីយ ផ្លាស់ទៅជាព្យញ្ជនៈ យ សិលាចារឹកលេខ ១៧

Nº 22 (B) សៀវភៅសិលាចារឹកនគរវត្ត ទំព័រ ៤៥ សរសេរជា

កាលមុះហ្មិ បរិង្វែង = កាលមួយគំ បរិង្វែង.

២- ស្រៈ ស្រៈខ្មែរយើងដែលប្រើនៅក្នុងសិលាចារឹកអធិដម្បូក

(ឃុំគោះ ស្រុកបាភ្នំ ខេត្តព្រៃវែង នៅក្នុងសតវត្សរ៍ទី ៧ នៅមានខ្វះស្រៈច្រើនដែលយើងប្រើសព្វថ្ងៃ ។ ពេលនោះស្រៈមានតែ ១៤ តួ ដូចជាស្រៈសំស្ក្រឹតគឺៈ

អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ហើយនឹងនិគ្គហិត-នឹងវិសជ្ជនីយ ។

ហេតុមកដល់សម័យដែលខ្មែរបានឡើងជាចក្រពត្តិហើយ ក៏យើងនៅតែប្រើស្រៈ ទាំង ១៤ តួនេះ ។ ស្រៈប៉ុណ្ណេះនៅមិនទាន់គ្រប់គ្រាន់ទេ ព្រោះភាសាខ្មែរយើងច្រើនជាឯកព្យាង្គនឹងទ្វេព្យាង្គ ។

ស្រៈខ្មែរដែលមិនឃើញមានប្រើនៅក្នុងសម័យសិលាចារឹកអង់ជម្ពឹកជាដើមគឺៈ អិ អី អួ អើ អឿ អៀ អែ ។

សូមកុំច្រឡំថាសម័យនោះ យើងមិនមានពាក្យដែលមានសំឡេងផ្សំជាមួយស្រៈនេះ ។ ចុះហេតុដូចម្តេចបានជាមិនមានស្រៈទាំងនោះ ព្រោះថាបុព្វបុរសយើងមិនទាន់រកថែបស្រៈទាំងនោះឃើញ ម្ល៉ោះហើយ គាត់ប្រើថែបស្រៈទាំងនោះដូចតទៅនេះ ។

ក)– ស្រៈ អិ = ស្រៈនេះកើតក្រោយគេបង្អស់ តែគេមិនដឹងជាកើតនៅក្នុងរជ្ជកាលណាទេ ។ នៅសម័យអង្គរ ស្រៈ អិ មានឃើញប្រើហើយ តែច្រើនតែប្រើនៅជាមួយពាក្យដែលមកពីសំស្ក្រឹត ដូចពាក្យ

ថា ប្ដី = ផ្ដិមអំពរ នៅក្នុងសិលាចារឹកប្រាសាទកំផុស គ.ស.៩៧២ ។

ខ)– ស្រះ អឹ, អួ, អើ, អឿ, អៀ ស្រះទាំងនេះមានខាងដើមសតវត្សទី ១៧ ( ១៧០១ ) តែស្រះទាំងនេះ ជួនកាលគេប្រើតាមរបៀបដើម ។

១) - ស្រះ អួ គេផ្សំដោយប្រើជើងអក្សរ វ ហើយមានបន្ទាត់មួយពីលើ ដូចពាក្យថា ម្វយ=មួយ តែក្រោយមកគេសរសេរថា ម្វាយ=មួយ វិញ តែដល់មកសតវត្សទី ១១ គេប្រែទៅជាសរសេរ ម្វយ ដូចដើមវិញ ។ តែដល់មកសតវត្សទី ១៨ ដែលខ្មែរមានស្រះ អួ ហើយក៏នៅតែសរសេរដូច្នេះខ្លះ ម្វៀ = មួយ ។

២) - ស្រះ អឺ ពីដើមឃើញមានសរសេរជាស្រះ អិ តែអានថា អឺ ដូចពាក្យនៅក្នុងសៀវភៅសិលាចារឹកនគរវត្ត (សិលាចារឹកលេខ១) ទំព័រ១

ជាព្រះពុទ្ធគិបិសំតេបព្រះមហាបេរ = ជាព្រះពុទ្ធគីបឹសម្តេបព្រះមហាបេរ

៣) - ស្រះ អើ នៅដើមសតវត្សទី ១៧ កាលយើងមិនទាន់មានស្រះ អើ យើងកត់សំឡេងតាមសៀមខ្លះ ។

នៅក្នុងសិលាចារឹកលេខ ១០ គ.ស. ១៦២៨ ( នៅក្នុងសៀវភៅសិលាចារឹកនគរវត្តទំព័រ ៣០ ) មានស្រះ អើ ដូច្នោះគឺ

កំម្បីតេបលេយ ខុំប្អូហជាគ្រាហាស = កុំបីតិបឡើយ ខ្ញុំបើជាគ្រហស្ថ

*នៅក្នុងសិលាចារឹកនគរវត្តទំព័រ ៣៨* ឱ្យវគ្នះបញ្ឈេហ អត្ទិស្សត្តិ កំម្បីឲ្យត្រ្យហ ឈេហផោងទាំងហ្វាយនោះលេយ = ឲ្យវគ្នះបាញ់ឈើ អាប់ទិសក្តិ កុំបីឲ្យត្រូវឈើផងទាំងវ្យាយនោះ ឡើយ

*៤)- ស្រៈ* អឿ *នៅក្នុងសិលាចារឹកលេខ ៨ គ.ស. ១៦២៨ គេឃើញមានប្រើពាក្យ* មឿង *នៅក្នុងសៀវភៅសិលាចារឹកទំព័រ ២២ សរសេរថា*

អ្នកស៊ើ្ត ( ១៩ ) បយសឯង អំត្ថឆ្នាំមខាល ប្វោម្អឿង ជាប្រាំពិល = អ្នកស្តេចបយសឯង អំពីឆ្នាំខាល បៅមឿងជាប្រាំពីរ

*៥)- ស្រៈ* អៀ *នៅក្នុងសៀវភៅសិលាចារឹក លេខ ២ ក្នុងសៀវភៅសិលាចារឹកនគរវត្តទំព័រ ២ សរសេរថា* តំណាបិត្រប្រឭទ្ធិសាងសត្វកុសលវ្យេងមោក = តម្លាបិត្តប្រព្រឹត្តកសាងសព្វកុសលរៀងមក

*នៅក្នុងសៀវភៅដដែល ទំព័រ ៤ សរសេរថា....* មានព្រះកេសកោរ ឱ្យនត្បៀងប្រាកតព្វកកណ្ដាលជំនុំ នៃបតុពិធបរសត្វ = មាន

ព្រះកេសកោរក្សណដៀងប្រាកដកណ្តាលជំនុំ នៃបតុពិធបរិ-ស័ទ ពាក្យថា = ដៀងប្រាកដ គឺ ដឹងប្រាកដ ឬ ទៀងប្រាកដ ឃើញថាសរសេរមិនដូចគ្នា មួយសរសេរជា េ-ៀង មួយទៀតជា ៀង ដូន កាលសរសេរជា េ-ឹង តែមានសំឡេងជា េ-ៀង ។

សិលាចារឹកលេខ ១៧ សៀវភៅសិលាចារឹកនគរវត្តទំព័រ ៤៣ សរ-សេរជា ព្រះពុទ្ធរូបរើងមោក = ព្រះពុទ្ធរូបរៀងមក

គ)- ចំណែកស្រៈ អុ វិញ ឃើញថាសម័យដើមគេសរសេរឲ្យ ឃើញមានរូបស្រៈ អុ ដូចនៅក្នុងសិលាចារឹកលេខ ៣៦ ក្នុងសៀវភៅ សិលាចារឹកនគរវត្តទំព័រ ៨៧ សរសេរជា . . . នេះសំម្តេចជោត្តិទេវិមហាសឃិរាជបុពិត្រមាន = នេះសម្តេចជោតិទេវាមហាសង្ឃរាជបពិត្រមាន

នៅក្នុងសាស្ត្រាស្លឹករឹត ឃើញសរសេរស្រៈ អុ ដូច្នេះ ,, នៅខាងក្រោមតួព្យញ្ជនៈ ដើម្បីកុំឲ្យច្រឡំថាតួនេះ ជាតួប្រកប ដូច្នោះហើយបាន ជាមានអ្នកខ្លះអានថា បុពិត្រ ។ នៅក្នុងសៀវភៅដដែលនេះ មាន កន្លែងខ្លះ ៗ សរសេរដូច្នេះ គឺ

១- សិលាចារឹកលេខ ៣៧ សរសេរជា . . . ប្រាជ្ញាព្រមនឹង

គ្នាលាប្រពន្ធចេញបួសៈយោកផលអនិ៍សង់ . . . = ប្រាប្ដាព្រមនឹង គ្នាលាប្រពន្ធចេញបួសយកផលអានិសង្ស

*៤- សិលាចារឹកលេខ៥ដែលសរសេរដូច្នេះ* ... ថ្លឹងយោកសំម្ពត មានតំម្លៃប្រព្យែកាតជាព្យំតាន២ហើយបាយប្រាកឲ្យជាទានឥស្ស កំម្រតែងសង្ស្ឋរោង = ថ្លឹងយកសំពត់មានតម្លៃប្រពៃ កាត់ជាពិតាន២ ហើយបាយប្រាក់ឲ្យជាទានអស់គម្លែងសង្ឃផង ។

*ឃ)- ចំណែកនិគ្គហិតវិញច្រើនប្រើជំនួស ម មានប្រើច្រើនជាងសព្វថ្ងៃ ។ សូមអានតាមតារាងខាងក្រោមនេះ*

| សម័យបុរាណ | | សម័យបច្ចុប្បន្ន | |
|---|---|---|---|
| ស្រៈ | ឧទាហរណ៍ | ស្រៈ | ឧទាហរណ៍ |
| អំ | អំបស្ស(១) | អម | អម្ចាស់ |
| ិំ | ថ្និំ (២) | ិម | ថ្និម |
| ុំ | សុំ | ុម | សុម |
| ើំ | ដើំ | ើម | ដើម |
| ោំ | ករោំ (៣) | ោម | ក្រោម |

១- សិលាចារឹកលេខ ២ ក្នុងសៀវភៅសិលាចារឹកនគរវត្តទំព័រ ២ ។ ២ សិលាចារឹកប្រាសាទកំពីស គ.ស. ៩៣២ ។ ៣- សិលាចារឹកលេខ ៣ ក្នុងសៀវភៅសិលាចារឹកទំព័រ ៦ (*សុំ សំយ័ក្ស= សុមសំណាក់*) ។

## បំពូកទី ៤

## មរតកភាសា

ដែលហៅថាមរតកភាសា គឺភាសាដែលមិនមានកំណើតកើតមក តែឯកឯង គឺមានពាក្យជាច្រើនដែលរួមផ្សំគ្នា បើគេហៅថា សមាស-ភាសា ក៏បានដែរ ។

១- សមាសភាសា គឺគេយកពាក្យមកផ្សំគ្នា ដើម្បីឲ្យបាន កើតជាពាក្យមួយមានន័យដោយឡែក ។

ក)- ពាក្យខ្មែរសុទ្ធ តែមានពាក្យច្រើន ហើយផ្សំគ្នាមកបានជា ពាក្យមានន័យផ្សេង ដូច សត្វដាល់អំបុក

សត្វដាល់អំបុក < សត្វ + ដាល់ + អំបុក ។ ពាក្យនេះមាន ន័យ ៣ យ៉ាង តែដល់គេរួមគ្នាមកបានជាសត្វមួយ ។

ខ)- ពាក្យបាលី ឬ សំស្រ្កឹតវិញក៏ដូចតែពាក្យខ្មែរខាងលើដែរ អង្គការសហប្រជាជាតិ < អង្គ + ការ + សហ + ប្រជា + ជាតិ

២- បរសមាសភាសា គឺពាក្យណាដែលផ្សំពាក្យខ្មែរ នឹងពាក្យ បរទេស ដូចយ៉ាងពាក្យថា ទូកដ ប៉ុដា ដាងទង ជាដើម ។

| ពាក្យខ្មែរ | បរទេសភាសា |
|---|---|
| ទូក | ដ ( ចម្ចង ) |

| ពាក្យខ្មែរ | បរទេសភាសា |
|---|---|
| ថ្ម | ដា ( ថ្ម ) |
| ដាន | ទន ( មាស ) |

៣– អាទិភាសា គឺពាក្យដែលគេបំប្រួញពាក្យវែង ៗ ឲ្យមកនៅខ្លីវិញ តែមានន័យនៅដដែល ៗ ដូចពាក្យថា ឥស្វាសុ ដែលគេប្រើនយកទៅសូត្រធ្វើជាមន្តអាគម

ឥ គឺ ឥតិ បិ សោ ( ពុទ្ធគុណ )

ស្វា គឺ ស្វាក្ខាតោ ( ធម្មគុណ )

សុ គឺ សុបដិបន្នោ ( សង្ឃគុណ )

ពាក្យមួយទៀត ដែលគេតែងពោលនៅមុនពេលស្តោះព្រួសថា ឱម ៗ ពាក្យពីរព្យាង្គនេះ មានន័យទូលាយណាស់ គេយកឈ្មោះព្រះ ៣ អង្គ នៅក្នុងព្រហ្មញ្ញសាសនាមកសង្ខេបនៅតែពីរព្យាង្គ ៗ ហើយឲ្យត្រឹមត្រូវគេថា អ.ម ឧ. តែគេផ្លាស់ អ + ឧ > ឱ + ម > ឱម បានន័យថា:

អ គឺ ព្រះ វិស្ណុ

ឧ គឺ ព្រះ សិវ

ម គឺ ព្រះ ព្រហ្ម

ពាក្យថា ព្រះតេជព្រះគុណ គឺជាពាក្យដែលគេនិយាយសំដៅយក:

ព្រះតេជ គឺ ព្រះឥស្សរ

ព្រះគុណ គឺ ព្រះនាយណ៍

៤- ប្រជានិរុត្តិសាស្ត្រភាសា (Populary Etymology)

ដែលគេហៅថា ប្រជានិរុត្តិសាស្ត្រភាសា គឺជាពាក្យដែលសង្គមមនុស្សនីមួយៗ ហៅសំរាប់សង្គម ឬបង្កើតពាក្យថ្មីទៀត ដើម្បីឲ្យស្រួលដល់ការត្រូវការប្រើរបស់សង្គមនោះ ។

ដូចជាពាក្យ សម្លខ្លាប

សម្លបែបនេះ ដូចជាមិនឃើញមាននៅគ្រប់ឃុំ ខែត្រទេ ខ្ញុំឃើញមាននៅតែ ឃុំបំបក់-ឫស្សីកែវស្រុកឆ្លង ខែត្រក្រចេះ ។ ខ្ញុំតែងសួរគេទៀតដែរ តែមានគេច្រើន ដែលមិនស្គាល់ឈ្មោះសម្លនេះ ។ សម្លនេះពិតជាពាក្យខ្មែរ ។ សម្លនេះមិនខុសគ្នាពីសម្លកកូរប៉ុន្មានទេ ។

មានពាក្យដទៃទៀត ដែលអាចចាត់ចូលថា ជាប្រជានិរុត្តិសាស្ត្រភាសាបាន ដូចពាក្យថា ផ្សិតខ្លាប់, ផ្សិតពងលលក . . . ។

បានជាគេហៅថា ផ្សិតខ្លាប់ ព្រោះផ្សិតនេះ ដុះនៅលើដីខ្លាប់ ឯផ្សិតពងលលកវិញ ព្រោះមានសណ្ឋានដូចជាពងលលក ។

មួយទៀត ភាសាស្នេហា ច្រើនតែប្លែកៗ ពីគ្នាព្រោះមានពាក្យ

ខ្លះគេបង្កើតឡើងសំរាប់តែគូស្នាម័គរិយា ឬសង្សាររបស់គេ ។ ពាក្យដែល គេប្រើជាញឹកញាប់ ហើយឮសូរតែគ្រប់សង្គមដូចពាក្យថា ព្រលឹង បេះដូង សរកាមទេព កែវភ្នែក ស្មើជីវិត . . . ។

តែបើយើងពិនិត្យទៅតាមអក្សរសាស្ត្រទៅវិញ មិនថាអក្សរសាស្ត្រខ្មែរ ឬបរទេសទេ គេច្រើនប្រដូចស្រីនៅក្នុងប្រលោមលោកថា កូឡាប, ណាគ្រី, បំប៉ា, បំប៉ី ... ឯប្រុសវិញគេថា កន្លង់, មេអំបៅ, ឃ្មុំ ... ។

បើយើងវិលមកស្តាប់ពួកម៉ាកខ្លះនិយាយជាកំប្លែង ឬនិយាយបំទមុខវិញ គេថា :

– ម៉េចមេគោទៅណាហើយ ! ឬថា

– ម៉េចមិនសណ្តាងរ៉ុម៉ក មកផង ! ឬក៏ថា

– ម៉េចមិនយកម្ហូបមកផង !

ពាក្យ មេគោ, រ៉ឺម៉ក, ម្ហូប សុទ្ធតែជាពាក្យគេប្រើជាមួយនឹងប្រពន្ធ ។

៥– ឥទ្ធិពលភាសា (Influence of Language)

ឥទ្ធិពលភាសានេះមានកំឡាំងណាស់ ដូច្នេះបានជាគេចំផ្សាយភាសាម្ទុះ ។ ដូចតួយ៉ាងសហរដ្ឋអាមេរិក ដែលធ្លាប់នៅក្រោមការត្រួតត្រារបស់ចក្រពត្តិអង់គ្លេស សហរដ្ឋអាមេរិក ក៏យកភាសាអង់គ្លេសជាភាសាជាតិ ។ ជនជាតិអាមេរិកាំងខាងត្បូង (Amérique du Sud ឬ Amérique latine) ដែលភាសាអេស្ប៉ាញ៉ុលផ្សាយចូលមក ប្រទេស

តាំងឡាយនោះ ក៏និយាយភាសាអេស្ប៉ាញ៉ុល លើកលែងតែជាតិប្រេ-ស៊ីល ( Brazil ) ដែលយកភាសាពកទុយហ្គេជាភាសាសំរាប់ជាតិ ព្រោះជាតិពកទុយហ្គេត្រួតប្រេស៊ីលមុន ។

ចំពោះភាសាខ្មែរយើងវិញ ដែលមិនមែនជាភាសាបាលីឬសំស្ក្រឹតនោះ យើងក៏យកពាក្យច្រើនដែលក្លាយមកពីបាលីឬសំស្ក្រឹត ។ មិនថាសាសន៍ណា ឬ ជាតិណាទេ គេតែងតែខ្ចីយកពាក្យបរទេសប្រើបានខ្លះ បើសាសន៍នោះជាតិនោះត្រូវការចាំបាច់ទៅហើយ ។

ឥទ្ធិពលភាសា ដែលចូលមកជ្រៀតជ្រែកភាសាខ្មែរច្រើនតែបាលីសំស្ក្រឹត-ចិន-យួន-សៀម បារាំង

១- ភាសាខ្មែរខ្ចីពាក្យពីបាលីនិងសំស្ក្រឹតជាច្រើន ដូចជា ព្រឹក្សា, មនុស្ស, គេហស្ថាន . . ។

២- ភាសាខ្មែរខ្ចីពីចិន គឺច្រើនតែមុខម្ហូបស៊ី គេច្រើនតែជួបប្រទះនឹងពាក្យចិន ដូចយ៉ាង គុយទាវ, សាមចូក . . . ។

៣- ភាសាខ្មែរខ្ចីពីយួន ភាសាយួនផ្សាយឥទ្ធិពលមកស្រុកខ្មែរច្រើនណាស់ដែរ ហើយច្រើនតែខាងម្ហូបដែរ ។ ពាក្យយួនខ្លះ ផ្សិ ជើងហែម-ជើងបង . . . ។

៤- ភាសាខ្មែរខ្ចីពីសៀម ភាសាខ្មែរយើងបានជាខ្ចី ឬមានលំនាំ

ដូចសៀមដោយហេតុ ៣ យ៉ាងគឺ

ក)- ព្រោះសៀមខ្ចីពាក្យខ្មែរទៅប្រើច្រើនក្រៃពេក

ខ)- ព្រោះសៀមក៏ខ្ចីពាក្យសំស្ក្រឹតនិងបាលី

គ)- ព្រោះនៅចុងសតវត្សទី ១៦ សៀមវាយលុកបន្ទាយលង្វែក សៀមយកពាក្យសៀមមកសង់ខ្មែរ ។

ភាសាខ្មែរសៀមដូចគ្នាតែខាងនិយណ្ឌសាស្ត្រ និងរូបសាស្ត្រហើយ ប្លែកគ្នាខាងស្នូរសាស្ត្រ ។

ខ្មែរយើងនៅមានពាក្យសង្គមមនុស្សខ្លះទៀត ដែលច្រើនតែចូលសៀម នៅក្នុងមន្តគាគម ឬនៅក្នុងចំរៀងខ្លះ ត្រង់នេះខ្ញុំសូមលើកយកឧទាហរណ៍ ចំរៀងមួយដែលខ្មែរនៅ យ៉ាំរលួស ខេត្តសៀមរាប គេច្រើនតែច្រៀងនៅក្នុងពេលឡើងអ្នកតា "បាឡាំង" ដើម្បីសុំទឹកភ្លៀង

គេច្រៀងថាៈ នាងម៉ែវៗអើយ ខបិតខកែ ខម៉ែដាយ រ៉ាំងហៃខម៉ា សែៗឡុងម៉ា លោកតាភ្លៀងមក់ ។

នេះមកពីឥទ្ធិពលភាសាសៀម ធ្លាប់នៅត្រួតខេត្តសៀមរាបនេះស្រាប់ តែទុកជាខេត្តខ្លះដែលសៀមមិនត្រួត ក៏ខ្មែរយើងនិយមប្រើពាក្យសៀមខ្លះដែរ ដូចពាក្យថា ដាំងទង . . .

## ៦- ភាសាខ្មែរខ្ចីមកពីអឺរ៉ុប

ក)- ភាសាខ្មែរយកមកពីបារាំង ដោយខ្មែរយើងខ្វះភាសាខាងបច្ចេកទេសនិងវិទ្យាសាស្ត្រ ដូចជា ‘‘គីមី’’

ខ)- ខ្មែរយើងក៏បានខ្ចីភាសាអង់គ្លេសខ្លះដែរ ដូចពាក្យថា ‘‘រ៉ក់អានរ៉ុល, ធ្វិស, (Rock n'Roll, Twist) ជាដើម ។

ខ្មែរនៅមានខ្ចីបរភាសាមកប្រើប្រើនទៀត ។



សិលាចារឹកនៅប្រាសាទវិមានអាកាស (សុជាតិលក)



Nouvelle inscription du Biméanakas

# សិលាចារឹកនៅប្រាសាទវិមានអាកាស (សុជាតិលក[១])

សិលាចារឹកនៅប្រទេសខ្មែរយើងមានច្រើនណាស់ ជាភាសាសំស្រ្កឹតក៏មាន ជាភាសាខ្មែរក៏មាន ។ យើងបានដឹងថា ភាសាខ្មែរជាអម្បូរភាសាមួយដោយឡែកហៅថា មន-ខ្មែរ ជាភាសាមួយក្នុងក្រុមភាសានៅអាស៊ីភាគអគ្នេយ៍ ដែលគេហៅថា « អូស្ត្រូអាស៊ីយាទិក » (Austro - asiatique) ។ អ្នកផងយល់ថា ភាសាខ្មែរ ជាភាសាអម្បូរ ភាសាហិណ្ឌូ - អារ្យ័ន តាមការណ៍ពិត ពុំមែនទេ តែមានបុព្វហេតុខ្លះដែលនាំឲ្យគេគិតច្រឡំ គឺមកពីបុព្វបុរសយើង បានខ្ចីយកពាក្យសព្ទសំស្រ្កឹតឬបាលីភាគច្រើនមកប្រើក្នុងភាសាយើង ដូចពាក្យសព្ទខ្មែរថា ភ្នែក ប្រមុះ មាត់ ក្បាល សក់ ត្រចៀក លោកខ្ចីយកពាក្យសព្ទសំស្រ្កឹត ឬបាលីមកប្រើជំនួសសម្រាប់រាជសព្ទនឹងបព្វជិតសព្ទដូចជានេត្រា នាសា ព្រះឱស្ឋ ព្រះកេស ព្រះកាណ៌ជាដើម មកបន្ថែមទៀត ។ ត្រង់នេះហើយដែលអ្នកខ្លះយល់ថា ភាសាខ្មែរជាអម្បូរភាសាហិណ្ឌូ.អារ្យ័ន ។ ក្នុងភាសាខ្មែរយើងមានពាក្យដែលអាចយកមកប្រើបានតាមត្រូវការ ស្ទើរតែមិនបាច់ខ្ចីពាក្យគេមកបន្ថែមក៏សឹងតែបាន តែការខ្ចីគ្នានេះ ជាការធម្មតាភាសាឬអ្វីនៅក្នុងលោកនេះទេ ព្រោះការទាក់ទងទៅវិញទៅមកតែងតែមាន ទីងនៅពេលតែម្នាក់ឯងពុំបានប្រសើរឡើយ ។ ក្នុងសិលាចារឹកជាភាសាខ្មែរ យើងសង្កេតឃើញថា បុព្វបុរសយើង បានប្រើ

(១)1- BFEO. T. XVIII 1918 P. 9 N. suivantes

ភាសាយើងជាផ្លូវការបានការគ្រប់សព្វ ទោះជាការនិយាយក្តី ទោះជាការសេសេរក្តី ឬទោះជាការចារឹកក្តី ប្រើបានគ្រប់តាំងពីបុរាណកាល ។ ភាសាយើងមានប្រវត្តិសាស្ត្រមកយូរអង្វែងស្ទើរតែជិត ២០០០ ឆ្នាំហើយ មិនអន់ថយជាងភាសាបរទេសទេ ។

ក្នុងពេលមួយដែលខ្ញុំអានសៀវភៅ ខ្ញុំបានប្រទះឃើញសិលាចារឹកនៅវិមានអាកាសនេះ ជាសំស្ក្រឹតផង ជាភាសាខ្មែរផង ។ សិលាចារឹកនេះ និយាយពីការដាំដើមពោធិមួយដើម មិនមានកាលបរិច្ឆេទទេ នឹងមិនមែនជាបុរាណពេកផង ហើយអក្សរសិលាចារឹកនេះប្រាប់ថា ជារបស់សម័យកណ្តាល គឺសម័យមហានគរ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ គឺក្នុងគ្រិស្តសតវត្សទី ១៣ ។ ខ្ញុំអានហើយជាប់ចិត្ត ដោយឃើញមានប្រ.យោជន៍ច្រើនប្រការដូចតទៅនេះគឺ:

១– សេចក្តីប្រែជាខ្មែរ ជាសេចក្តីប្រែត្រង់តាមសំស្ក្រឹត ដូចជាយើងនិយាយថា «ប្រែផ្តិត» មិនមែនដូចសិលាចារឹកដទៃ ៗ ទៀតទេ សិលាចារឹកបុរាណយើងដោយច្រើន តែងតែមានជាពីរភាសា ជាសំស្ក្រឹតផង ជាខ្មែរផង តែសេចក្តីជាខ្មែរ មិនមែនជារបៀបប្រែផ្តិតដូចសិលាចារឹកវិមានអាកាសនេះទេ គ្រាន់តែនិយាយជាសេចក្តីប្រាប់ដូចសេចក្តីភាសាសំស្ក្រឹត ។

២– យើងមានលទ្ធិសាសនារលាយចូលគ្នា គឺពុទ្ធសាសនា នឹងសាសនាព្រាហ្មណ៍ ។ រឿងលទ្ធិរលាយចូលគ្នានេះ បើយើងបានមើល

សិលាចារឹកច្រើន យើងនឹងឃើញព្រឹត្តិការណ៍នេះពិតមែន បុព្វបុរសយើងហាក់ដូចជាមិនសូវរវល់ ឬមិនមានការបារម្ភក្នុងរឿងលាយចូលគ្នានេះទេ អ្នកកាន់សាសនាព្រាហ្មណ៍ នៅរួមជាមួយអ្នកកាន់ពុទ្ធសាសនាដោយសុខក្សេមក្សាន្ត មិនសូវរង្គៀសគ្នា ។

៣- សិលាចារឹកនេះ និយាយពីការដាំដើមពោធិព្រឹក្ស ។ យើងបានដឹងថា ការគោរពពោធិព្រឹក្សនេះជាប្រពៃណីពុទ្ធសាសនា ក្នុងកាលនោះ តែគេទុកពោធិព្រឹក្សនេះទៅជា "ត្រិមូត៌" គឺព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ ដែលជាសាសនាព្រាហ្មណ៍ទៅវិញ ។

៤- ភាសាខ្មែរ មានការវិវឌ្ឍន៍ខ្ពង់ខ្ពស់ ហើយចូលទៅក្នុងអក្សរសាស្ត្រពេញលក្ខណៈពិតប្រាកដ គួរឲ្យកោតស្ងើចក្រៃលែង ។ ក្នុងភាសាខ្មែរ បុព្វបុរសយើងប្រើពាក្យសព្ទខ្មែរ នឹងពាក្យសព្ទសំស្ក្រឹតលាយចំរុះគ្នា ហើយខ្ញុំសូមយកមកលាតត្រដាងជាបួនបែបដូចខាងក្រោមនេះ ៖

| សិលាចារឹកសំស្ក្រឹត | សិលាចារឹកខ្មែរ | ប្រែផ្ដិត | ប្រែយកសេចក្ដី |
|---|---|---|---|
| ឝិវៈ | ព្រះត្ដៀស្វរ | ព្រះឥសូរ | ព្រះឥសូរ |
| សនាតនៈ | និត្យ | និត្យ | នៃបនិត្យ ជានិច្ច |
| វ្ឫក្សៈ | វ្រ្ឫក្ស | ព្រឹក្ស | ព្រឹក្សា ដើមឈើ |
| ភាគ្យៈ | ភាគ្យ | ភាគ្យ | ភាគ្យ មានបុណ្យ មានជោគ |

| សិលាចារឹកសំស្ក្រឹត | សិលាចារឹកខ្មែរ | ប្រែផ្តិត | ប្រែយកសេចក្តី |
|---|---|---|---|
| អាស្រយ: | អាស្រយ | អាស្រ័យ | អាស្រ័យ |
| ផល: | ផល | ផល | ផល-ផ្លែ |
| អនិល: | ប្រះពាយុ | ព្រះពាយុ | ព្រះពាយោ ព្រះពាយ |
| ក្រុធ: | ក្រោធ | ក្រោធ | ក្រោធ ខឹង |
| ទុស្សប្ន: | សុបអសុរ | សុបអាស្រវ | យល់សប្តអាក្រក់ |
| ទុឝ្ចិន្តិត: | ចិន្តាអសុរ | ចិន្តាអាស្រវ | ចិត្តអាក្រក់ |
| ទិវ្យ: | សួគ៌ | ស្ថានសួគ៌ | ស្ថានសួគ៌ |

ឃើញមានប្រយោជន៍ដូច្នេះហើយ ខ្ញុំបាននិយាយប្រាប់មិត្តទាំងឡាយ ៗ មិត្តទាំងនោះក៏មានមតិស្របគ្នា ទើបខ្ញុំដកស្រង់យកមកស្នើអស់លោកអក្សរសាស្ត្រទាំងឡាយទុកជាការសិក្សា តទៅដូចខាងក្រោម

## អត្ថបទជាសំស្ក្រឹត

ព្រហ្មមូលឝិវស្កន្ធ　　វិឞ្ណុឝាខសនាតន:
វ្ឫក្សរាជមហាភាគ្យ　　សំឝ្រយ ផលប្រទ
មា ត្វា ឝនិ ម៌ា បវនុ-　　ម៌ានិលោ មា ហុតាឝន:
មា រាជា មា គជ: ក្រុទ្ធោ　　វិនាឝមុបនេឝ្យតិ
អគ្និស្សន្ទំ ក្រោធស្យ-　　ទុស្សប្នទុឝ្ចិន្តិតម
អសូត្វ ឝមយេត្វំ　　យទ្ទិវ្យំ យច្ច មានុឞម

# សេចក្ដីប្រែជាខ្មែរ

បពិត្រព្រះមហាពោធិ! ព្រះអង្គមានឫសគឺព្រះព្រហ្ម មានដើមគឺព្រះឥសូរ មានមែកគឺព្រះវិស្ណុ ឋិតថេរជានិច្ច ជាស្ដេចនៃព្រឹក្សា មានបុណ្យច្រើនក្រៃ ជាទីអាស្រ័យនៃសព្វសត្វ ទ្រង់ប្រទានផល ។

សូមរន្ទះកុំបាញ់ សូមពូថៅកុំកាប់ សូមខ្យល់កុំបំបាក់ សូមភ្លើងកុំឆេះ សូមព្រះរាជាកុំបំផ្លាញ សូមដំរីកុំព្រេច (ព្រះមហាពោធិអង្គនេះ) ឡើយៗ

ឱព្រះមហាពោធិ! សូមទ្រង់រម្ងាប់កុំឲ្យមានការព្រិចភ្នែកអាក្រក់ ការញាក់ចិញ្ចើមអាក្រក់ ការយល់សប្តិអាក្រក់ ការគិតអាក្រក់ ទាំងអស់នេះដែលជារបស់ទេវតាក្ដី ដែលជារបស់មនុស្សក្ដី កុំបីឲ្យមានឡើយហោង ។

ឯសិលាចារឹកខ្មែរ ខ្ញុំចាត់ជាបីបែបគឺ ១) ពាក្យសិលាចារឹកខ្មែរសុទ្ធ ២) ប្រែជាពាក្យសម័យ ៣) ប្រែយកសេចក្ដីតាមសម័យនិយម ដូចខាងក្រោម ៖

| ពាក្យសិលាចារឹកខ្មែរ | ប្រែផ្ដិតជាពាក្យសម័យ | ប្រែយកសេចក្ដី |
|---|---|---|
| ១. ហៃវ្រះមហាពោធិ | ១. ហៃព្រះមហាពោធិ | ១. បពិត្រព្រះមហាពោធិ |
| ២. ហៃតមាទ្ទុគតិវ្រះ វ្រហ្ម | ២. ហៃដ៏មានដើមដ៏គឺ ព្រះព្រហ្ម | ២. បពិត្រព្រះអង្គដែល មានដើមជាព្រះព្រហ្ម |

| ពាក្យសិលាចារឹកខ្មែរ | ប្រែផ្ទឹតជាពាក្យសម័យ | ប្រែយកសេចក្តី |
|---|---|---|
| ៣- ហៃគមានខ្ទួន គតិព្រះព្រឹត្រ: | ៣. ហៃដ៏មានខ្ទួនដ៏គឺ ព្រះតា្រស្ទូរ | ៣. បពិត្រព្រះអង្គ ដែលមានព្រះកាយជា ព្រះឥស្សូរ |
| ៤- ហៃគមានមេក គតិព្រះវិប្ណុ | ៤- ហៃដ៏មានមែក ដ៏គឺព្រះវិស្ណុ | ៤- បពិត្រព្រះអង្គ ដែលមានមែកជាព្រះ វិស្ណុ |
| ៥- ហៃគនិត្យ | ៥- ហៃដ៏និត្យ | ៥- បពិត្រព្រះអង្គ ដែលស្ថិតនៅជានិច្ច |
| ៦- ហៃគជាកុរុងតវ្រ៊ុប្យជាង | ៦- ហៃដ៏ជាក្រុងដ៏ ព្រឹក្សផង | ៦- បពិត្រព្រះអង្គ ដែលជាស្តេចព្រឹក្សផង |
| ៧- ហៃគភាគ្យវេគ | ៧- ហៃដ៏ភាគ្យពេក | ៧- បពិត្រព្រះអង្គ ដែលមានបុណ្យ មាន ជោគជ័យពន់ពេក |
| ៨- ហៃគជាអាស្រ៊ យគដគគ | ៨- ហៃដ៏ជាអាស្រ័យ ដ៏ផ្ទៃក្រោមផង | ៨- បពិត្រព្រះអង្គ ដែលជាទីសំណាក់អា- ស្រ័យនាផ្ទៃក្រោមផង |

| ពាក្យសិលាចារឹកខ្មែរ | ប្រែផ្តិតជាពាក្យសម័យ | ប្រែយកសេចក្តី |
|---|---|---|
| ៩- ហៃតឲ្យផលច្បា | ៩- ហៃដ៏ឲ្យផលដី អាត្មា | ៩- បពិត្រព្រះអង្គដែល ប្រទានផលសម្រាប់ ចិញ្ចឹមជីវិតនៃអាត្មា |
| ១០- កំបិរទ្ធះបញ្ចកម្រ តេងអញ | ១០- កុំបីរទ្ធះបាញ់ គម្តែងអញ | ១០- កុំបីឲ្យរទ្ធះបាញ់ ខ្ញុំ (ប្រហែលពោធិ) |
| ១១- កំ បិ ត្រូ គង | ១១- កុំបីត្រូវជង | ១១- កុំបីត្រូវគេកាប់ ទឹងជឹងឡើយ |
| ១២- កំបិវ្រះវាយុ កប | ១២- កុំបីព្រះពាយ កាប់ | ១២- កុំបីឲ្យព្រះវាយោ បក់កាប់បំបាក់ |
| ១៣- កំបិវ្រះវ្លេង គុត | ១៣- កុំបីព្រះភ្លើង ដុត | ១៣- កុំបីឲ្យព្រះភ្លើង ឆាបឆេះឡើយ |
| ១៤- កំបិកម្រតេងផ្ទៃ កពេបំបត | ១៤- កុំបីគម្តែងផ្ទៃ ក្រោមបំបាក់ | ១៤- កុំបីឲ្យស្តេចផ្ទៃ ក្រោមបំផ្លាញឡើយ |
| ១៥- កំបិតម្ប្យេក្រោធ កំបិវ្រប | ១៥- កុំបីដ៏រក្រោធ កុំបីព្រេប | ១៥- កុំបីដ៏រចុះប្រេង ព្រេចបំបាក់ឡើយ |
| ១៦- នៅកម្រេកវេកយេង គអស្ទុរ | ១៦- នៅកំរេកក្លែក យើងដំអាស្រូវ | ១៦- នូវកំរេកក្លែកយើង ដំអាក្រក់ |

| ពាក្យសិលាចារឹកខ្មែរ | ប្រែផ្ទិតជាពាក្យសម័យ | ប្រែយកសេចក្ដី |
|---|---|---|
| ១៧– នៅកម្រេកបំ<br>បេតំអសរុ | ១៧– នៅកើក<br>ចំពើមដីអាស្រូវ | ១៧. នូវកម្រើកចំពើម<br>ដីអាក្រក់ |
| ១៨– នៅស្វបតអសរុ | ១៨– នៅសប្ដដី<br>អាស្រូវ | ១៨– នូវយល់សប្ដដីអា<br>ក្រក់ |
| ១៩– នៅចិន្ដាតអសរុ | ១៩–នៅចិត្តដីអាស្រូវ | ១៩– នូវចិត្តដីអាក្រក់ |
| ២០– នៅមះតអសរុ<br>ផៅង៍ តមាន តសួគ្គិ<br>តមនុម្យ លោះបុរ បំ-<br>បនះនោះ | ២០– នៅមោះដី<br>អាស្រូវផង ដីមាន<br>ដីសួគ៌ ដីមនុស្ស<br>លោះបំបាត់នោះ | ២០– នូវមោះមៃអាក្រក់<br>ផង ដែលមានៅស្ថាន<br>សួគ៌ក្ដី ស្ថានមនុស្សក្ដី<br>ទាំងអស់ ចូរបំបាត់កុំឲ្យ<br>មានឡើយ |

# អង្គរនិងសម័យអង្គរ តាមទស្សនាវដ្ដី «ញូវអូរីយ៉ង់»
# (ក្រុងប្រាក) លេខ ៣/១៩៦១

(តចប់)

សព្វថ្ងៃ ប្រាសាទទាំងពីរនេះ ជាវត្ថុបំណងដ៏ធំរបស់អ្នកទស្សនាទាំងឡាយនៅអង្គរ ។ អង្គរវត្ត (ប្រាសាទនៃទីក្រុង) មានគូទឹកមួយមានទទឹងប្រហែល ២០០ ម៉ែត្រព័ទ្ធជុំវិញ ។ កន្លែងគ្រង់សង់ប្រាសាទមានបណ្ដោយ ១៥០០ ម៉ែត្រ និងទទឹង ១៣០០ម៉ែត្រ ។ ស្ថាបត្យកម្មនៃប្រាសាទមានលក្ខណៈបែបសំណង់ជាទីលាន មានសទិសសណ្ឋានឥតខ្ចោះ សូម្បីមើលពីអាកាសយានមកក៏ដោយ . . . ។ មានកំពូលប្រាសាទសិលាសង់នៅគ្រប់ជ្រុង ចំណែកតួប្រាសាទធំមានកំពស់ ៦៥ ម៉ែត្រ ។ បើគេក្រឡេកមើលបញ្ឆៀង តាមតែពីទិសខាងណាក៏ដោយ គេតែងតែឃើញស្រមោលកំពូលបីដ៏ល្អស្ការនៃអង្គរវត្ត ។ វត្ថុទាំងនេះផ្សាយចេញនូវមហាសភាពសមសួន ពោរពេញដោយវិញ្ញូភាព ហើយការម្ចៃបែបនេះកាន់តែមានខ្លាំងឡើង បើកាលណាគេចូលទៅខាងក្នុង ។ មិនមានកន្លែងគ្រង់ណាមួយ ដែលនៅលាកស្អាតទំនេរសោះនោះទេ ជញ្ជាំងក្ដី សសរក្ដី បង្អួចក្ដី ពិតានក្ដី ខ្លោងទ្វារក្ដី សុទ្ធសឹងមានគំនូរក្បាច់រចនាប្រកបដោយការប៉ុនប្រសប់យ៉ាងសម្បើម គ្រឿងតុបតែងលំអក៏សុទ្ធសឹងយ៉ាងសំខាន់ទាំងអស់ ។

ឈុតសិល្បៈផ្នែកបូរាណសាស្ត្រ និងឈុតផ្នែកនាដការដែលប្រកប ដោយចលនាដ៏សមសួន បានញ៉ាំងផ្ទាំងសិលាឲ្យមានសភាពកាន់តែស្រស់ប្រពៃឡើង ។ ប្រាសាទមិនមែនកសាងសម្រាប់មនុស្សទេ ។ ហេតុដូច្នេះហើយ បានជាជាងចម្លាក់ខ្មែរ មិនទុកឲ្យសល់នៅមានកន្លែងលាតទំនេរ សូម្បីតែកន្លែងដែលគេមិនអាចចូលដល់ និងកន្លែងងងឹតកឹតក៏មានក្បាច់ចម្លាក់ដែរ ។ នៅកន្លែងទាំងនេះ គេឃើញមានផ្ទាំងចម្លាក់កប់ពាន់ គឺរូបមនុស្សនិងរូបទេពតា រូបស្រីទេពអប្សរល្អស្រស់រេរាំ ញញឹមប្រិមប្រិយ៍ ខ្ទង់ទេហាក់ដូចមានវិញ្ញាណជានិច្ច ។ ឯវង់ភក្ត្រប្រកបដោយសោភណភាពនៃស្រីទេពអប្សរខាងលើ គឺដូចជាវង់មុខនៃយុវនារីខ្មែរដ៏ល្អឆើតសព្វថ្ងៃនេះដែរ ។ អង្គរវត្តគេឧទ្ទិសចំពោះព្រះវិស្ណុដែលជាទេពតាមួយព្រះអង្គនៅព្រះវិហារហិណ្ឌូ ( ក្នុងប្រទេសឥណ្ឌា ) ។ ផ្ទាំងចម្លាក់ច្រើនតែថ្លែងនូវធាតុរឿងបូរាណសាស្ត្រ នៃប្រទេសឥណ្ឌាជាន់ចាស់ ។ ឯធាតុរឿងរាមាយណៈនិងមហាភារតៈក៏គេឃើញមាននៅនោះផងដែរ ។ ស្រីទេពអប្សរគឺជានាដការីនៅស្ថានព្រះឥន្ទ្រ ក្នុងប្រាសាទខ្ទះនៃអង្គរ គេក៏ឃើញមានព្រះពុទ្ធបដិមាករ ប្រកបដោយសភាពពិសេសនិងរូបព្រះពោធិសត្វ ព្រមទាំងផ្ទាំងចម្លាក់ផង ។ ការណ៍នេះមិនមែនសម្រាប់បំភាន់ជនណាទេ គឺគ្រាន់តែជាទម្រង់ក្រៅបន្តិចបន្តួច និងជាកិច្ចការខាងសាសនាប៉ុណ្ណោះ ។ ចំពោះរឿងនេះ មួយផ្នែកមកពីសិល្បករ

និយមធ្វើដោយយកលំនាំពីគេ មួយផ្នែកទៀត មកពីព្រះមហាក្សត្រទ្រង់ព្រះបញ្ញា ។ ប៉ុន្តែមិនមានការរចនាអ្វីដែលអាចឲ្យបដិសេធពោលបាននូវសភាពពិសេសខាងសិល្បៈនៃសិល្បខ្មែរ ហើយនឹងដាំឲ្យខាងសោភណ-ភាពដ៏ថ្លៃករបស់សិល្បខ្មែរទេ ។ អានុភាពនៃវប្បធម៌ឥណ្ឌៀ ពិតជាមានមុខងារដ៏ធំក្នុងសិល្បខ្មែរ នេះគឺជាការធម្មតា ។ អានុភាពវប្បធម៌ឥណ្ឌៀ បានបង្កើតឲ្យមានប្រភពខាងសិល្បៈនៃប្រទេសច្រើន តែនៅសម័យដើមបំផុត ហើយក្នុងករណីយជាច្រើន អានុភាពនេះបានចាក់ចុចញ៉ាំងសកម្មភាពខាងបង្កើតដោយខ្លួនឯងឲ្យកើតមានទៅវិញទេ ។ មិនយូរប៉ុន្មាន ទេពកោសល្យនៃសិល្បករខ្មែរ ក៏ដោះខ្លួនស្រឡះចេញពីអា-នុភាពសិល្បឥណ្ឌៀនោះ ដើម្បីងាកមកចូលក្នុងមាគ៌ានៃការកសាងជាបែបរបស់ខ្លួនសុទ្ធ ។

រជ្ជកាលនៃព្រះបាទសុរ្យវរ្ម័នទី ២ បានគង់នៅអស់រយៈវេលា ៣២ ឆ្នាំ (១១១៣-១១៤៤) ប្រាសាទអង្គរវត្តជាស្នាព្រះហស្តនៃព្រះអង្គ ។ គឺព្រះអង្គនេះហើយដែលបានឡើងគ្រងរាជសម្បត្តិ ដោយសារតែទ្រង់ធ្វើការប្រយុទ្ធ ព្រះអង្គទ្រង់ការពារប្រឆាំងនឹងការលុកលុយមិនឈប់ឈរនៃពួកចាម អ្នកជិតខាង ក៏ដោយពិធីប្រយុទ្ធដែរ ព្រោះតាំងពីយូរណាស់មកហើយ ដែលចាមមានគោលបំណងនឹងដណ្ដើមយកព្រះអធិរាជាណាចក្រដ៏មានអំណាចនេះ ។ ព្រះមហាក្សត្រតាំងឡាយជាតំណពីព្រះបាទសុរ្យ-

វរ្ម័ន ទ្រង់បានតស៊ូធ្វើសង្គ្រាមជានិច្ច ប្រឆាំងនឹងពួកចាមទៀត ។ មានព្រះរាជទាយាទមួយព្រះអង្គនៃព្រះរាជបល្ល័ង្កខ្មែរ ទ្រង់បានធ្វើការប្រយុទ្ធក្នុងចំណោមទ័ពស្រួចនៅឱកាសនៃការរុករានរបស់ពួកចាម ។ ព្រះអង្គនេះឥតបានសោយរាជ្យ មិនមានព្រះហានទ្ទសក្តិជាអ្នកក្នុងព្រះរាជអាណាចក្រទេ ហើយមិនយូរប៉ុន្មាន ទ្រង់ក៏កៀសព្រះអង្គចេញពីឆាកនយោបាយ ព្រមទាំងពីព្រះបរមរាជវាំងអង្គរផងទៀត ។ ក្នុងរយៈកាលប្រមាណជាង ១០ ឆ្នាំ ទ្រង់បានជ្រាបអស់នូវសេចក្តីទុក្ខព្រួយកើតអំពីការលុកលុយរាតត្បាតផ្សេង ៗ ។ ទ្រង់បានស្តេចចេញធ្វើព្រះរាជដំណើរទេសន្តរក្នុងប្រទេសដោយប្លែងព្រះអង្គជាមនុស្សធម្មតា ហើយទ្រង់បានទតឃើញច្បាស់នូវជីវភាពនៃជនសាមញ្ញទាំងឡាយ ។ ព្រះអង្គមានព្រះជន្ម ៥០ ឆ្នាំហើយ ទ្រង់មានការពិសោធន៍ មានព្រះហឫទ័យស្លូតបូត សុភាពរាបសា តាមការណ៍ដែលទ្រង់បានចូលស៊ីបក្នុងព្រះពុទ្ធសាសនា ។ ក្នុងរយៈកាលប៉ុន្មានឆ្នាំក្រោយមក ទ្រង់ស្រាប់តែបានឡើងជាឥស្សរជនដ៏ធំបំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ ។ តមក ឥស្សរជននេះមិនគឺអ្នកណាក្រៅពីព្រះបាទជ័យវរ្ម័នទី ៧ ឡើយ ទ្រង់សោយរាជ្យពីឆ្នាំ ១១៨១ ទៅទល់ឆ្នាំ ១២០១ ។

នៅសម័យនោះ ខ្មែរនឹងចាមប្រយុទ្ធគ្នាយកស្លាប់រស់ ។ តាមដើមគោក ចាមទទួលបរាជ័យ ហើយបានប្រែកលល្បិចជាចុងក្រោយអស់ គឺបានដឹកនាំទ័ពតាមទូកដោយសម្ងាត់ បើកប្រាសទន្លេមេគង្គ ឆ្ពោះមក

ទន្លេសាប ។ នៅឆ្នាំ ១១៧៧ កងទ័ពជើងទឹករបស់ចាំ បានមកបោះយុទ្ធា ដោយលួចលាក់ នៅពីខាងក្រោយទីក្រុងដែលគ្មានការប្រុងប្រៀបសោះ។ ខាងក្រោយពីការប្រយុទ្ធស៊ីសាច់មក អង្គរក៏ត្រូវទទួលបរាជ័យ រួចត្រូវបច្ចាមិត្រចូលដណ្ដើមយកសម្បត្តិទ្រព្យ និងបំផ្លិចបំផ្លាញចោល ។ នៅឆ្នាំ ១១៨០ ពួកចាមក៏ដកខ្លួនថយទៅវិញ ហើយនាំយកទៅជាមួយផងនូវរបស់របរជាច្រើន ព្រមទាំងអ្នកទោសទាំងឡាយ ព្រោះចាំយល់ច្បាស់ថាខ្មែរអស់បានកម្រើកហើយ ។

តែមិនមែនដូច្នោះឯណា ដំណើរការណ៍ស្រាប់តែប្រែត្រឡប់ផ្សេងទៅវិញ គួរជាទីអស្ចារ្យពន់ពេកក្រៃ គឺថាព្រះរាជាណាចក្រខ្មែរត្រូវមានជីវិតឡើងវិញ ។ រឿងនេះជាហេតុមួយដែលបញ្ជាក់ឲ្យឃើញច្បាស់នូវកម្លាំងនៃថាមពលជីវភាពរបស់អារ្យធម៌ខ្មែរ ទើបជាកម្លាំងដែលបញ្ជាក់ឲ្យឃើញម្យ៉ាងទៀតថាការត្រឡប់មានកំណើតឡើងវិញនេះ គឺជាគុណធម៌នៃមហាប្រជាពលរដ្ឋតែម្ដង ។ ពេលនោះ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់កាន់បន្តនៃព្រះរាជរដ្ឋាភិបាល ។ មិនឆ្ងាយពីប្រាសាទអង្គរវត្តប៉ុន្មាន មានព្រះរាជធានីមួយបានផុះឡើង គឺអង្គរធំ ។ ទ្រង់បានកសាងព្រះរាជ-ធានី ដោយមានកំផែងសិលាកម្រាស់ ៧ មែត្រព័ទ្ធជុំវិញ ដើម្បីការពារនឹងការលុកលុយដ៏យ៉ាងរហ័ស ។ ឯការធ្វើរបៀបនេះ ជាគ្រាលើកដំបូងបង្អស់ក្នុងប្រវត្តិសាស្រ្តអង្គរ ។ ជីវភាពក៏ត្រឡប់មានដំណើរប្រព្រឹត្តទៅ

ជាធម្មតាឡើងវិញ ។ រជ្ជកាលនៃព្រះបាទជ័យវរ្ម័នទី ៧ មានសភាពជំ-យូរ (ប្រហែល[1] ៤០ ឆ្នាំ) ។ សេដ្ឋកិច្ចនៃប្រទេសបានត្រូវរីកចំរើនឡើងជាថ្មី ។ ក្នុងតំបន់អង្គរ មានប្រជារាស្ត្រចំនួនមួយលាននាក់ ។ ចំណែករបៀបបង្ហូរទឹកដាក់ស្រែ ក៏បានត្រឡប់មានជាថ្មីឡើងវិញដែរ ។ គេកសាងថ្នល់សុទ្ធសឹងក្រាលថ្ម ។ ព្រះវិហារ សាលាសំណាក់ពេលរាត្រីទីជម្រកសម្រាប់បូជនិយេសក៍នឹងឈ្មួញ ដុះដូចផ្សិតនៅហូរហែតាមថ្នល់ទាំងឡាយ ។ តាមប្រវត្តិសាស្ត្រដាច់បាស់ថាមានការកសាងមន្ទីរពេទ្យដល់ទៅ ១២០ ខ្នងផង ។ ព្រះបរមរាជវាំង មានសភាពដ៏រុងរឿង ក្ស ចិញ្ចាចចិញ្ចែង ពោរពេញដោយព្រះមហាកិត្តិយសរកអ្វីប្រៀបគ្មាន ។ ព្រះពុទ្ធសាសនាមិនបានធ្វើអ្វីឲ្យមានការប្រែប្រួល ចំពោះរឿងស្តីពីការទុកព្រះមហាក្សត្រជាទេពតាឡើយ ហើយព្រះមហាក្សត្រទ្រង់តែងអនុញ្ញាតឲ្យប្រជារាស្ត្រក្រីក្រចូល[2] ក្រាបបង្គំគាល់ជាធម្មតា ដើម្បីថ្លែងសេចក្តីសុខទុក្ខថ្វាយព្រះអង្គទ្រង់ជ្រាប ។ សិលាចារឹកពោលអំពីព្រះបាទជ័យវរ្ម័នទី ៧ ថា: ។

---

១. សេចក្តីត្រង់នេះ ហាក់ដូចជាមិនស្របនឹងសេចក្តីខាងលើដែលថាទ្រង់សោយរាជ្យពី ១១៨១ ដល់១២០១ ។ ២ ដំណើររៀបរាប់ស្តីពីការអនុញ្ញាតឲ្យប្រជារាស្ត្ររបស់ព្រះអង្គ ចូលក្រាបបង្គំគាល់ដើម្បីថ្លែងសេចក្តីសុខទុក្ខថ្វាយ ជាព្រះរាជប្រពៃណីខ្មែរមានមកតាំងពីជំនាន់អង្គរនេះ គឺជាព្រះកាយវិការដ៏សែនសប្បុរស នឹងរកព្រះមហាក្សត្រប្រទេសដទៃមកប្រៀបផ្ទឹមពុំបាន ។

« ទ្រង់ឈឺចាប់អំពីជម្ងឺនៃប្រជារាស្ត្រព្រះអង្គ ជាទ្រង់ឈឺចាប់អំ-ពីជម្ងឺផ្ទាល់ព្រះអង្គ » « ដ្បិតថា សេចក្ដីទុក្ខនៃប្រជារាស្ត្រ គឺជាសេចក្ដីទុក្ខនៃព្រះមហាក្សត្រ »

រឿងនេះ ជាសក្ខីភាពស្ដីពីព្រះគុណសម្បត្តិ ដែលមិនសូវមានចំពោះព្រះមហាក្សត្រសម័យស្ដេចត្រាញ់ ( moyen âge: យុគកណ្ដាល ) ។

ត្រូវតែសង់ឲ្យមានប្រាសាទមួយនៅអង្គរធំ នេះជាទម្លាប់ក្នុងក្រុងធំខ្មែរនីមួយ ៗ ក្នុងសម័យនោះ ។ មានសំណង់ពិសេសមួយអំពីថ្ម នៅកណ្ដាលកំផែងជាទីការពារ ជាមហាសំណង់ចុងក្រោយបង្អស់នៃសម័យខ្មែរអង្គរ ។ ឯមហាសំណង់នេះ គឺប្រាសាទបាយ័ន ។ ប្រាសាទនេះជាចំណុចបង្ហើយនូវការវិវត្តន៍នៃស្ថាបត្យកម្មខ្មែរ ។ សព្វថ្ងៃប្រាសាទបាយ័នបាក់បែកអស់ ។ ទោះបីយ៉ាងដូច្នេះក៏ដោយ គេនៅតែមានគំនិតអាចយល់បាន នូវហេតុដែលថាប្រាសាទបាយ័ន កាលពីដើមនោះយ៉ាងណា . . . ។ មានអ្នកជំនាញការខ្លះពោលថា: ទិដ្ឋភាពប្រាសាទបា-យ័នមិនជាបែប ជាគំរូដូចជាទិដ្ឋភាពនៃប្រាសាទអង្គរវត្តទេ ។ ប៉ុន្តែបាយ័នក៏ជាស្នាដៃខាងស្ថាបត្យកម្មមួយដ៏ពិតប្រាកដដែរ ដែលមិនគប្បីបំភ្លេចឡើយ ។ បាយ័នជាភ្នំអធម្មជាតិមួយដ៏ពិតធ្វើអំពីថ្ម ដែលមានកំពូលជាច្រើនលេចប្រូងឡើង ហើយក្នុងកំពូលនីមួយៗ មានមុខព្រហ្មបួនដ៏សម្បើម បែរទៅគ្រប់ទិសទាំងបួន ។ បាយ័នជាប្រាសាទមួយដ៏

ចម្លាក់ផ្សេង ហើយនៅអង្គរ គឺប្រាសាទបាយ័ននេះហើយជាលើកដំបូង ដែលគេដឹងថានៅមានជាតិចិត្តចាំងស្រស់ ។ គេនិយាយទៀតថា ការញញឹមនៃមុខព្រហ្មដ៏សម្បើមនៅប្រាសាទបាយ័ន នាំឲ្យទឹកដល់ព្រះភក្ត្រនៃព្រះបាទជយវរ្ម័នទី៧ ។ ចំពោះរឿងនេះ អ្នកទស្សនាមិនអាចបំភ្លេចបានឡើយ ។

ដំបូង ដួងព្រលឹងរមែងពោរពេញដោយបីតិសោមនស្សនឹងដោយការកោតសរសើរ កាលណាគេគ្រាន់តែដើរកាត់ប្រាសាទទាំងឡាយនៅអង្គរ ។ រួចមានបញ្ហាមួយកោទឡើងដល់គំនិតថា ៖ មនុស្សទាំងនោះដែលបានធ្វើឲ្យកើតមានការដ៏ធំច្រើនដូច្នេះ ដែលបានធ្វើឲ្យកើតមានថាមពលខាងការបង្កើតច្រើនដូច្នេះ តើមានជីវភាពដូចម្ដេច ? កាលគេកសាងប្រាសាទទាំងនោះ ដើម្បីជាបណ្ណាការណាកិត្តិយសដល់ព្រះមហាក្សត្រនៃអាត្មា តើគេគិតឃើញដូចម្ដេច ហើយគេមានអារម្មណ៍ដូចម្ដេច? ម្យ៉ាងទៀត ចុះហេតុអ្វី ក៏គេមិនកសាងប្រាសាទទាំងនោះខ្លះ ដើម្បីជាកិត្តិយសដល់ទេពកោសល្យដ៏ឆ្នើមអស្ចារ្យរបស់ខ្លួនផង នឹងដល់កម្លាំងយកចិត្តទុកដាក់ធ្វើមិនចេះនឿយហត់របស់ខ្លួនផង ? តើបែបសង្គមសម័យនោះដូចម្ដេច តើសង្គមសម័យនោះ បានធ្លងកាត់ការរើកបញ្ឆាប់ញ័រដូចម្ដេច ហើយបានធ្វើការប្រយុទ្ធយ៉ាងណា ? ការណ៍ទាំងនេះ ពិតជាអាចបញ្ចាំងឲ្យឃើញពន្លឺបានក្នុងការស្ថាបនាប្រាសាទទាំងនោះដែរ ព្រោះប្រាសាទ

តាំងឡាយជាតំណាងវត្ថុនៃសង្គមសម័យនោះ គេរមែងដឹងថាសិល្បករគ្រប់សម័យ តែងធ្វើដោយយកលំនាំជាទិដ្ឋពីមនុស្ស និងពីវត្ថុតាំងឡាយដែលនៅជុំវិញខ្លួន ។ ត្រូវយើងនិយាយដូច្នេះទៀតថាៈ បែបនិងនិមិត្តរូប គឺជារូបភាពមួយដោយចំពោះ ឬមិនចំពោះដែលទាក់ជាប់ទៅនឹងការណ៍ដែលមានពិតប្រាកដ ។ ជីវភាពសម័យនោះ សឹងប្រកបតែដោយប្រិយភាព ដោយពិធីបុណ្យផ្សេង ៗ និងដោយសេចក្តីស្នេហា ។ គេពោលជាញឹកញយតែអំពីការញញឹមចម្លែក ដែលផ្សាយចេញពីស្នាដៃខាងរចនានៃអង្គរ គឺជាការញញឹមដែលគេមិនអាចរកអ្វីមកប្រៀបផ្ទឹមបាន ។ ការញញឹមនេះមានសភាពដ៏មុតជ្រាលជ្រៅក្រៃលែង តែមិនមែនជាការញញឹមនៃអមនុស្សនៅនាលោកដទៃណាទេ ។ ចំពោះរឿងនេះ មិនត្រឹមតែការញញឹមប៉ុណ្ណោះទេ គឺមានរបាំងនៃអង្គរផងថែមទៀត ។ ប្រសិនបើគេអាចយករបាំងនេះចេញបាន នោះរឿងអាថ៌កំបាំងនៃអតីតកាលដ៏ពិតប្រាកដរបស់អង្គរ ប្រហែលជានឹងអាចលេចមានពន្លឺឡើងបាន ។

ឯចក្ខុក៏ចេះធ្វើឲ្យមានការរំភើបដែរ ព្រោះនៅត្រង់ថ្នាក់មួយនៃប្រាសាទអង្គរវត្ត មានការរចនាតាក់តែងជារូបភាពស្តីពីស្ថានសួគ៌ និងស្ថាននរក ។ ចំណែកស្ថានសួគ៌ គេរចនាមានទំនងព្រងើយ សោះកក្រោះបន្តិច តែឯការធ្វើទុក្ខទោសខាងស្ថាននរកវិញ គឺជារូបសំណាកដ៏ពិតរបស់លទ្ធិ

ធម្មជាតិនិយមតែម្តង ៗ តើផ្ទាំងចម្លាក់ទាំងនេះ គេធ្វើសម្រាប់អ្នកណា? តើសិលាចារឹកទាំងនេះ គេឧទ្ទិសចំពោះអ្នកណា ? ព្រោះសិលាចារឹកនេះមិននិពន្ធជាភាសាសំស្ក្រឹតទេ គឺនិពន្ធជាភាសាខ្មែរជាន់ចាស់ដូច្នេះថា :

« ស្ថាននរក : ការធ្វើទោសបំបែកឆ្អឹង ចំពោះជនណាដែលបំផ្លាញ
« បំផ្លាញសួនច្បារ ដែលធ្វើអន្តរាយដល់ទីលំនៅ រអាងទឹក
« អណ្តូងទឹក ព្រះវិហារ . . . »

« ស្ថាននរក: ការធ្វើទោសដោយយកទៅស្ងោរក្នុងឆ្នាំងខ្ទះ ចំពោះ
« ជនណាដែលបានកែបំបាត់យកព្រះគជទ្រព្យ ដែលលួចទ្រព្យ
« គ្រូ និងទ្រព្យពួកព្រាហ្មណ៍ទាំងឡាយ . . . . »

« ការធ្វើទោសដោយយកទៅផ្អើរលើរងើកភ្លើង ចំពោះជនណា
« ដែលមិនសងបំណុលគេ . . . »

« ការចងព្យួរនឹងដើមឈើមានបន្លា ( រកា? ) ដល់អ្នកធ្វើសាក្សី
« កោង . . . »

« ការធ្វើទោសគួរឲ្យស្ញប់ស្ញែងជាងគេនៅស្ថាននរក គឺនរកដង្កូវ
« ចំពោះជនណា ដែលប្រមាថមើលងាយព្រះអាទិទេព ពួក
« ព្រាហ្មណ៍អ្នកចេះដឹង តាមាបិតានិងមិត្តសំឡាញ់ . . . »

លុះតែក្នុងពេលនេះ ទើបអនុស្សាវរីយ៍នៃជីវតាក្វាន អ្នកការទូតចិន

អមព្រះមហាក្សត្រខ្មែរ (១២៩៦) ហើយដែលបានអាស្រ័យនៅប្រ-

ហែលមួយឆ្នាំនាអង្គរធំ មានន័យពេញលក្ខណៈ ។ កស្កុតាន់ជាលាយ

លក្ខអក្សរនេះ ជាប្រភពតែមួយដែលសម្រាប់ឲ្យគេអាចក្រេបយកបាន

នូវដំណើរការណ៍ទាំងឡាយស្តីពីជីវភាពក្នុងសម័យនោះ ។ ជីវតាក្អួន

មិនសង្កេតតែត្រឹមជីវភាពនៅព្រះរាជវាំងប៉ុណ្ណោះទេ គឺបានសង្កេតពិនិត្យ

ទាំងជីវភាពនៅទីក្រុងផង ។ មុនពេលដែលគេរកឃើញអង្គរ នៅប្រ-

ទេសអឺរ៉ុប គ្មាននរណាយកចិត្តទុកដាក់ជាខ្លាំង ចំពោះអនុស្សាវរីយ៍ជា

លាយលក្ខអក្សររបស់ជីវតាក្អួនឡើយ ។ សព្វថ្ងៃនេះ ទើបគេដឹងថាជីវ-

តាក្អួន មិនបានគាក់តែង មិនបានបំផ្លើសអ្វីបន្តិចបន្តួចសោះ ។

ជីវតាក្អួននិទានថា :

ខ្មែរអ្នកស្រែប្រតស្រូវបី ឬបួនដងក្នុងមួយឆ្នាំ ។ តើត្រូវឲ្យប្រជា

រាស្ត្រចិញ្ចឹមជីវិតដោយប្រការម្តេចទៅវិញ ក្រៅពីរបៀបនេះ ?

ជញ្ជាំងប្រាសាទសឹងតុបតែងលំអដោយរូបគំនូរឆ្លាក់តពណិ ដំបូល

ក្រឡូមនៃកំពូលប្រាសាទបិទស្លឹកនៃមាសសន្លឹក ។

គេបានឃើញស្នាមក្រហមឆ្អៅ នៅត្រង់កន្លែងកំបាំងខ្លះនៃប្រា-

សាទអង្គរ ។

ព្រះមហាក្សត្រ លុះតែព្រះអង្គទ្រង់គ្រឿងគ្រោះដែលមុខកាំបិតក្តី

ព្រួញក្តី មិនអាចធ្វើឲ្យព្រះអង្គរបួសបាន ទើបទ្រង់ស្តេចយាងចេញពីព្រះ

បរមរាជវាំង ។ ព្រះអង្គទ្រង់ព្រះម្កុដមាស ផ្ចង់ព្រះកេសាលំអដោយក្លួងមាលាដ៏យ៉ាងក្រអូបដូចផ្កាម្លិះ ។ ព្រះសុវង់ទ្រង់កងកជើងទម្ងន់ប្រហែលបីនាឡិ ។ កព្រះហស្ត ទឹងភ្លូព្រះហស្ត លំអដោយគ្រឿងអលង្ការមាសដាំត្បូងដ៏មានដំឡៃ ។ ព្រះអង្គទ្រង់ព្រះខ័នមាសផង នៅវេលាដែលទ្រង់ស្ដេចចេញពីព្រះបរមរាជវាំង ។ ក្បួនហែព្រះអង្គ មានសភាពដូចគ្នាបេះបិទ នឹងរូបភាពនៅផ្ទាំងចម្លាក់ទាំងឡាយ ។ ព្រះខ័នមាសជានិមិត្តរូបនៃព្រះរាជាធិបតេយ្យ គេដំកល់ទុកនៅព្រះរាជធានីភ្នំពេញសព្វថ្ងៃ ។

រឿងប្រើខ្ញុំកំដរ មានគ្រប់ទីកន្លែង មានតែអ្នកក្រខ្សត់ទេដែលគ្មានខ្ញុំកំដរប្រើ ។ ការជំរះក្ដីនៃតុលាការ ច្រើនមានទម្រង់ជាតុលាការដោយយកទេពតាជាប្រធាន ។ ការពិន័យទោសមានសភាពដ៏តឹងរឹងណាស់ៈ សម្លាប់ក្បាល ។ កាត់ដៃកាត់ជើង ឬកប់ទាំងរស់ ។

នេះហើយជារឿងដែលជីវតាក្វានបាននិទាន ។ គឺពិតជាមួយរយឆ្នាំគត់ មុនពេលដែលគាត់មកដល់អង្គរ ដែលសិល្បករខ្មែរបានឆ្លាក់រូបភាពដែលមានក្នុងសៀវភៅរបស់គាត់ នៅទីជញ្ជាំងបាយ័នជាប្រាសាទដែលអ្នកមិនគោរពសាសនា មិនអាចចូលដល់បាន ។ រូបភាពនេះជាផ្នែកដ៏មានដំឡៃបំផុតនៃប្រាសាទបាយ័ន ដែលជាឃ្លាំងមានដំឡៃខាងប្រវត្តិសាស្ត្រដ៏ពិតប្រាកដ ។ ជាងបានយករឿងរាល់ជីវិតនៅតាមថ្នល់ទីង

ទីលំនៅដ៏គ្រោតគ្រាត មកដាក់ទុកនៅប្រាសាទបាយ័ន ហាក់ដូចជាខ្លួន ទើបនឹងមានសេរីភាពភ្លាម អំពីការអនុសញ្ញាទាំងអស់ខាងសាសនា ៗ ជាលើកដំបូង នៅប្រាសាទនោះ គេឃើញរូបភាពនៃស្ត្រីសាមញ្ញ រូបកូន-ក្មេង ផ្សារកំពង់លក់ដូរ ភាពពិតប្រាកដនៃទីលំនៅ ហើយមិនតែប៉ុណ្ណោះ មានទាំងការប្រដល់មាន់ មានសិល្បករគោចរកំពុងសំដែងរឿងផង ...ៗ រឿងទាញសង្គ្រាមប្រឆាំងនឹងចាមក៏នៅរស់រវើកក្នុងគំនិតដែរ ៗ នៅជុំង ចម្លាក់នៃប្រាសាទបាយ័ន គេឃើញរូបភាពផ្សេងច្រើនទៀត គឺរូបភាពមិនត្រឹមតែស្តីអំពីសេចក្តីអង់អាចក្លាហាន នឹងជោគជ័យនៃមេទ័ពប៉ុណ្ណោះទេ មានទាំងការប្រយុទ្ធគ្នារវាងទាហានម្នាក់ទល់នឹងម្នាក់ សេចក្តីទុក្ខព្រួយនៃប្រជារាស្ត្រផងថែមទៀត . . . ៗ នេះជាលើកដំបូងហើយ ដែលរូបភាពនៃការពិតការមែន បានច្រៀតចូលក្នុងស្រមោលព្រឹល ៗ នៃប្រាសាទនៅអង្គរ ៗ

កាលដែលអ្នកការទូតចិន ខាងក្រោយការសំណាក់អាស្រ័យនៅមួយឆ្នាំ បានថយចេញពីប្រទេសទៅ អានុភាពនៃព្រះអធិរាជាណាចក្រខ្មែរ បានឡើងដល់កំពូលហើយ ៗ ឯការរស់នៅនៃប្រជាពលរដ្ឋ បានប្រព្រឹត្តទៅស្រួល តែដោយសារលទ្ធផលអំណាចជោគជ័យពីអតីតកាលរបស់ខ្លួនប៉ុណ្ណោះ ៗ គេមិនដឹងនូវហេតុដ៏ជាក់ច្បាស់ដែលបណ្តាលឲ្យវីរភាពនោះអន្តរធានសាបសូន្យ នៅសតវត្សទី ១៥ ឡើយ ៗ ប្រហែល

ទីតាំងនៃព្រះរាជធានី ស្ថិតនៅជ្រុលទៅទិសពាយព្យពេកក៏មិនដឹង ដែលជាហេតុនាំឲ្យទ្វារចំហរទៅរកការលុកលុយរាតត្បាតនៃពួកថៃ មានចំនួនច្រើនជានិច្ចនោះ ។ ប្រហែលមកពីមានទឹកជំនន់ មានទុរ្ភិក្ស មានជម្ងឺកាតត្បាត ធ្វើឲ្យអន្តរាយដល់ប្រជារាស្ត្រទេដឹង? ព្រោះគ្រាន់តែមានការប្រហែសបន្តិចក្នុងកិច្ចថែរក្សានូវរបៀបដ៏សំខាន់ខាងពិធីបញ្ចូលទឹកដាក់ស្រែ អាចកំហែងគំរាមដល់ផលដំណាំទាំងឡាយបាន ។ រឿងសាបសូន្យនេះបណ្តាលមកពីជំលោះគ្នាឯង ទឹងមកពីការប្រយុទ្ធនៃវណ្ណៈ ក៏សឹងថាបាន ។ ប៉ុន្តែរឿងមួយដ៏ពិតនោះ គឺនៅត្រង់ដែលទីក្រុងបានត្រូវរំកិលទៅទិសបូព៌ា ហើយជាអវសាន មកដល់ទីកន្លែងបច្ចុប្បន្នគឺភ្នំពេញនេះឯង ដែលជាព្រះរាជធានីប្រទេសកម្ពុជាសព្វថ្ងៃ ។

អង្គរតំណាងវត្ថុធាតុសកម្មមួយនៃប្រពៃណីជាតិសព្វថ្ងៃ ។ គេយករូបអង្គរវត្តមកធ្វើជាទង់ជាតិប្រទេសកម្ពុជា ។ ហើយសិល្បខ្មែរសោភរមែងស្ថិតនៅអាចិន្ត្រៃ ជាសម្បត្តិដ៏ប្រសើរថ្លៃថ្លាមួយភាគ សម្រាប់ចូលរួមក្នុងអំណោយជាគ្រឿងខាងវប្បធម៌នៃមនុស្សលោក ។

# ពាក្យខ្មែរប្រែពីបរទេស

## ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ « ក »

( តមក )

---

| | | |
|---|---|---|
| Acquérir à titre gratuit | បានដោយទទេ | (ព.ឬ.)។ |
| Acquisition à titre gratuit | ការបានដោយទទេ | (ព.ឬ.)។ |
| Action en nullité | បណ្តឹងសុំឲ្យទុកជាមោឃៈ | (ព.ឬ.)។ |
| Aliéner à titre onéreux | ផ្ទេរដោយចេញថ្លៃ | (ព.ឬ.)។ |
| Aliéner à titre gratuit | ផ្ទេរដោយទទេ | (ព.ឬ.)។ |
| Annuler (v.t.) | ធ្វើមោឃកម្ម | (ព.ឬ.)។ |
| Annulation (n.f.) | មោឃៈកម្ម | (ព.ឬ.)។ |
| Aveugle (abj.) | ខ្វាក់ ។ | |
| Assistance judiaire | តុលាការសង្គ្រោះ | (ព.ឬ.)។ |
| Astreintes (n.f. pl.) | ប្រាក់បង្ខំ | (ព.ឬ.)។ |

— B —

| | | |
|---|---|---|
| Biens communs | ទ្រព្យរួម | (ព.ឬ.)។ |
| Biens propres | ទ្រព្យដើម | (ព.ឬ.)។ |

— C —

| | | |
|---|---|---|
| Casser ou annuler un jugement ou un arrêt | បដិសេធសាលក្រម ឬសាលដីកា | (ព.ឬ.)។ |
| Cause de divorce | បុព្វហេតុនៃការលះលែងគ្នា | (ព.ឬ.)។ |
| Cécité (n.f.) | ភាពខ្វាក់ | (ព.ឬ.)។ |

( នៅមានត )

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ទាំង . ទាត់ រៀបរៀង*

( តមក )

---

អតិឝយ, ចុំ. ភាគច្រើន, ។ *អតិឝយម៑ អតិឝយេន អតិឝយតស៑* ដោយច្រើន ។ *អតិឝយវន្ត* គុ. ដែលមានភាគច្រើន ។

អតិឝយន អតិឝយនី គុ. ដែលប្រសើរកន្លង, ឧត្តម ។

អតិឝយិត គុ. ដែលថ្លៃថ្លាកន្លង ។

អតិឝយិន៑ គុ. ដែលខ្ពង់ខ្ពស់ ដែលថ្លៃថ្លាកន្លង ។

អតិឝស្ត្រ គុ. ដែលមានអាវុធក្រៃលែង ។

អតិឝាត គុ. ដែលរីករាយក្រៃលែង ។

អតិឝាយន នបុំ. កិរិយាខ្ពង់ខ្ពស់ក្រៃលែង ។ គុ. ដែលខ្ពង់ខ្ពស់កន្លង ។ *អតិឝាយិន៑* គុ. ដែលប្រសើរកន្លង ។

អតិឝិឝិរ គុ. ដែលត្រជាក់ក្រៃលែង ។

អតិឝិឞ៑ ធាតុ. សល់នៅ ។ *អតិឝិឞ្ត* គុ. ដែលសល់នៅ ។

អតិឝី ធាតុ. ហោចក្រៃលែង បោះបង់ចោល លះបង់ចោល ។

(នៅមានត)

# រឿងសាមកុក

## ក័ណ្ឌទី ៤៨

ឧកញ៉ាវិបុលរាជសេនា នង-កាង ប្រែរៀបរៀង

( តមក )

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះខ្វាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ
>
> យូរ - អ៊ុន

ប៊ូឆ្វក៏យកក្រើបកាត់ពុកមាត់ពុកចង្កាអស់ ពួកទាហានម៉ាឆៀវស្រែកថា ប៊ូឆ្វកាត់ពុកមាត់ពុកចង្កាអស់ហើយ ឲ្យចាប់ខ្លួនអាពុកមាត់ខ្លីឲ្យបាន ប៊ូឆ្វក៏យកព្រែកន្ទុយទង់រុំចង្កាហើយបំផាយសេះចេញទៅ ម៉ាឆៀវបំ-ផាយសេះតាម ប៊ូឆ្វក្រឡេកមកឃើញម៉ាឆៀវតាមពីក្រោយក៏ភ័យណាស់ ភ្ញាក់ធ្លាក់ពីលើសេះរត់ចូលទៅអែបផ្អាប់គល់ឈើមួយ ម៉ាឆៀវក៏បន្ទំសេះស្ទុះចូលទៅជិតលើកលំពែងពួយទៅ មិនត្រូវប៊ូឆ្វក៏ត្រូវដើមឈើជាប់លំ-ពែង ប៊ូឆ្វក៏គេចស្ទុះរត់វាងពីទីនោះចូលទៅក្នុងព្រៃ ម៉ាឆៀវស្ទុះទៅដកយកលំពែងបាន ហើយដេញតាមប៊ូឆ្វទៅទៀតជិតនឹងទាន់ ទទួលហោហងបរសេះមកទាំង ក៏តាំងតែប្រយុទ្ធគ្នានឹងម៉ាឆៀវបាន ៥០០ ក្បួន

ហៃហ៊ូគៀនឃើញពលហានខ្ទក់កម្លាំងណាស់ ក្រែងថ្លស់ការទីងម៉ាឈៀវ ក៏បរសេះចូលទៅជួយ ម៉ាឈៀវក៏ដេញហួសផុតពួកទាហានទៅតែម្នាក់ឯង មិនទុកចិត្តក៏ញាក់សេះវិលថយមកក្រោយវិញចូលបន្ទាយតុងគួន ចុចូក៏ត្រឡប់ចូលបន្ទាយ តាំងកំដាប់ពលទាហានឲ្យយាមល្បាតប្រយ័ត្នការជាមាំមួន មិនបានចេញតទីងម៉ាឈៀវ ហើយក៏លើកសេចក្តីគាប់ប្រសើរដល់ពលហានឲ្យបានបំណាច់រង្វាន់ជាច្រើន ។

ឯម៉ាឈៀវក៏ចាត់ការប្រុងប្រៀបទាហាន ដើម្បីទីងចេញទៅវាយយកបន្ទាយចុចូទៀត តែឃើញថាចុចូប្រយ័ត្នការមាំមួនមិនបានចេញត ម៉ាឈៀវក៏ឲ្យផ្លាស់ប្តូរទាហានទៅស្រែកជេរបញ្ឈឺចិត្តចុចូ នៅមុខបន្ទាយទាំងយប់ថ្ងៃមិនដាច់ ទាហានចុចូឮដូច្នេះខឹងណាស់ គិតគ្នាទីងលើកចេញមកតយុទ្ធទីងម៉ាឈៀវ ។

ចុចូនិយាយយកចិត្តទាហានទាំងពួងថា ដែលម៉ាឈៀវឲ្យមកជេរបញ្ឈឺចិត្តដូច្នេះ ប្រាថ្នាទីងឲ្យយើងក្តៅក្រាំនៅស្ងៀមមិនបាន បើយើងទីងលើកទាហានចេញទៅតវេលានេះ ក៏ដូចជាចាញ់ប្រាជ្ញាម៉ាឈៀវ អ្នកទាំងពួងចូរជួយគ្នាគិតតែរក្សាបន្ទាយកុំឲ្យអន្តរាយសិនចុះ ការដែលទីងគិតយកជ័យជំនះនោះ ជាភ្នាក់ងារលើយើង បើអ្នកឯណាមិនស្តាប់យើង ខំតែលើកគ្នាចេញទៅតទីងម៉ាឈៀវ យើងទីងកាត់ក្បាលចេញ ។

ទាហានទាំងពួងឮដូច្នោះ ក៏នាំគ្នាថយចេញទៅ ហើយនិយាយគ្នាថា

ពីដើមមហាឧបកជនឹងចេញធ្វើការរណរង្គសង្គ្រាម ក៏អង់អាចមិនចេះខ្លាចសោះ មានតែចេញទៅមុខបង្អស់ ដូចគ្មានញញើតអ្នកឯណា វេលានេះទើបឃើញថាមហាឧបកជខ្លាចថ្វីដៃម៉ាឈៀវ សូម្បីម៉ាឈៀវឲ្យមនុស្សមកស្រែកជេរប្រមាថដល់មុខបន្ទាយក៏នៅស្ងៀមបាន កន្លងមក ៣ ថ្ងៃ ទាហានចេញទៅស៊ើបការវិលមកជំរាបចូឆូថា ឥឡូវមានទាហានម៉ាឈៀវលើកមកថែមទៀតពីរម៉ឺន ចូឆូឮដូច្នោះក៏គិតថា ពីស្រុកសែ-លៀងនឹងមកដល់បន្ទាយតុងគួននេះ គឺជាផ្លូវឆ្ងាយដាច់ស្រយាលណាស់ ម៉ាឈៀវមានកម្លាំងខ្លាំងពូកែមែន តែនៅក្មេងសេចក្ដីគំនិតប្រាជ្ញាមិនធ្លាប់កាន់ការធំសោះ ទាំងមិនទាន់ចំណានចេះផ្ចាស់ប្ដូរយកចិត្តទាហានទាំងពួង យូរទៅស្បៀងអាហារក៏គង់នឹងដាច់ចុះ មុខជាទាហានក្នុងចំ-ណុះនឹងប្រែចិត្តចេញពុំខាន យើងក៏នឹងបានធ្វើការពេញដៃ ចូឆូនិយាយនឹងទាហានទាំងពួងថា ដែលទាហានម៉ាឈៀវបញ្ជូនមកទៀត ២ ម៉ឺននោះ យើងមានអំណរណាស់ នឹងគិតយកជ័យជំនះឲ្យបាន ។

មានមួយថ្ងៃនោះ ពេលព្រឹក មានបំរើមកប្រាប់ចូឆូថា ទាហានម៉ា-ឈៀវបញ្ជូនមកទៀតច្រើនណាស់ ចូឆូឮដូច្នោះក៏អស់សំណើចហើយថា ការសង្គ្រាមគ្រានេះ យើងមុខជាយកជ័យជំនះឲ្យបាន ហើយក៏តែងតុ-លៀងអាហារបណ្ដាសេនាទាហានខ្ញុំរាជការទាំងពួង ពេលកំពុងសេពសុរានោះ ពួកទាហានក៏នាំគ្នាពិគ្រោះដល់ការសង្គ្រាមដែលចូឆូញញើត

ខ្លាចម៉ាឈៀវហើយក៏នាំគ្នាញញឹម ចូចូកូនស្ងួរសេដ្ឋិនប្រាជ្ញាទឹងចង់ ច្បាស់ចិត្តទឹងគំនិតសេនាទាហានទាំងពួងថា អ្នកទាំងពួងញញឹមឡកឲ្យ យើងឬអ្វី? ប្រហែលអស់អ្នកពល់គ្នាសំគាល់ថា យើងទឹងចាញ់ថ្វីដៃ ម៉ាឈៀវអស់គំនិតគិតហើយឬ? តើសេចក្តីគិតនៃអ្នកទាំងពួងទឹងរិះគិតដូច ម្តេច? ដែលទឹងយកជ័យជំនះបាន ក៏ចូរប្រាប់មកឲ្យយើងដឹងចុះ ។

ស៊ុំឡុងឆ្លើយថា ដែលមហាឧបពជនៅក្រៅបន្ទាយនេះឲ្យខ្ជាប់មាំមួន នោះក៏ជាការប្រពៃណាស់ ឥឡូវម៉ាឈៀវក៏តាំងនៅក្នុងបន្ទាយគុំគួន មានចិត្តកំរើបគ្មានសេចក្តីរង់ការពារផ្លូវក្រោយទេ សូមឲ្យមហាឧបពជ តាក់ទាហានឲ្យលើកទ័ពទៅតាំស្ទាក់ស្បៀង វាយខ្ចប់ពីក្រោយមកវិញ ដើម្បីឲ្យម៉ាឈៀវវង្វេងស្ទូនខាងក្រោយ ហើយសឹមយើងលើកទ័ពខ្ចប់ វាយយកបន្ទាយគុំគួនវិញ គង់ទឹងបានដោយងាយ ចូចូព្ធចូហោះក៏ កូនឆ្លើយតបទៅស៊ុំឡុងវិញ ដើម្បីមិនឲ្យមនុស្សទាំងពួងមើលងាយប្រាជ្ញា ថាយល់តាមគំនិតគេ ថាគំនិតអ្នកឯងដែលនិយាយនេះ ត្រូវគំនិតខ្ញុំដែរ តែថាមិនទាន់ជ្រៅប៉ុន្មាន គំនិតយើងយល់ជ្រៅជាងនេះ យើងត្រូវប្រើ ឲ្យអ្នកឯងទឹងជូឡេងលើកពល ៦ ពាន់លបចេញទៅ បើឃើញព្រៃទឹងភ្នំ ឯណាជាផ្លូវមានទំនងស្រួល ក៏ត្រូវឲ្យពួនបង្កប់នៅទីនោះ យើងទឹងលើក ពលទៅតាមតាំស្ទាក់មុខទ័ពទឹក ហើយទឹងពមកវាយយកបន្ទាយគុំគួន វិញ ខាងអ្នកឯងត្រូវវាយខ្ចប់ចូលមកពីម្ខាង ស៊ុំឡុងទឹងជូឡេង ទទួល

ប្រសាសន៍ហើយលាចូឆូលើកទាហានចេញទៅ ចូឆូក៏ប្រើចោយិនឃុំទាហាននៅក្រោយបន្ទាយ ហើយក៏នាំចោហងលើកទាហានព័ទ្ធទៅតាំងតទូកចម្បាំងនៅមាត់កំពង់ស៊ូងហ៊ុយហោខាងទិសឯកើតបន្ទាយតុងគួន ។

ឯម៉ាឈៀវ កាលបើដឹងការណ៍ដូច្នោះក៏និយាយនឹងហ័នស៊ុយនៅទាហានទាំងពួងថា ឥឡូវចូឆូលើកទ័ពទៅតាំងនៅមាត់កំពង់ ប្រាថ្នានឹងចាំវាយទ័ពទឹករបស់យើង បើយើងលើកទ័ពឆ្លងទៅត្រើយម្ខាងចាំស្កាត់ផ្លូវស្បៀងឲ្យបាន គង់តែចូឆូនឹងចាញ់ប្រៀបយើងប្រាកដ ហ័នស៊ុយឆ្លើយថា ដែលនឹងលើកទ័ពទៅស្កាត់ផ្លូវស្បៀងនោះឃើញមិនស្រួល ព្រោះជាទីកណ្ដាលកងទ័ពចូឆូ ត្រូវយើងរង់ចាំឲ្យចូឆូឆ្លងមកត្រើយខាងណោះកាលណា សឹមទៅលើកទ័ពទៅខ្ទប់ពីក្រោយ យើងនឹងឃុំពលទល់ពីមុខ មុខជាចូឆូនឹងបែកខ្ញែកមិនខាន ម៉ាឈៀវឮដូច្នោះក៏គិតឃើញត្រូវផង ទើបឲ្យទាហានទៅសើបយកការខាងកងទ័ពចូឆូថានឹងចូលវាយយកបន្ទាយតុងគួនវេលាណា ។

(នៅមានត)

# សកម្មភាព
# នៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បានតាំងឡើងតាមព្រះរាជប្រកាសលេខ ១២ ចុះថ្ងៃ២៥ មករាឆ្នាំ ១៩៣៨ ។ ក្រុមជំនុំនេះ ជាផ្នែកមួយសំខាន់ណាស់ក្នុងចំណោមផ្នែកនានា ដែលមានកន្លែងធ្វើការនៅក្នុងផ្ទៃនៃក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ។

គោលធំរបស់ក្រុមជំនុំនេះ នៅត្រង់ការតែងជាសៀវភៅមួយបែបស្តីអំពីទំនៀមទម្លាប់ខ្មែរ និងប្រមែប្រមូលរក្សាទុក ព្រមទាំងផ្សាយជាបន្ត ៗ នូវឯកសារទាំងឡាយ ដែលស្តីអំពីអារ្យធម៌ខ្មែរបុរាណ ដើម្បីជាប្រយោជន៍ខាងជាតិពន្ធុវិជ្ជា ។

សមាសភាពនៃក្រុមជំនុំនេះ មានអធិបតីម្នាក់ អធិបតីរងម្នាក់ មានអ្នកជំនាញខាងអក្សរសាស្ត្រខ្មែរនិងលេខាធិការ ដែលបានទទួលការអប់រំសម្រាប់ជួយធ្វើការ ព្រមទាំងមានសមាជិកឆ្លើយឆ្លងជាច្រើនរូបដែលរាយតាមក្រុងនិងតាមខេត្តនានាក្នុងកម្ពុជាណាចក្រទាំងមូល សម្រាប់ធ្វើការទាក់ទងជាមួយផង ហើយសមាជិកទាំងនោះបានជួយឲ្យការដោយសប្បុរស ។

ក្រុមជំនុំបានទទួលឯកសារជាច្រើនពាន់ ដោយសមាជិកឆ្លើយឆ្លង

ទាំងនោះបានឲ្យការមកខ្លះ ដោយការអង្កេតយកការរបស់ក្រុមជំនុំផ្ទាល់ខ្លះ ដោយដាក់ឲ្យប្រឡងប្រជែងគ្នាមួយឆមាសម្តងខ្លះ នឹងដោយវិញ្ញូជនក្រៅពីសមាជិកធ្វើអំណោយមកខ្លះ ។ ឯកសារទាំងនេះច្រើនតែជារឿងទំនៀមទម្លាប់ខ្មែរ ដែលមានឫសគល់ទាក់ទងដោយព្រហ្មញ្ញសាសនា ឬដោយព្រះពុទ្ធសាសនា ។ ក្រុមជំនុំបានចុះលេខរៀងឯកសារទាំងនោះរក្សាទុកដោយដំពូក ៗ ជា ៩៩ ដំពូក ហើយបានប្រែចេញជាភាសាបារាំងផង តំកល់ទុកក្នុងទូមាន ៩៩ ថត ។ ឯកសារទាំងនោះមានប្រយោជន៍ដល់អ្នកស្រាវជ្រាវបរទេសផង ដល់ខេមរជនផងដែលក្រុមជំនុំតែងបានទទួលជនរួមជាតិនឹងជនបរទេស ចូលមកសួរកិច្ចការអំពីទំនៀមទម្លាប់ខ្មែរសឹងតែរាល់ថ្ងៃ ។

ក្នុងប៉ុន្មានឆ្នាំនេះ ក្រុមជំនុំបានចាត់ការតាមគោលដៅដូចរៀបរាប់ខាងមុខនេះ ៖

១– ប្រមូលឯកសារស្តីអំពីជាតិពន្ធសាស្ត្រខ្មែរ គឺប្រវត្តិការណ៍ផ្សេង ៗ - បច្ចេកទេស - ទំនៀម - ជំនឿ ។ ល ។ ដែលមានសេចក្តីអធិប្បាយសព្វគ្រប់យ៉ាងហ្មត់ចត់ ។

២– ផ្សាយជាភាសាខ្មែរ នូវទំនៀមដោយពួក ៗ ដែលបានចេញសៀវភៅព្រះរាជពិធីទ្វាទសមាស ៣ ភាគរួចមកហើយ ព្រមទាំងសៀវភៅប្រជុំរឿងព្រេង ៣ ភាគផង ដែលបានបោះពុម្ពរួចហើយ ។

៣– ផ្សាយជាភាសាបារាំងនិងភាសាអង់គ្លេស នូវសៀវភៅស្តីអំពីទំនៀមជនជាតិខ្មែរ ដែលបានចេញសៀវភៅទី ១ និងទី ២ រួចហើយ គឺពិធីទ្វាទសមាស ១ ភាគ ពិធីក្នុងគ្រួសារខ្មែរ ១ ភាគ ជាភាសាបារាំង ។ ឯសៀវភៅទី ៣ មួយក្បាលទៀត ស្តីអំពីជីវភាពខ្មែរជាភាសាបារាំងដែរ កំពុងរៀបរៀងសព្វថ្ងៃនេះ ។

៤– ធ្វើជាសារមន្ទីរមួយទុកនៅការិយាល័យទំនៀមទម្លាប់ សម្រាប់ដំកល់ទុកនូវសំណាកវត្ថុដែលជាកេរ្តិ៍ដំណែលរបស់ខ្មែរ ព្រមទាំងមានផ្ទាំងគំនូររូបភាពដំណាងទំនៀមផ្សេង ៗ ជាជំនួយសេចក្តីអធិប្បាយទៀតផង ។

ក្រៅពីការធម្មតា ជាអាទិ៍គឺការអង្កេត ការពិនិត្យស្រាវជ្រាវ ការប្រែឯកសារជាភាសាបរទេស និងការតែងជាសៀវភៅស្តីអំពីទំនៀមទម្លាប់ខ្មែរ ដើម្បីបោះពុម្ពផ្សាយ មានការប្រឡងប្រជែងជ្រើសយកឯកសារទំនៀមទម្លាប់ប្រចាំឆមាសរៀងរាល់ឆ្នាំ ។ សម្រាប់ឆមាសទី ១ ឆ្នាំ ១៩៦២ នេះ បានបើកការប្រឡងប្រជែង ២ មុខ ទី ១ អំពីរឿងរាមកេរ្តិ៍ដែលទាក់ទងដោយទំនៀមទម្លាប់ខ្មែរ ទី ២ អំពីពិធីឲ្យឈ្មោះមនុស្ស ឈ្មោះសត្វ ឈ្មោះទីលំនៅ និងឈ្មោះរបស់ប្រើប្រាស ។

ក្នុងរវាង ៦ ខែនេះ ក្រុមជំនុំបានទទួលឯកសារ ១៨ រឿង អំពីបេក្ខជន និងអំពីសមាជិកគឺ:

- លោក ឌួង-អ៊ិច អតីតមេឃុំ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ឯកសារជើងកមកេរ្តិ៍ នឹងពិធីឲ្យឈ្មោះ ។

- លោកគ្រូ ឈាុប-ភាង វត្តអង្គព្រះចេតិយ ឃុំអង្គតាសោម ស្រុកត្រាំកក់ (តាកែវ) ពិធីឲ្យឈ្មោះ ។

- លោក ឌឹក-តាម ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញភាសា-សាស្ត្រខ្មែរ ។

- លោកគ្រូ ចាម-ចន្ទ វត្តគីរោ ឃុំខ្នារស ស្រុកស្រីសន្ធរ (កំពង់ចាម) ជើងកមកេរ្តិ៍នឹងពិធីឲ្យឈ្មោះ ។

- លោក ប៊ូ-ប៊ូ ផ្ទះលេខ ៦៣៩ មហាវិថីព្រះបាទមុនីវង្ស សង្កាត់លេខ ៤ ភ្នំពេញ ជើងបុណ្យផ្កា ។

- លោក កៀត-គី ឃុំកំពង់ហ្លួង ស្រុកពញាឮ កណ្ដាល ជើងកមកេរ្តិ៍នឹងពិធីឲ្យឈ្មោះ ។

- លោក ពេជ្រ-ធិត ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ជើងទូកអុំ នឹងទូកចែវប្រណាំង ។

- លោក ម៉ាក់-ម៉េង ឃុំអង្គតាសោម ស្រុកត្រាំកក់ (តាកែវ) ជើងកមកេរ្តិ៍ ។

លោកគ្រូ កែវ-ដៃ វត្តគីរោ ឃុំខ្នារស ស្រុកស្រីសន្ធរ (កំពង់ចាម) ជើងកមកេរ្តិ៍ ។

- លោក កៅ - យិ ឃុំបឹងគ្រាញ់ ស្រុកសំពេង (តាកែវ) ពិធីឡូឈ្មោះទីងកំណើតគ្នីង ។

- លោក ជឹម - ឈិ ឃុំបុស្សព្រៃ ស្រុកសណ្ដាន់ (កំពង់ធំ) រៀងកាមកេ្ដ ទីងពិធីឡូឈ្មោះ ។

- លោក សេក - សែត ឃុំតាំងក្រសាំង ស្រុកសន្ទុក (កំ-ពង់ធំ) រៀងកាមកេ្ដ ទីងពិធីឡូឈ្មោះ ។

- លោក ម្រាក់ - ខាត់ ឃុំពង្រ ស្រុកឆ្លូង (ក្រចេះ) ពិធីឡូឈ្មោះ ។

ក្រុមជំនុំបានជួបជុំពិនិត្យរៀញសាប្រឡងដោយហ្មត់ចត់ ឃើញបានលទ្ធផល ដូចរៀបរាប់ខាងមុខ :

ផ្នែករៀងកាមកេ្ដ

- លេខ ១ បានដល់លោក កែវ - កុល ឃុំអង្គតាសោម ស្រុកត្រាំកក់ (តាកែវ) រង្វាន់ ៧០០៛០០ ។

- លេខ ២ បានដល់លោក ជឹម - ឈិ ឃុំបុស្សព្រៃ ស្រុកសណ្ដាន់ (កំពង់ធំ) រង្វាន់ ៥០០៛០០ ។

- លេខ ៣ បានដល់លោក សេក - សែត ឃុំតាំងក្រសាំង ស្រុកសន្ទុក (កំពង់ធំ) ៤០០៛០០ ។

- លេខ ៤ បានដល់លោក ច្រាក់ - ខាត់ ឃុំពង្រ ស្រុកឆ្លូង (ក្រចេះ) រង្វាន់ ២០០៛០០ ។

ផ្នែកពិធីឲ្យឈ្មោះ

- លេខ ១ បានដល់លោក ឡុង - អ៊ិច អតីតមេឃុំ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស (តាកែវ) រង្វាន់ ៧០០៛០០ ។

- លេខ ២ បានដល់លោក កៀត - គី ឃុំកំពង់ហ្លួង ស្រុកពញាឮ (កណ្ដាល) រង្វាន់ ៥០០៛០០ ។

- លេខ ៣ បានដល់លោក កៅ - យី ឃុំបឹងត្រាញ់ ស្រុកសំរោង (តាកែវ) រង្វាន់ ៤០០៛០០ ។

លេខ ៤ បានដល់លោកគ្រូ ឈាប - ភាង វត្តអង្គព្រះចេតិយ ឃុំអង្គតាសោម ស្រុកត្រាំកក់ (តាកែវ) រង្វាន់ ២០០៛០០ ។

រង្វាន់ដែលត្រូវបានដល់អ្នកប្រឡងជាប់ ក្រុមជំនុំបានជូនគ្រប់រូបរួចហើយ ។

ចំណែករង្វាន់ដែលត្រូវបានដល់សមាជិកឆ្លើយធួន ក្រុមជំនុំនឹងជូននៅថ្ងៃខាងមុខ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ មានអំណរណាស់ ចំពោះការដែលលោកអ្នកជាបេក្ខជន ឬ ជាសមាជិកបានយកចិត្តទុកដាក់រៀបរៀងឯកសារ

មកដាក់ប្រឡង ឬធ្វើអំណោយក្នុងខមាសទី ១ ឆ្នាំ ១៩៦២ រួចមកហើយ

នៅឆមាសទី ២ ឆ្នាំដដែលនេះ មានបើកការប្រឡង ២ មុខទៀត គឺ-

អំពីពពីល ១ មុខ អំពីទឹក ១ មុខ ដូចបានថែកប្រកាសប្រឡងផ្សាយទូទៅ

តាមខែត្រ ស្រុក និងជនបទនានារួចហើយ សូមព្រះតេជគុណនិងអស់

លោកអ្នកយកព្រះទ័យនិងយកចិត្តទុកដាក់ជួយទំនុកបម្រុងក្រុមជំនុំទំនៀម

ទម្លាប់ ដោយការតែងឯកសារទៅដាក់ប្រឡង ឬទៅធ្វើអំណោយត

ទៅទៀត សូមទទួលអំណរគុណទុកជាមុន !

## ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ផ្នែកបច្ចុប្បន្នភាពជាតិ

# ពិធីសម្ពោធព្រះវិហារអាពាធិការនុគ្រោះ

នៅក្នុងមន្ទីរពេទ្យព្រះកុសុមៈ មានការស្ថាបនាព្រះវិហារតូច ១ មានបណ្ដោយ ១៦ ម. ទទឹង ៦ ម. ធ្វើអំពីបេតុងអារម៉េ ដំបូលឈើប្រក់ក្បឿង ជហ្លាជង្ដការសុទ្ធតែធ្វើអំពីស៊ីម៉ងត៍ទាំងអស់ ។ នៅតាមបរិវេណនៃឃឿនខាងក្រៅ មានបណ្ដោយ ២២ ម. ទទឹង ១៨ ម. ក្រាលឥដ្ឋពណ៌យ៉ាងរលើបរលោងល្អឆើតឆាយ គួរជាទីទស្សនាទីជាទីមនោរម្យ ។

ព្រះវិហារអាពាធិការនុគ្រោះនេះ ស្ថាបនានៅខាងកើតជាប់នឹងមន្ទីរពេទ្យ ។ ការចាប់ផ្ដើមគំនិតស្ថាបនានេះ តាំងពីថ្ងៃសម្ពោធមន្ទីរពេទ្យព្រះកុសុមៈម៉្លេះ គឺតាំងពីថ្ងៃទី ២១ កុម្ភៈ ១៩៥៦ មក អ្នកដែលផ្ដើមគំនិតដ៏ប្រសើរនេះ គឺសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ដោយមានការជួយឧបត្ថម្ភយ៉ាងពេញទំហឹង អំពីគហបតី តាង-ហុង់អាង នឹងភរិយារបស់លោក ។ បន្ទាប់មកព្រះតេជព្រះគុណ រាជ-គាំង នឹងពុទ្ធបរិស័ទជាច្រើនទៀត ដែលមានសទ្ធាយ៉ាងមុតមាំ បានជួយខ្នះខ្នែងដោយកម្លាំងធនធាន កម្លាំងកាយ នឹងកម្លាំងចិត្ត លុះត្រាតែសំណង់នេះ បានសម្រេចរូបរាងជាព្រះវិហារយ៉ាងមនោរម្យ គួរដល់ការធ្វើសង្ឃកម្មតាមវិន័យបញ្ញត្តិនៃព្រះពុទ្ធសាសនា ។

លុះព្រះវិហារអាពាធិកានុគ្រោះ ទៅមន្ទីរពេទ្យព្រះកុសុមៈនេះសម្រេចហើយ កាលពីរាត្រីនៃថ្ងៃទី ១៥ កក្កដា ១៩៦២ មានការរៀបចំធ្វើបុណ្យឧទ្ទិស ទានបញ្ចុះខណ្ឌសីមា យ៉ាងមហោឡារិក ក្រោមការឧបត្ថម្ភនៃក្រុមអភិបាលសមាគមគិលានសង្គ្រោះ ដែលមានសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ជាប្រធាន ។

លុះព្រឹកឡើងថ្ងៃទី ១៦ កក្កដា ១៩៦២ វេលាម៉ោង ៨ ព្រឹក សម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាឯកភាពជាតិ បានស្តេចយាងដល់មន្ទីរពេទ្យព្រះមហាក្សត្រិយានីកុសុមៈតាមព្រះទីនាំងរថយន្ត ដោយមានសមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក និងឥស្សរៈជនជាន់ខ្ពស់ជាច្រើនតាមហែអមព្រះរាជដំណើរផង សម្តេចព្រះបិតាជាតិ ស្តេចបានយាងចូលទៅក្នុងឧបដ្ឋានសាលា នៅបរិវេណនៃគិលានដ្ឋានព្រះមហាក្សត្រិយានី ដើម្បីថ្វាយបង្គំព្រះសង្ឃ ដែលមានជាអាទិ៍គឺព្រះសង្ឃនាយកទាំងពីរគណៈជាប្រធានក្នុងទីនោះ នៅត្រង់មាត់ទ្វារចូល សម្តេចព្រះប្រមុខរដ្ឋទ្រង់ស្តេចបានទទួលបាច់ផ្កាពីកញ្ញាបីរូប ដែលបានថ្វាយចំពោះព្រះអង្គ ជានិមិត្តរូបនៃការថ្វាយព្រះពរស្វាគមន៍ចំពោះសម្តេចឪ ។

បន្ទាប់មក សម្តេចព្រះបិតាជាតិ បានស្តេចយាងចូលទៅក្នុងព្រះវិហារថ្មី ដើម្បីទ្រង់កាត់ឫសសីមា ហើយព្រះសង្ឃបានស្វាធ្យាយព្រះពុទ្ធមន្តជយន្តោប្រសិទ្ធិពរជ័យថ្វាយព្រះអង្គជាកិច្ចបង្ហើយពិធីនេះ ។

លុះព្រះសង្ឃស្វាធ្យាយព្រះពុទ្ធមន្តជ័យនោះចប់ សម្តេចព្រះមហាសុមេធាធិបតី បានថ្លែងសេចក្តីយ៉ាងខ្លីថ្វាយព្រះរាជកុសលចំពោះសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ និងសម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ ។

សម្តេចព្រះប្រមុខរដ្ឋ ស្តេចបានយាងនិវត្តន៍ កាន់ព្រះរាជដំណាក់វិញ នៅវេលាម៉ោង ១០ និង ៣០ នាទី ដោយសុវត្ថិភាព ។

---

រីគ្រូបាធ្យាយ អាចឲ្យពណ្ណកាយ មានរូបស្មើ ហើយឲ្យរុងរឿង
អស់បញ្ចឥន្ទ្រិយ ស្មើព្រះជននី ជនកសោតហោង ។ ព្រះជនកសោត-
ណា បង្កើតអាត្មា ឲ្យមានសរីរផង រក្សាពីតូច មិនឲ្យមានហ្មង
អស់សុខទុក្ខផង តាំងដែលនឹងធ្ងន់ ។ ព្រះជនកព្រះជននី បើនឹងស្រដី
ប្រសើរពេកពន់ ថាភ្នំព្រះសុមេរុ នោះហោងមហាធ្ងន់ ថាបើនឹង-
គណន៍ ពុំអាចកន្លង ។ រីគ្រូបាធ្យាយ ប្រដូចនូវមាតា អាពុកឯង-
ហោង អាចឲ្យក្តីច្បាប់ ប្រដៅធម៌ផង ដោយនូវគន្លង ព្រះពុទ្ធតាំង-
ឡាយ ។ នរអ្នកណា តោះមានប្រាជ្ញា ឲ្យគិតវែងឆ្ងាយ គុណ-
លោកតាំងបី ហៅមហាទូលាយ កុំឲ្យអន្តរាយ ក្តីព្យាយាម ។

# សម្ដេចឪជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភ
# បានស្ដេចយាងជាព្រះអធិបតីក្នុងពិធីបញ្ចុះសីមាវត្តអង្គសិម្ពលី
# ស្រុកភ្នំពេញ (កណ្ដាល) ។

---

ក្នុងព្រះឋានៈព្រះអង្គជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភ សម្ដេចព្រះប្រមុខរដ្ឋព្រះបិតាជាតិ ជាទីគោរព ស្ដេចបានយាងទៅជាព្រះអធិបតី ក្នុងពិធីបញ្ចុះសីមាវត្តអង្គសិម្ពលី ឃុំពើក តំបន់អង្គស្នួល ស្រុកភ្នំពេញ ខេត្តកណ្ដាល នៅពេលព្រឹកថ្ងៃទី ១ សីហា ១៩៦២ ។

នៅវេលាម៉ោង ៨ និង ៣០ នាទី នៅទីវត្តអង្គសិម្ពលី មានសភាពអ៊ូអរយ៉ាងក្រៃលែង ពេញពោរទៅដោយមនុស្សម្នាមហាជនយ៉ាងកកកុញ ជាពិសេសគឺព្រះសង្ឃពួកពុទ្ធបរិស័ទ និងឥស្សរជនជាភ្ញៀវកិត្តិយសទាំងឡាយ បាននិមន្តនិងអញ្ជើញទៅដល់ជាបន្តបន្ទាប់គ្នា ដែលយើងបានសង្កេតឃើញជាអាទិ៍នៅពេលនោះគឺ : ផ្នែកព្រះសង្ឃមានសម្ដេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្ត ព្រះគ្រូមង្គលមេធា អ៊ុំ-អ៊ួង ចៅអធិការវត្តអង្គសិម្ពលីវនារាម ព្រះគ្រូសាសនសោភ័ណ ជុន-សាលី វត្តបទុមវតីរាជវរារាម ។

ចំណែកខាងគ្រហស្ថ យើងបានសង្កេតឃើញជាអាទិ៍នៅពេលនោះគឺ : សហជីវិន ចៅសែនគោសល ប្រធានរដ្ឋសភា ឯកឧត្ដម ក្វ-រុង

សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក សហជីវិន ឃួន-គឹមម៉ង ចេង-ហោង លោកវរសេនីយឯក មាស-ហ៊ីល ។

ចំណែកខាងឥស្សរជនស៊ីវិលក្នុងខេត្ត យើងបានសង្កេតឃើញជាអាទិ៍គឺ សហជីវិន ឆេត-សុង ចៅហ្វាយខេត្តកណ្ដាល សហជីវិន ហួត-ថន ចាងហ្វាងសាលាដំបូងកណ្ដាល សហជីវិន សៅ-វ៉ា ព្រះរាជអាជ្ញា ។

នៅវេលាម៉ោង ៩ ព្រះទីនាំងឧទ្ធម្ភាគចក្រ ដែលបើកបរដោយអនុសេនីយទោ ឈុន-កៀង បានដឹកនាំព្រះរាជដំណើរនៃសម្ដេចឪទៅចុះចតនៅកន្លែងប្រារព្ធពិធី ដែលនៅទីនោះ ក្រោយដែលព្រះអង្គទ្រង់យាងចុះពីព្រះទីនាំងឧទ្ធម្ភាគចក្រ សម្ដេចឪព្រះបិតាជាតិ បានទទួលបាច់ផ្កាពីកញ្ញាពីររូប ដែលបានថ្វាយចំពោះព្រះអង្គ ជានិមិត្តរូបនៃសេចក្ដីស្នេហាស្វាមីភក្ដិ និងថ្វាយព្រះពរស្វាគមន៍ដំណាងឥស្សរជន មន្ត្រីរាជការទាហាន ស៊ីវិល និងប្រជាពលរដ្ឋទាំងអស់ ។ បន្ទាប់មកទ្រង់បានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជន ទាហាន ស៊ីវិល ដែលមានលោកប្រមុខខេត្ត បានរង់ចាំក្រាបថ្វាយបង្គំព្រះអង្គនៅទីនោះ ។

ក្រោយដែលបានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជន ទាហាន ស៊ីវិលទាំងអស់រួចហើយ ព្រះអគ្គមគ្គុទ្ទេសជាតិ ស្ដេចយាងទៅទទួលការក្រាបថ្វាយបង្គំ ពីមន្ត្រីភ្នាក់ងាររាជការ យុវ័ន យុវតី និងប្រជា

ពលរដ្ឋទាំងអស់ ដែលឈរអមសងខាងផ្លូវឡើងទៅកាន់វេទិកាពិសេស ដែលតាំងនៅក្នុងបរិវេណនៃព្រះវិហារថ្មី ។ ពេលនោះកងខេមរភូមិន្ទបាន លើកអាវុធវន្ទា និងបន្ទូបទក្លែងបរលីលាថ្វាយជាព្រះរាជកិត្តិយស ។

បន្ទាប់ពីនេះ សម្តេចព្រះប្រមុខរដ្ឋ បានស្តេចយាងឡើងលើវេទិកាពិសេសថ្វាយបង្គំព្រះសង្ឃ ដែលមានសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តជាប្រធាន ។

ក្រោយដែលបានថ្វាយបង្គំព្រះសង្ឃ និងក្រោយដែលព្រះអង្គទ្រង់សម្រួលព្រះឥរិយាបថបន្តិចមក ក៏មានធ្វើពិធីគោរពទង់ជាតិ ហើយព្រះសង្ឃបានសូត្រព្យាយព្រះពុទ្ធមន្តជយន្តោប្រសិទ្ធិពរជ័យ ហើយតមកយុវតីមួយក្រុមស្លៀកពាក់យ៉ាងស្អាត បានច្រៀងថ្វាយព្រះពរជ័យគួរជាទីចាប់អារម្មណ៍ក្រៃលែង ។

បន្ទាប់មក ព្រះគ្រូសាសនសោភ័ណ ជួន-សាលី វត្តបទុមវតីតំណាងព្រះសង្ឃ និងពុទ្ធបរិស័ទទាំងអស់ក្នុងវត្តអង្គសិម្ពលីបានថ្វេងសុន្ទរកថាមួយ រៀបរាប់ជាអាទិ៍អំពីប្រវត្តិនៃការកសាងព្រះវិហារនោះ ។

លុះចប់សុន្ទរកថានៃព្រះគ្រូសាសនសោភ័ណនេះមក សម្តេចព្រះប្រមុខរដ្ឋ បានស្តេចប្រគេននិងប្រោសព្រះរាជទានព្រះសង្កថាឥតព្រាងមួយដែរ ដែលមានអត្ថន័យដ៏សែនពិរោះនិងជាទីចាប់ចិត្តយ៉ាងពន់ពេក ។

លុះចប់ព្រះសង្ឃថា ប្រកបដោយគត្ថន័យដ៏ជ្រាលជ្រៅនេះមក ព្រះបិតាជាតិជាទីគោរព ស្តេចយាងឡើងកាន់ព្រះវិហារថ្មី ដែលជាទីប្រារព្ធបញ្ចុះសីមា យាំងមហោឡារិកនាព្រឹកថ្ងៃនោះ ដើម្បីជាព្រះអធិបតីក្នុងពិធីកាត់ឫសសន្ទតខណ្ឌសីមា ។

ក្រោយដែលព្រះអង្គនឹងពុទ្ធបរិស័ទទាំងឡាយ បានទទួលស្គាល់ព្រះរតនត្រៃនឹងសមាទានសីលតាមប្រពៃណីនៃព្រះពុទ្ធសាសនារួចហើយ ពិធីកាត់ឫសសីមា ដែលមានព្រះសង្ឃបានស្វាធ្យាយជ័យន្តោប្រសិទ្ធិពរជ័យផង ក៏បានប្រារព្ធធ្វើឡើងគ្រប់ទាំង ៨ ទិស ដែលមានសម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទ្រង់ជាព្រះអធិបតី ក្រោយដែលស្គរគងទី ៣ បានចាប់ផ្តើមឡើង ។

ពិធីកាត់ឫសសន្ទតខណ្ឌសីមានេះ បានចប់សព្វគ្រប់នៅវេលាម៉ោង ១២ ថ្ងៃត្រង់ ។

សម្តេចព្រះអគ្គមគ្គុទ្ទេសក៍ជាតិ ស្តេចបានថ្វាយបង្គំព្រះសង្ឃ នឹងលាឥស្សរជន ព្រមទាំងប្រជាពលរដ្ឋ ជាកូនចៅព្រះអង្គ យាងនិវត្តចូលព្រះរាជដំណាក់វិញ ដោយព្រះសុវត្ថិភាព ។

យើងសូមបញ្ជាក់ថា ក្នុងឱកាសដែលសម្តេចឪជាទីគោរពស្តេចយាងទៅជាព្រះអធិបតី ក្នុងពិធីបញ្ចុះសីមាវត្តអង្គសិម្ពលីនាព្រឹកថ្ងៃនោះ ព្រះអង្គបានទ្រង់ប្រោសព្រះរាជទានសំពត់ជាច្រើនរយម៉ែត្រ ដល់កូនចៅព្រះអង្គនៅដំបន់នោះផង ។